សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# ការប្រៀបធៀបយុត្តាធិការរបស់តុលាការយុត្តធម៌អន្តរជាតិ និង តុលាការព្រហ្មទណ្ឌអន្តរជាតិ

សរសេរសារណាពីថ្ងៃទី២៧ ខែមេសា ឆ្នាំ ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ: **រិន សោមពៅនិកា**

**ហេង នីធី**

សាស្ត្រាចារ្យណែនាំ

**លោក ឡឿក ពិដោរ**



ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា **២០១៧**

ឆ្នាំសរសេរសារណា **២០២១**

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំ **រិន ឆោមពៅនិកា** និង **ហេង នីទី** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០២០-២០២១ សូមសម្តែងនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅជូនចំពោះ៖

- **លោកឪពុក អ្នកម្តាយ** ដ៏មានគុណមិនអាចកាត់ថ្លៃបាននៃយើងខ្ញុំទាំងពីរ ដែលបានផ្តល់កំណើតនិងចិញ្ចឹមបីបាច់ថែរក្សាកូន ដោយចិត្តសណ្តោសប្រណី អប់រំប្រៀនប្រដៅ ប្រកបដោយ ព្រហ្មវិហារធម៌ គុណធម៌ សប្បុរសធម៌ ព្រមទាំងឱ្យកូនបានរៀនសូត្រខ្ពង់ខ្ពស់។
- **ឯកឧត្តមសាកលវិទ្យាធិការ លុយ ចណ្ណា** សកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង នៃសាកលវិទ្យា-ល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្តល់ឱកាសឱ្យយើងខ្ញុំទាំងពីរបានសរសេរសារណាបញ្ចប់ការសិក្សានេះផងដែរ។
- **សាស្ត្រាចារ្យណែនាំ ឌឿក ពិដោរ** ដែលលោកបានយកចិត្តទុកដាក់ពន្យល់យើងទាំងពីរពីរបៀបតាក់តែង និងចំណុចខ្វះខាតរបស់យើងជាប្រទីបបំភ្លឺផ្លូវឱ្យយើងដើរត្រូវចំគោលដៅ និងទទួលបានជោគជ័យជាស្ថាពរនៃការសរសេរសារណាបញ្ចប់ការសិក្សានេះ។

ជាទីបញ្ចប់ យើងខ្ញុំទាំងពីរ សូមបួងសួងដល់វត្ថុស័ក្តសិទ្ធក្នុងលោក សូមព្រះប្រទានពរជ័យ សិរីមង្គល ដល់លោកអ្នកមានគុណនៃយើងខ្ញុំទាំងពីរ ឯកឧត្តមសាកលវិទ្យាធិការ លោកសាស្ត្រាចារ្យណែនាំ និងសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមឱ្យអស់លោកទទួលបាននូវសុខភាពល្អ ប្រាជ្ញាវាងវៃ ជោគជ័យគ្រប់ភារកិច្ច ជាពិសេសជួបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុវណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចអស់រយៈពេល៤ឆ្នាំ កន្លងមកនេះ យើងខ្ញុំមានការចាប់អារម្មណ៍ជាខ្លាំងលើមុខវិជ្ជានីតិអន្តរជាតិសាធារណៈ។ យើងខ្ញុំរំពឹងថា នៅពេលបញ្ចប់ថ្នាក់បរិញ្ញាបត្រគឺច្បាស់ណាស់នឹងរើសយកប្រធានបទមួយដែលទាក់ទិននឹងនីតិអន្តរជាតិសាធារណៈមកសរសេរជាអត្ថបទសារណា។ ជាលទ្ធផលនៅឆ្នាំទី៤ ឆមាសទី១ ឈ្មោះរបស់យើងទាំងពីរត្រូវបានសាលាតម្រូវឱ្យសរសេរសារណាដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រ។ ខណៈនោះយើងខ្ញុំក៏បានស្នើសុំយោបល់ពី លោកសាស្ត្រាចារ្យ **ឌឿក ពិដោរ** អំពីប្រធានបទមួយស្តីពីការប្រៀបធៀបយុត្តាធិការរបស់តុលាការយុត្តិធម៌អន្តរជាតិ និងតុលាការព្រហ្មទណ្ឌអន្តរជាតិ។ ក្រោយពីលោកគ្រូបានសាកសួរយើងខ្ញុំខ្លះៗអំពីប្រធានបទនេះហើយលោកក៏បានឯកភាព និងបានណែនាំយើងខ្ញុំឱ្យសរសេរសារណាមួយនេះ។

សារណានេះបានកើតចេញជាផ្លែផ្កាបានដូចនេះគឺ អាស្រ័យលើកិច្ចខិតខំប្រឹងប្រែងរបស់យើងខ្ញុំផ្ទាល់ក្នុងការបកស្រាយ និងវិភាគបែបប្រៀបធៀបអំពីស្ថាប័នអន្តរជាតិដ៏សំខាន់ពីររបស់ពិភពលោក។ ប្រធានបទរបស់យើងត្រូវបានចងក្រងឡើងដោយ យើងខ្ញុំបានខិតខំរកគ្រប់ឯកសារពាក់ព័ន្ធទាំងអស់ហើយភាគច្រើន គឺជាឯកសារអន្តរជាតិ និងពុំសូវមានសវតានៃការស្រាវជ្រាវពីមុនមកនោះទេ។ យើងជឿជាក់ប្រធានបទសារណានេះមានភាពល្អប្លែកគេ ប៉ុន្តែយើងមានការលំបាកក្នុងការបកប្រែភាសាបច្ចេកទេសច្បាប់អន្តរជាតិមកជាភាសាខ្មែរឱ្យត្រូវសមសួន។ ដូច្នេះការបកឱ្យចំអត្ថន័យមានភាពខ្វះខាតមួយចំនួនដែលជាហេតុធ្វើឱ្យខ្លឹមសារស្រាវជ្រាវយើងខ្ញុំមិនមានលក្ខណៈគ្រប់ជ្រុងជ្រោយដល់អ្នកអាន និងអ្នកស្រាវជ្រាវដែលចំបាច់ណាស់យើងខ្ញុំសុំធ្វើការអភ័យទោសទុកជាមុន។ ទោះយ៉ាងណាយើងខ្ញុំសង្ឃឹមថាសារណានេះនឹងក្លាយទៅជាឯកសារជំនួយស្មារតីក្នុងការសិក្សាស្រាវជ្រាវ និងជាគន្លឹះជួយបំភ្លឺផ្លូវដល់និស្សិតជំនាន់ក្រោយ និងអ្នកអាន អ្នកស្រាវជ្រាវទូទៅបាន។

ជាចុងបញ្ចប់ ប្រសិនបើមានកង្វះខាត ឬ កំហុសឆ្គងត្រង់ចំណុចណាមួយ យើងខ្ញុំសូមទទួលយកនូវការរិះគន់ពីសំណាក់ លោក លោកស្រីសាស្ត្រាចារ្យ សិស្ស និស្សិត គ្រប់មជ្ឈដ្ឋានទាំងអស់ដើម្បីស្ថាបនាសមត្ថភាព ដោយក្តីគោរព និងក្តីគោរពរាប់អានយ៉ាងកក់ក្តៅបំផុតដើម្បីឱ្យសារណាមួយនេះមានភាពកាន់តែប្រសើរ។

## មាតិកា


តារាងសម្គាល់អក្សរកាត់.......................................................vii

សេចក្តីផ្តើម .......................................................................... ១

ជំពូកទី១៖ យុត្តាធិការតុលាការយុត្តធម៌អន្តរជាតិ និង យុត្តាធិការតុលាការព្រហ្មទណ្ឌអន្តរជាតិ .......................................................................... ៨

ផ្នែកទី១៖ យុត្តាធិការរបស់តុលាការយុត្តធម៌អន្តរជាតិ .......................... ៨

កថាខណ្ឌទី១៖ យុត្តាធិការលើជម្លោះអន្តរជាតិ (Contentious Jurisdictions)............. ១០

១.ការទទួលយកយុត្តាធិការICJដោយឯកតោភាគី.......................................១២

១.១ បទប្បញ្ញត្តិទូទៅ .....................................................................១២

១.២ បទប្បញ្ញត្តិពិសេស ..................................................................១៣

១.២.១ ការផ្តល់ឱ្យនូវយុត្តាធិការ ....................................................១៣

១.២.២ អវសានប្បញ្ញត្តិ ..................................................................... ១៥

១.២.៣ ការចុះហត្ថលេខា ................................................................... ១៥

២.ការទទួលយកយុត្តាធិការICJដោយសន្ធិសញ្ញា....................................... ១៥

២.១ បទប្បញ្ញត្តិទូទៅ ........................................................................ ១៥

២.២ បទប្បញ្ញត្តិពិសេស ...................................................................... ១៦

២.២.១ ភាគីនៃសន្ធិសញ្ញាដែលផ្តល់យុត្តាធិការឱ្យICJលើជម្លោះបកស្រាយសន្ធិសញ្ញា.......................................................................... ១៦

២.២.២ ភាគីនៃសន្ធិសញ្ញាដែលផ្តល់យុត្តាធិការឱ្យICJលើជម្លោះផ្លូវច្បាប់រវាងភាគី.......................................................................... ១៧

៣.ការទទួលយកយុត្តាធិការតុលាការICJដោយកច្ចព្រមព្រៀងពិសេស ............ ១៧
៣.១ បទប្បញ្ញត្តទូទៅ........................................................................ ១៧
៣.២ បទប្បញ្ញត្តពិសេស ...................................................................... ១៨
៣.២.១ នីតិវិធីផ្តល់យុត្តាធិការតាមរយៈកច្ចព្រមព្រៀងពិសេស ................. ១៩
៤. ការទទួលយកយុត្តាធិការICJដោយសេចក្តីប្រកាសរបស់រដ្ឋឆ្លើយតប..........២១
កថាខណ្ឌទី២៖ យុត្តាធិការប្រឹក្សាយោបល់..............................................២២
ផ្នែកទី១៖ អង្គការមានសមត្ថកិច្ចដាក់សំណើសុំការប្រឹក្សាយោបល់......................... ២៣
១.១ អង្គការមានសមត្ថកិច្ចដោយផ្ទាល់ ..................................................... ២៣
១.១.១ មហាសន្និបាត .......................................................................... ២៣
១.១.២ ក្រុមប្រឹក្សាសន្តិសុខ ..................................................................២៤
១.២ អង្គការមានសមត្ថកិច្ចដោយប្រយោល .................................................២៥
១.២.១ អង្គការសំខាន់ៗដទៃទៀតរបស់អង្គការសហប្រជាជាតិ................២៦
១.២.១.១ ក្រុមប្រឹក្សាសេដ្ឋកិច្ច និង សង្គម ...............................................២៦
១.២.១.២ អគ្គលេខាធិការ ......................................................................២៦
១.២.២ ភ្នាក់ងារពិសេស ......................................................................... ២៧
២. លក្ខខណ្ឌក្នុងការស្នើសុំយោបល់ ......................................................... ២៧
២.១ ដែនសិទ្ធិនៃការស្នើសុំរបស់អង្គការ......................................................... ២៧
២.២ ការបោះឆ្នោត និង ប្រធានបញ្ហានៃសំណើ...............................................២៨
២.៣ បែបបទក្នុងការរៀបចំសំណើសុំយោបល់ ..............................................២៩
ផ្នែកទី២៖ យុត្តាធិការតុលាការព្រហ្មទណ្ឌអន្តរជាតិ ...................................................២៩
កថាខណ្ឌទី១៖ យុត្តាធិការលើកម្មវត្ថុនៃខាង(Subject-matter Jurisdiction) ..........២៩

១.ឧក្រដ្ឋកម្មប្រល័យពូជសាសន៍ ......... ៣០

២.ឧក្រដ្ឋកម្មប្រឆាំងមនុស្សជាតិ ......... ៣០

៣. ឧក្រដ្ឋកម្មសង្គ្រាម ......... ៣២

៤. ឧក្រដ្ឋកម្មឈ្លានពាន ......... ៣៨

៥. បទល្មើសប្រឆាំងនឹងរដ្ឋបាលយុត្តធម៌ ......... ៣៨

កថាខណ្ឌទី២៖ យុត្តាធិការលើដែនដី ឬបុគ្គល (Territorial or Personal Jurisdiction)..៣៩

១.យុត្តាធិការដែនដី ......... ៣៩

២. យុត្តាធិការសញ្ជាតិ ......... ៣៩

កថាខណ្ឌទី៣៖ យុត្តាធិការលើពេលវេលា(Temporal Jurisdiction) ......... ៤០

ជំពូកទី២៖ ការប្រៀបធៀបយុត្តាធិការតុលាការយុត្តធម៌អន្តរជាតិ និងយុត្តាធិការតុលាការព្រហ្មទណ្ឌអន្តរជាតិ ......... ៤១

ផ្នែកទី១៖ ភាពដូចគ្នា ......... ៤១

កថាខណ្ឌទី១៖ វិសាលភាពនៃយុត្តាធិការ ......... ៤១

១.ចរិតលក្ខណៈនិងសមាជិកភាព ......... ៤១

១.១ យុត្តាធិការដែលបានព្រមព្រៀង ......... ៤១

១.២ យុត្តាធិការដែលមានតួនាទីតែមួយប្រភេទ (ICJ &ICC) ......... ៤១

កថាខណ្ឌទី២៖ ការបង្ហាញឆន្ទៈរបស់រដ្ឋក្នុងការទទួលយកយុត្តាធិការ ......... ៤២

១. ភាគពួកចូររបស់រដ្ឋ ......... ៤២

ផ្នែកទី២៖ ភាពខុសគ្នា ......... ៤២

កថាខណ្ឌទី១៖ ភាគនៃនីតិវិធី ......... ៤៣

កថាខណ្ឌទី២៖ ប្រភេទនៃនីតិវិធី ......... ៤៥

កថាខណ្ឌទី៣៖ ការអនុវត្តយុត្តាធិការ ........................................................ ៤៥

កថាខណ្ឌទី៤៖ ការបញ្ចប់យុត្តាធិការ ........................................................ ៥១

ករណីសិក្សាស្តីពីយុត្តាធិការតុលាការយុត្តធម៌អន្តរជាតក្នុងសំណុំរឿងក្តីប្រាសាទព្រះ
វិហារ ........................................................ ៥៣

ករណីសិក្សាយុត្តាធិការផ្តល់យោបល់របស់តុលាការយុត្តធម៌អន្តរជាតលើភាពស្រប
ច្បាប់នៃការគំរាមកំហែងឬប្រើប្រាស់អាវុធនុយក្លេអ៊ែរ ........................................................ ៥៩

ករណីសិក្សាស្តីពីយុត្តាធិការតុលាការព្រហ្មទណ្ឌអន្តរជាតនៃសំណុំរឿងអតីត
ប្រធានាធិបតីស៊ូដង់ខាងត្បូង លោក Omar Hassan Ahmad Al Bashir ........................................................ ៦៤

សេចក្តីសន្និដ្ឋាន ........................................................ ៦៧

អនុសាសន៍ ........................................................ ៦៩

# តារាងសម្គាល់អក្សរកាត់

ICC: តុលាការព្រហ្មទណ្ឌអន្តរជាតិ ( International Criminal Court )

ICJ: តុលាការយុត្តិធម៌អន្តរជាតិ( International Court Of Justice )

IFAD:អង្គការមូលនិធិអន្តរជាតិដើម្បីអភិវឌ្ឍកសិកម្ម ( International Fund For Agricultural Development )

IMO: អង្គការសមុទ្រអន្តរជាតិ ( International Maritime Organization )

ITLOS: មជ្ឈត្តិការអន្តរជាតិសម្រាប់ច្បាប់សមុទ្រ ( International Tribunal for Law Of The Sea )

LN: សម្ព័ន្ធប្រជាជាតិ ( League of Nations )

PCIA: តុលាការអចិន្ត្រៃយ៍នៃមជ្ឈត្តិការអន្តរជាតិ ( Permanent Court of International Arbitration )

PCIJ: តុលាការអចិន្ត្រៃយ៍នៃយុត្តិធម៌អន្តរជាតិ ( Permanent Court of International Justice )

UN: អង្គការសហប្រជាជាតិ ( United Nations )

UNESCO: អង្គការអប់រំ វិទ្យាសាស្ត្រ និង វប្បធម៌អង្គការសហប្រជាជាតិ ( United Nations of Educational, Scientific And Cultural Organization )

WHO: អង្គការសុខភាពពិភពលោក ( World Health Organization )

# សេចក្តីផ្តើម

ជារៀងរាល់ថ្ងៃ ពិភពលោកយើងនេះតែងតែមានព្រឹត្តិការណ៍ជាច្រើនកើតឡើង។ ព្រឹត្តិការណ៍ទាំងនោះបានក្លាយជាផ្ទាំងទស្សនីយភាពដ៏ជាទីចាប់អារម្មណ៍របស់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ។ អយុត្តិធម៌ បញ្ហាសិទ្ធិមនុស្ស ការរំលោភអំណាចពីសំណាក់រូបវន្តបុគ្គលដែលមានឋានៈ បញ្ហាប្រឈមនឹងការអភិវឌ្ឍ បញ្ហាព្រំដែន បញ្ហាសន្តិសុខអន្តររដ្ឋ ជម្លោះការប្រើប្រាស់ធនធានរួមគ្នារវាងមួយ និងរដ្ឋមួយ នៅតែកើតមាននៅសតវត្សទី២១នេះ។ ដោយសារពិភពលោកយើងទាំងមូលមានលក្ខណៈចម្រុះ មិនថាជាតិ សាសនា ប្រព័ន្ធនយោបាយ របនាសម្ព័ន្ធសង្គម ។ល។ ទេជាហេតុនាំឱ្យពុំអាចមានសោះឡើងការបង្កើតរដ្ឋាភិបាលមួយមកគ្រប់គ្រង។ ទោះបីជាពុំអាចមានស្ថាប័ននីតិប្រតិបត្តិអន្តរជាតិក៏ដោយក្តី ក៏ពិភពលោកសម្រេចមិនទុកឱ្យបញ្ហាអន្តរជាតិកើតឡើងដោយពុំមានដំណោះស្រាយបាននោះទេ។ ជាលទ្ធផលដ៏ច្រើនបានបង្ហាញផងដែរ ថាដំណោះស្រាយដែលពិភពលោកប្រគល់ជូនមានភាពសុក្រិត្យ និងយុត្តិធម៌បំផុត ដោយតាមរយៈផ្លូវច្បាប់នៃបណ្តឹងទៅដល់តុលាការអន្តរជាតិ។ ដោយសារតែកំណើននៃប្រភេទវិវាទធ្ងន់ធ្ងរ ឬរឿងក្តីអន្តរជាតិមានកាន់តែច្រើនធ្វើឱ្យតុលាការអន្តរជាតិចាប់កកើតមានរូបរាងឡើងច្រើនឡើងៗតាមចរិតលក្ខណៈ និងឧបនិស្ស័យខុសគ្នាៗ។ ក្នុងចំណោមនោះគឺ មានតុលាការអន្តរជាតិពីរដែលសកម្មបំផុត ហើយត្រូវបានកត់សម្គាល់ថាមានឥទ្ធិពលជាងតុលាការដទៃទៀតផងបានដោះស្រាយបណ្តឹងរបស់ប្រទេសជាច្រើន។ ក្នុងនោះគឺមានតុលាការមួយឈ្មោះថា តុលាការយុត្តិធម៌អន្តរជាតិ ដែលរាជរដ្ឋាភិបាលកម្ពុជាធ្លាប់បានពឹងអាស្រ័យដើម្បីស្វែងរកយុត្តិធម៌បានសម្រេចក្នុងសំណុំរឿងជម្លោះបូរណភាពដែនដីនៃប្រាសាទព្រះវិហារជាមួយភាគីថៃ។ ចំណែកតុលាការអន្តរជាតិដ៏ទុកចិត្តបានបំផុតឈរនៅលើលំដាប់ទីពីរដោយផ្អែកលើចំនួនរដ្ឋជា សមាជិកដល់ទៅ១២៣ប្រទេសនោះគឺ តុលាការព្រហ្មទណ្ឌអន្តរជាតិ។ ដោយមើលឃើញពីភាពចាំបាច់របស់តុលាការទាំងពីរនេះ សារណារបស់យើងនឹងធ្វើការបង្ហាញឱ្យច្បាស់បំផុតពីសមត្ថកិច្ចដាច់ដោយឡែកពិសេសរៀងៗខ្លួនរបស់តុលាការទាំងពីរ ក្រោមប្រធានបទថា **ការប្រៀបធៀបយុត្តាធិការរបស់តុលាការយុត្តិធម៌អន្តរជាតិ និងតុលាការព្រហ្មទណ្ឌអន្តរជាតិ។**

ប៉ុន្តែដើម្បីជាជំនួយដល់ការបកស្រាយប្រធានបទនេះឱ្យបានស៊ីជម្រៅ និងងាយយល់បំផុតនោះយើងមិនអាចរំលងបានឡើយនូវការឈ្វេងឱ្យយល់នូវពាក្យគន្លឹះសំខាន់ចំនួនពីរឱ្យបានច្បាស់គឺ **«យុត្តាធិការ»** និង **«តុលាការអន្តរជាតិ»** ជាមុនសិន។

យុត្តាធិការគឺជា ពាក្យមួយដែលមិនងាយស្រួលក្នុងការឱ្យនិយមន័យនោះទេ។ តាមនិក្ខេបបទថ្នាក់បណ្ឌិតរបស់លោក Michail Vagias អំពីយុត្តាធិការដែនដីICCបានគូសបញ្ជាក់ថាត្រឹមពាក្យយុត្តាធិការមួយគេប្រើកញ្ចក់អន្តរជាតិមើលក្នុងស្មារតីច្បាប់អន្តរជាតិជាច្រើន។ តាមច្បាប់អន្តរជាតិ ទស្សនៈនៃយុត្តាធិការមានភាព

ទាក់ទងជាខ្លាំងនឹង សញ្ញាណអធិបតេយ្យ ត្បិតបណ្តារដ្ឋទាំងឡាយអាចអនុម័តនូវច្បាប់របស់ខ្លួនលើបញ្ហាទាំងឡាយវាជារឿងផ្ទៃក្នុងរបស់ខ្លួនសុទ្ធសាធ។ មានយុត្តាធិការអន្តរជាតិគឺប្រៀបដូចជាមានចំណងឱ្យរដ្ឋត្រូវតែអនុញ្ញាតប្រគល់ឥទ្ធិពលឯករាជ្យអធិបតេយ្យភាពទៅនឹងច្បាប់ដែលបញ្ជាក់ពីបុគ្គល និងសកម្មភាពដែលត្រូវសម្បទាន។ គោលការណ៍របស់យុត្តាធិការ គឺវាកាត់បន្ថយនូវដែនសមត្ថកិច្ចរវាងរដ្ឋ ធ្វើដូចនេះគឺដើម្បីជាច្បាប់ចរាចរណ៍សម្រាប់សណ្តាប់ធ្នាប់អន្តរជាតិ។ តាមនិក្ខេបបទបណ្ឌិតMichail គឺលោកគូសបញ្ជាក់និយមន័យយុត្តាធិការរបស់លោកFrancis Mann ដ៏ល្បីថា យុត្តាធិការ គឺជាសិទ្ធិរបស់រដ្ឋមួយក្រោមច្បាប់អន្តរជាតិធ្វើនិយ័តកម្មប្រព្រឹត្តកម្មបញ្ហាដោយមិនចាត់ទុកវាជាបញ្ហាក្នុងប្រទេសសុទ្ធសាធនោះទេ ។ វចនានុក្រមច្បាប់Anderson រៀបរាប់ថា យុត្តាធិការ គឺជាអំណាចបើកសវនាការ និងកំណត់ពីបញ្ហា។ និយមន័យនេះ ត្រូវបានអ្នកសិក្សាយកមកពន្លាតថា យុត្តាធិការ គឺជាអំណាចក្នុងការបើកសវនាការ និងសម្រេចកម្មវត្ថុនៃវិវាទចម្រូងចម្រាស់រវាងភាគីហើយអនុវត្តអំនាចយុត្តិធម៌លើពួកគេទាំងមុនអង្គសេចក្តី សវនាការ និងក្រោយសវនាការ។ យោងទៅតាមនិយមន័យ យុត្តាធិការរបស់គេហទំព័រ Law.com វិញ បានពិពណ៌នាថាយុត្តាធិការ គឺជាអំណាចផ្តល់ដោយច្បាប់ទៅឱ្យតុលាការក្នុងការសាកល្បងរឿងក្តី និងគ្រប់គ្រងបញ្ហាច្បាប់លើដែនដីកំណត់ជាពិសេស ឬ លើប្រភេទបទល្មើស។ គេហទំព័រនេះក៏បញ្ជាក់ថា តុលាការរបស់រដ្ឋមានយុត្តាធិការលើរឿងក្នុងរដ្ឋ ហើយតុលាការនីមួយៗមានយុត្តាធិការផ្សេងគ្នាតួយ៉ាងយុត្តាធិការលើទីតាំងនៃជម្លោះត្រូវស្ថិតក្នុងសមត្ថកិច្ចតុលាការណា ជាអ្នកមានសមត្ថកិច្ចក្នុងបណ្តឹងដែលផ្តើមឡើងដោយគូភាគីមកពីណា។ ខណៈតុលាការអន្តរជាតិមានយុត្តាធិការលើក្តីក្តាំងអន្តរជាតិ។

យោងតាមវចនានុក្រមព្រះសង្ឃរាជជួនណាត តុលាការ គឺជាបន្ទំនៃពាក្យតុលា និងការដែលតុលាមាននៃថាថ្លឹងស្ទង់មិនលម្អៀង ពោលតុលាការគឺជាបុគ្គល ឬស្ថាប័នដែលជម្រះក្តីមិនលម្អៀង។ ចំណែក Brian P. Smentkowski សាស្ត្រាចារ្យរងវិទ្យាសាស្ត្រនយោបាយនៃសាកលវិទ្យាល័យQueen of Charlotteបានឱ្យនិយមន័យតុលាការថាជា បុគ្គល ឬ ស្ថាប័ននីតិបុគ្គលដែលមានសិទ្ធិអំណាចខាងតុលាការក្នុងបើកសវនការ និងដោះស្រាយវិវាទក្នុងសំណុំរឿងរដ្ឋប្បវេណីព្រហ្មទណ្ឌសាសនា ឬយោធា។ តុលាការអន្តរជាតិវិញបើ តាមនិយមន័យក្នុងសៀវភៅស្តីពីការបង្ហាញពីការវិនិច្ឆ័យរបស់តុលាការអន្តរជាតិគឺជា អង្គការអន្តរជាតិដែលមានសមាសភាពចៅក្រមឯករាជ្យច្រើនកំណត់ទុកជាមុននូវគោលការណ៍នីតិវិធីលើសេចក្តីសម្រេចនានា តាមមូលដ្ឋានច្បាប់អន្តរជាតិហើយ បើកសវនាការដោយមានភាគីម្ខាងគឺជារដ្ឋ ឬអង្គការអន្តរជាតិ។ ទាក់ទងនឹងបន្ទំពាក្យយុត្តាធិការតុលាការអន្តរជាតិវិញ គឺគ្រប់ដណ្តប់គ្រប់សំណួរទាំងឡាយបានសំដៅមក និងគ្រប់បញ្ហាទាំងអស់ដែលត្រូវផ្តល់សម្រាប់ធម្មនុញ្ញសហប្រជាជាតិ ឬ ស្ថិតក្នុងសន្ធិសញ្ញា ឬអនុសញ្ញាដែលផ្តល់ឱ្យតុលាការ ឬ ក៏ធ្វើការ

ប្រកាសចំពោះប្រសិទ្ធភាពរបស់តុលាការនោះ។ ការប្រកាសទទួលយកយុត្តាធិការរបស់ តុលាការអន្តរជាតិគឺមានតាមរបៀបដែលរដ្ឋចូលទទួលយកតាមអនុសញ្ញាអន្តរជាតិដែលបង្កើតឡើងដោយរដ្ឋ ទទួលស្គាល់ដោយរដ្ឋដែលមានវិវាទកម្ម តាមរយៈទំនៀមទម្លាប់អន្តរជាតិ ជាភស្តុតាងនៃការប្រតិបត្តិទូទៅមួយដែលទទួលស្គាល់ដោយច្បាប់តាមរយៈគោលការណ៍ទូទៅ នៃច្បាប់ដែលទទួលស្គាល់ដោយប្រទេសទាំងឡាយជាសមាជិកនៃអង្គការសហប្រជាជាតិ( United Nations ) ក៏ដូចជាតាមការសម្រេចចិត្តរបស់តុលាការ និងយុត្តិសាស្ត្រនានាហើយប្រសិនបើភាគីទាំងអស់យល់ព្រម តុលាការអាចសម្រេចចិត្តក្នុងករណីមួយ ដោយឈរលើមូលដ្ឋានសមភាព។

ឆ្លងតាមនិយមន័យ នេះពាក្យគន្លឹះខាងលើប្រធានបទរបស់យើងនឹងបកស្រាយរួចប្រៀបធៀបអំពីដែនអំណាចដែលផ្តល់ដោយច្បាប់ក្នុងការបើកសវនាការ និងសម្រេចកម្មវត្ថុនៃវិវាទរវាងភាគីម្ខាងដែលជារដ្ឋ ឬអង្គការអន្តរជាតិរបស់តុលាការយុត្តិធម៌អន្តរជាតិ និងតុលាការព្រហ្មទណ្ឌអន្តរជាតិ។

បន្ថែមពីលើការដឹងលឺជាធម្មតាថាសង្គមអន្តរជាតិយើងមានតុលាការជាច្រើនដូចជា តុលាការយុត្តិធម៌អន្តរជាតិ តុលាការអន្តរជាតិសម្រាប់ច្បាប់សមុទ្រ តុលាការរដ្ឋបាលអន្តរជាតិ តុលាការព្រហ្មទណ្ឌអន្តរជាតិ តុលាការកូនកាត់ជាដើម គេត្រូវដឹងថាតើប្រភេទនៃជម្លោះបែបណាដែលតុលាការអន្តរជាតិនោះមានសមត្ថកិច្ចដោះស្រាយ។ ផ្អែកតាមការស្រាវជ្រាវរបស់លោក មូសារ អ៊ីហ្សាម នៅខែតុលា ឆ្នាំ២០១៥ អំពីតួនាទីរបស់តុលាការយុត្តិធម៌អន្តរជាតិក្នុងការដោះស្រាយជម្លោះអន្តរជាតិ បានចំណាត់ប្រភេទតុលាការអន្តរជាតិដោយផ្អែកតាមយុត្តាធិការរបស់ ៥បែបៈ

- តុលាការអន្តរជាតិដែលមានអំណាចទូលំទូលាយ និងមានដែនយុត្តាធិការទូទាំង សាកលលោក ឬ ក្នុងតំបន់ដែលមានដូចជាតុលាការយុត្តិធម៌អន្តរជាតិ( ICJ )តុលាការយុត្តិធម៌អាមេរិកកណ្តាល ( Central American Court of Justice )ជាដើម
- តុលាការអន្តរជាតិដែលមានផ្នែកជំនាញ និងដែលយុត្តាធិការទូទាំងសកលលោករួមមាន តុលាការអន្តរជាតិស្តីពីច្បាប់សមុទ្រ( ITLOS ) តុលាការព្រហ្មទណ្ឌអន្តរជាតិ។ល។
- តុលាការអន្តរជាតិដែលមានផ្នែកជំនាញ និងដែនយុត្តាធិការមានកម្រិត រួមមានលើផ្នែកមនុស្សធម៌ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ឬរ៉ាន់ដា ឬសាលាក្តីព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀត (នៅកម្ពុជា សៀរ៉ាឡេអូន កូសូវ៉ូ ទីម័រខាងកើត) ហើយផ្នែករដ្ឋបាលអន្តរជាតិវិញមាន ដូចជាតុលាការរដ្ឋបាលរបស់ធនាគារពិភពលោករបស់អង្គការពលកម្មអន្តរជាតិ របស់អង្គការសហប្រជាជាតិ
- តុលាការដែលមានជំនាញ និងលក្ខណៈតំបន់លើផ្នែកសិទ្ធិមនុស្ស ដូចជាតុលាការសិទ្ធិមនុស្សរបស់អឺរ៉ុប តុលាការយុត្តិធម៌អឺរ៉ុប។

- និងជាចុងក្រោយគឺ មជ្ឈត្តកម្មដែលមានបីប្រភេទទៀតគឺ មជ្ឈត្តកម្មអន្តរជាតិទូទៅ តួយ៉ាងតុលាការអចិន្ត្រៃយ៍នៃមជ្ឈត្តកម្ម ឬមជ្ឈត្តកម្មចំពោះកិច្ច មជ្ឈត្តកម្មអន្តរជាតិផ្នែកជំនាញវិនិយោគទុន និងមជ្ឈត្តកម្មក្នុងតំបន់ជាអាទិ៍។

ឯកសារស្រាវជ្រាវសង្ខេបរបស់លោកម៉ូសាក៏បានបង្ហាញអំពីចរិតលក្ខណៈនៃយុត្តាធិការផងដែរគឺ យុត្តាធិការមានលក្ខណៈច្រើនយ៉ាងដូចជាយុត្តាធិការមានលក្ខណៈចាប់បង្ខំ គឺរដ្ឋដែលជា ភាគីក្នុងកិច្ចព្រមព្រៀងបញ្ជាក់ពីប្រព័ន្ធដោះស្រាយជម្លោះមួយ ដោយពួកគេគ្មានជម្រើស ហើយរឿងក្តីត្រូវបញ្ជូនជាស្វ័យប្រវត្តិទៅតុលាការដែលបានកំណត់ទុក។ យុត្តាធិការចាប់បង្ខំជាយុត្តាធិការដែលទទួលបានអំណាចដោះស្រាយជម្លោះតាមករណីនីមួយ(Case by case basis)។ ប៉ុន្តែ អ្វីដែលគួរឱ្យកត់សម្គាល់គឺតុលាការអាចប្រើប្រាស់យុត្តាធិការនេះមានកម្រិតដរាបរដ្ឋនោះចូលរួមក្នុងសន្ធិសញ្ញាដែលបង្កើតតុលាការ ហើយចូលក្នុងលក្ខណៈទីពីរទៀតគឺ រដ្ឋនីមួយៗនៅតែអាចធ្វើការសម្រេចចិត្តបានថាតើ ទទួលយកឬមិនទទួលយកយុត្តាធិការដែលមានលក្ខណៈចាប់បង្ខំនោះ ដូចជាតុលាការយុត្តិធម៌អន្តរជាតិ ឬ អាចធ្វើការជ្រើសរើសបាននឹងតុលាការនានាផ្សេងទៀត តែភាគច្រើនតុលាការថ្នាក់តំបន់ ហើយមានជំនាញតែងជាយុត្តាធិការដែលមានលក្ខណៈចាប់បង្ខំហើយគូវិវាទគ្មានជម្រើសទេ។

សម្រាប់យុត្តាធិការចាប់បង្ខំវាមានចរិតលក្ខណៈបន្សំរបស់វាមួយទៀតគឺវាជាយុត្តាធិការដែលទាល់មានការព្រមព្រៀងទទួលយក។ គេអាចនិយាយបានថា រដ្ឋមួយមិនអាចត្រូវបានគេប្តឹងទៅតុលាការឡើយ បើរដ្ឋនោះមិនព្រមទទួលយកយុត្តាធិការ ប៉ុន្តែនៅតែតុលាការអាចមានវិធីសាស្រ្តធ្វើឱ្យការចាប់បង្ខំដើម្បីឈ្លេចរកយុត្តិធម៌ឱ្យបាន។ វិធីសាស្រ្តទាំងនោះរួមមាន៖

- តាមរយៈកិច្ចព្រមព្រៀងចំពោះកិច្ច(Ad hoc)ដែលធ្វើឡើងដោយភាគីបន្ទាប់ពីវិវាទបានកើតឡើង។ តាមអត្ថបទសង្ខេប និង ការស្រាវជ្រាវរបស់លោកម៉ូសា វិធីសាស្រ្តនេះបានទទួលជោគជ័យ១៥ រឿងក្តីមកហើយដូចជាជម្លោះដែនដី លីប៊ី និង ឆាដជាដើម
- តាមរយៈការដាក់បញ្ចូលជំពូកស្តីពីមជ្ឈត្តកម្មទៅក្នុងសន្ធិសញ្ញា។ គេបានឃើញថ្មីៗនេះ មានអនុសញ្ញាពហុភាគីនានាមានកម្មវត្ថុទូលាយបានផ្តល់យុត្តាធិការដល់តុលាការយុត្តិធម៌អន្តរជាតិ
- តាមរយៈការចូលរួមក្នុងកិច្ចព្រមព្រៀងដោះស្រាយវិវាទ

- តាមរយៈសេចក្តីប្រកាសជាជម្រើសនៃការទទួលយកយុត្តាធិការដែលមានលក្ខណៈចាប់បង្ខំ គឺដោយយោងតាមមាត្រា៣៦(២)[1](៣) បញ្ជាក់អំពីប្រភេទនៃជម្លោះដែលត្រូវបញ្ជូនទៅតុលាការ ហើយមានសុពលភាពជាទូទៅ៥ទៅ១០ឆ្នាំ និង ទុកពេលវេលាជូនដំណឹងដើម្បីឱ្យរដ្ឋបញ្ជាក់ពីគម្រោងរបស់ខ្លួននៃការឈប់ទទួលស្គាល់យុត្តាធិការរបស់តុលាការ

**ចរិតលក្ខណៈទី២នៃយុត្តាធិការគឺ មានគូវិវាទតែមួយឬច្រើនតួយ៉ាង៖**

- មាត្រា៣៤នៃលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ បានបញ្ជាក់យ៉ាងច្បាស់ថាមានតែរដ្ឋប៉ុណ្ណោះដែលអាចជាភាគីនៅចំពោះមុខតុលាការ។ ចំណែកតុលាការព្រហ្មទណ្ឌអន្តរជាតិក៏ដូចគ្នា ភាគីគូវិវាទគឺជាបុគ្គលមិនមែនរដ្ឋវិញ។
- យុត្តាធិការខ្លះមានគូវិវាទច្រើន គឺទាំងរូបវន្តបុគ្គល នីតិបុគ្គលផងដែរ គឺដូចជា តុលាការច្បាប់សមុទ្រ ក្រៅពីនេះ យុត្តាធិការតាមសាស្ត្រាចារ្យច្បាប់អន្តរជាតិ Cedric នៃសកលវិទ្យាល័យ Utrecht បានរកឃើញថាមានបួនប្រភេទទៀតគឺ៖
- យុត្តាធិការដែលបានកំណត់(Prescriptive Jurisdiction)រដ្ឋនានាត្រូវបានគេទទួលស្គាល់ថាមានយុត្តាធិការបែបបញ្ញានេះដោយផ្អែកលើកត្តាមួយក្នុងចំណោមពីរប្រភេទគឺ កត្តាដែនដីដែលឆ្លុះបញ្ចាំងពីទំនាក់ទំនងជិតស្និទ្ធរវាងការគ្រប់គ្រងទឹកដីនិងភាពជារដ្ឋនៅក្នុងច្បាប់អន្តរជាតិ និងកត្តាទីពីរ គឺកត្តាសញ្ជាតិដែលឆ្លុះបញ្ចាំងពីគំនិតនៃប្រធានបទបុគ្គលចំពោះអំណាចអធិបតេយ្យ។
- យុត្តាធិការដោយបង្ខំ (Enforcement Jurisdiction)៖ យុត្តាធិការនេះសំដៅទៅលើយុត្តាធិការរបស់រដ្ឋដើម្បីពង្រឹងឬបង្ខំឱ្យមានការអនុលោម ឬ ដាក់ទណ្ឌកម្មការមិនគោរពតាមច្បាប់ឬបទបញ្ញត្តិរបស់ខ្លួនមិនថាតាមរយៈតុលាការឬដោយការប្រើប្រាស់នីតិប្រតិបត្តិរដ្ឋបាលប៉ូលីស ឬ សកម្មភាពក្រៅច្បាប់ផ្សេងទៀត។ យុត្តាធិការនៃការអនុវត្តច្បាប់គឺ តឹងរឹងជាងវិធាននៃយុត្តាធិការដែលបានកំណត់។ រដ្ឋនានាមិនមានសិទ្ធិអនុវត្តច្បាប់របស់ពួកគេនៅខាងក្រៅទឹកដីរបស់ពួកគេឡើយ លើកលែងតែគុណធម៌នៃច្បាប់

[1] មាត្រា៣៦ កថាខណ្ឌទី២ចែងថា: រដ្ឋភាគីនៃលក្ខន្តិកៈបច្ចុប្បន្នអាចនៅពេលណាមួយប្រកាសថាពួកគេទទួលស្គាល់យុត្តាធិការដាច់ខាតតុលាការ និងដោយគ្មានកិច្ចព្រមព្រៀងពិសេសនៅក្នុងទាក់ទងទៅនឹងរដ្ឋផ្សេងទៀតដែលទទួលយកការត្រួតគ្នាដូចគ្នាយុត្តាធិការរបស់តុលាការតាមច្បាប់ទាំងអស់និងជម្លោះទាក់ទងនឹង៖
ក. ការបកស្រាយសន្ធិសញ្ញាមួយ;
ខ. សំណួរណាមួយនៃច្បាប់អន្តរជាតិ;
គ. អត្ថិភាពនៃការពិតណាមួយដែលត្រូវបានបង្កើតឡើងអាចជាការរំលោភលើកាតព្វកិច្ចអន្តរជាតិ
ឃ. ធម្មជាតិឬវិសាលភាពនៃសំណងចំពោះការរំលោភលើបណ្តឹងឧទ្ធរណ៍អន្តរជាតិ
ចំណែកកថាខណ្ឌទី៣ប្បញ្ញត្តិថា សេចក្តីប្រកាសសំដៅលើខាងលើអាចជាត្រូវបានធ្វើឡើងដោយគ្មានលក្ខខណ្ឌឬតាមលក្ខខណ្ឌនៃភាពមានបានកំណត់ដោយផ្អែកនៃរដ្ឋមួយចំនួនឬជាក់លាក់ឬសម្រាប់ពេលជាក់លាក់មួយ។

អនុញ្ញាតិដែលទទួលបានពីទំនៀមទម្លាប់អន្តរជាតិ ឬពីអនុសញ្ញាមាននោះទេ។ ដូច្នោះហើយអនុវត្តន៍អាចកើតឡើងបានតែតាមរយៈវិធានការណ៍ទឹកដីពោលគឺ ការចាប់ខ្លួនមនុស្សដែលមានវត្តមាននៅលើទឹកដីដោយស្ម័គ្រចិត្តឬដោយការរឹបអូសទ្រព្យសម្បត្តិរបស់ជនជាប់ចោទដែលមានទីតាំងនៅលើទឹកដី។

ជាញឹកញាប់កិច្ចសហប្រតិបត្តិការអន្តរជាតិនឹងតម្រូវឱ្យមានវត្តមានជនល្មើសដែល បានសន្មតដោយមធ្យោបាយធ្វើបត្យាប័ន ឬ មានដីកាតុលាការក្នុងស្រុកដែលបានអនុវត្តប្រឆាំងនឹងទ្រព្យសម្បត្តិដែលមាននៅបរទេស។

- យុត្តាធិការបែបវិនិច្ឆ័យ( Adjudicatory Jurisdiction )៖យុត្តាធិការដែលអនុវត្តដោយប្រព័ន្ធតុលាការជាធម្មតាត្រូវបានកំណត់ដោយលក្ខខណ្ឌវិនិច្ឆ័យរបស់តុលាការមានសិទ្ធិអំណាចលើសពីរដ្ឋ។ យុត្តាធិការប្រភេទនេះច្រើនមានក្នុងរឿងក្តីពាណិជ្ជកម្មដោយមិនខ្វល់ពីរដ្ឋសំណួរជារដ្ឋណានោះទេ។
- និង យុត្តាធិការមុខងារ ( functional Jurisdiction ) ជាយុត្តាធិការដែលភាគច្រើនត្រូវបានប្រើនៅ ក្នុងច្បាប់សមុទ្រដែលជាខ្លឹមសារវាសំដៅទៅលើយុត្តាធិការមានកំណត់របស់រដ្ឋនៅលើឆ្នេរសមុទ្រលើសកម្មភាពនៅក្នុងតំបន់សមុទ្ររបស់ពួកគេ និង សម្រាប់ដែនកំណត់មួយសម្រាប់យុត្តាធិការរបស់រដ្ឋណាមួយលើសកម្មភាពជាក់លាក់នៅលើសមុទ្រខ្ពស់ដូចជាការលួចចម្លងនិងការធ្វើពាណិជ្ជកម្មមានទាសភាព។

ទាំងប្រភេទតុលាការអន្តរជាតិផ្អែកតាមយុត្តាធិការ ទាំងចរិតលក្ខណៈយុត្តាធិការតុលាការអន្តរជាតិ និងប្រភេទយុត្តាធិការក្នុងច្បាប់អន្តរជាតិត្រូវបានយកបកស្រាយខាងលើក្តីក៏ លក្ខណៈប៉ុណ្ណេះមិនគ្រប់គ្រាន់ទេ ម្ល៉េះហើយបានជាយើងចាំបាច់ធ្វើការឆ្លុះបញ្ចាំងឱ្យបានច្បាស់លាស់នូវបញ្ហាគតិយុត្តិចម្បង ថាតើតុលាការយុត្តិធម៌អន្តរជាតិ និងតុលាការព្រហ្មទណ្ឌអន្តរជាតិមានយុត្តាធិការដូចម្តេចខ្លះ? ដើម្បីឈានទៅរកការប្រៀបធៀបលក្ខណៈដូចគ្នា និងខុសគ្នាស្រឡះណាមួយ។

ដើម្បីអាចឱ្យយើងបកស្រាយលក្ខណៈសម្បត្តិយុត្តាធិការដ៏ល្អឯករបស់តុលាការទាំងពីរនេះ បានយើងបានធ្វើការស្រាវជ្រាវលើទិន្នន័យពីរយ៉ាង។ ទិន្នន័យចម្បងគឺ យើងផ្អែកលើច្បាប់អន្តរជាតិដែលមានដូចជាធម្មនុញ្ញអង្គការសហប្រជាតិ លក្ខន្តិកៈនៃតុលាការយុត្តិធម៌អន្តរជាតិ លក្ខន្តិកៈក្រុងស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ សាលក្រមរបស់តុលាការទាំងពីរ និងលិខិតបទដ្ឋានគតិយុត្តិដទៃទៀត។ ទិន្នន័យបន្ទាប់បន្សំដែលយើងចងក្រង មកប្រមូលមាន សៀវភៅអន្តរជាតិនានា ទស្សនាវដ្តីអេឡិចត្រូនិក ឯកសារស្រាវជ្រាវសង្ខេបខេមរភាសា សារព័ត៌មាន និង គេហទំព័រមួយចំនួនទើបអាចសម្រេចឱ្យយើង រៀបចំសារណានេះបាន ជា២ជំពូកធំៗដែលៈ

**ជំពូកទី១៖** ការបកស្រាយអំពីយុត្តាធិការតុលាការយុត្តិធម៌អន្តរជាតិ និងយុត្តាធិការតុលាការព្រហ្មទណ្ឌអន្តរជាតិ សំដៅលើការបង្ហាញពីប្រភេទយុត្តាធិការនៃតុលាការនីមួយៗ និង ការទទួលយក ឬ សំណើសុំយុត្តាធិការរបស់តុលាការទាំងនោះពីរដ្ឋ ឬ អង្គការអន្តរជាតិដោយរបៀបណា។

**ជំពូកទី២៖** ការប្រៀបធៀបយុត្តាធិការតុលាការយុត្តិធម៌អន្តរជាតិ និងយុត្តាធិការតុលាការព្រហ្មទណ្ឌអន្តរជាតិជាការបន្សំទ្រឹស្តី និង ការអនុវត្តយុត្តាធិការនៃតុលាការទាំងពីរដើម្បីវែកញែកឱ្យបានច្បាស់លាស់ពីលក្ខណៈដូចនិងខុសគ្នារបស់តុលាការទាំងពីរនេះរួមជាមួយនឹងការផ្តល់ជូនពិសេសនូវករណីសិក្សាដ៏ល្បីរបស់ព្រះរាជាណាចក្រកម្ពុជា និង ប្រទេសស៊ូដង់ខាងត្បូងជាឧទាហរណ៍។

# ជំពូកទី១៖ យុត្តាធិការតុលាការយុត្តិធម៌អន្តរជាតិ និង យុត្តាធិការតុលាការព្រហ្មទណ្ឌអន្តរជាតិ

## ផ្នែកទី១៖ យុត្តាធិការរបស់តុលាការយុត្តធម៌អន្តរជាត

មុននឹងឈានមានតុលាការអចិន្ត្រៃយ៍នៃយុត្តិធម៌អន្តរជាតិ (PCIJ) គឺវាល់វិវាទរវាងរដ្ឋត្រូវបានដោះស្រាយតាមកិច្ចព្រមព្រៀងចំពោះកិច្ច (Adhoc)[2] ។ លុះត្រាមានការបើកសន្និសីទសន្ធានកម្មក្រុងឡាអេរួច ទើបមានការបង្កើតតុលាការអចិន្ត្រៃយ៍នៃមជ្ឈត្តិកម្ម(PCIA)នៅឆ្នាំ១៨៩៩ដើម្បីជា វេទិកាដោះស្រាយជម្លោះរដ្ឋក្រៅតុលាការក្រោមការចេញសេចក្ដីសម្រេចចងឬពុំចងកាតព្វកិច្ចពីសំណាក់មជ្ឈត្តិករឯករាជ្យ។

យ៉ាងណាមិញតុលាការមជ្ឈិត្តការអន្តរជាតិនេះ ពុំមានយុត្តាធិការរឹងមាំដើម្បីអនុវត្តសេចក្ដីសម្រេចរបស់ខ្លួននោះទេដោយមិនបានចាំបង្ខំឬដាក់ទណ្ឌកម្មភាគីចាញ់ក្ដីធ្ងន់ធ្ងរនោះទេគឺ គ្រាន់តែជាសេចក្ដីសម្រេចចង្អុលបង្ហាញថា ភាគីដើមបណ្ដឹងមានបុព្វសិទ្ធិទៅចូលក្នុងទីតាំងវិវាទដែលចុងចម្លើយរំលោភយក។ ជាច្រើនទសវត្សមកទៀត វិវាទក៏ចេះតែផ្ទុះឡើងបណ្ដារដ្ឋមួយទៅរដ្ឋមួយ តួយ៉ាងវិវាទរំលោភព្រំដែន ជម្លោះនៃការរំលោភបំពានអធិបតេយ្យជាដើម។ លុះយូរៗទៅពិភពលោកក៏ធ្លាក់ចូលក្នុងសង្គ្រាមលោកលើកទី២ ដែលបញ្ជាក់បានថា មានប្រទេសធំៗរំលោភប្រទេសទន់ខ្សោយ។ រឿងរ៉ាវហូតដល់ប៉ះទង្គិចគ្នាប្រើប្រាស់កងទ័ពទៀតផងហើយក៏ឈានដល់ជម្រុញឱ្យមានការបង្កើតអង្គការសហប្រជាជាតិតាមរយៈធម្មនុញ្ញអង្គការសហប្រជាជាតិ។

សង់ហ្វ្រង់ស៊ីនស្កូ (San Francisco Conference) បានក្លាយជាសន្និសីទនៃការផ្ដួចផ្ដើមឱ្យមានអង្គការអន្តររដ្ឋាភិបាលដែលមានចរិតលក្ខណៈសកលគឺអង្គការសហប្រជាជាតិនេះ។ ប្រទេសនានាបានមកចូលរួមប្រជុំចាប់ពីខែមេសានៅឆ្នាំ១៩៤៥។ ការប្រជុំពោរពេញដោយការខ្វែងគំនិតគ្នាក្នុងការរក្សាទុក PCIJ ឬដូចម្ដេច ត្បិតតម្រូវឱ្យរំលាយសម្ព័ន្ធប្រជាជាតិ (League of Nations )ដែលជាអង្គការមានសមាជិកមិនគ្រប់ចំនួនដោយសារប្រទេសនានាដកខ្លួនចេញជាបន្តបន្ទាប់ និងដោយសារតែកម្សោយរចនាសម្ព័ន្ធរបស់អង្គការនេះ។ បើសម្ព័ន្ធប្រជាជាតិគ្មានចំនួនគ្រប់គ្រាន់តើគេអាចបើកមហាសន្និបាតរបៀបណាដើម្បីបោះឆ្នោតជ្រើសរើសចៅក្រមថ្មី។ បែបនេះហើយនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៤៦ គេសម្រេចរំលាយអង្គការសហប្រជាជាតិហើយអំណាច និងមុខងាររបស់អង្គការនេះត្រូវបានផ្ទេរទៅឱ្យអង្គការសហប្រជាជាតិដែលត្រូវបានបង្កើតឡើងតាម ការអនុម័តធម្មនុញ្ញអង្គការ

[2]អាដហុកគឺជាវិធីសាស្ត្របន្ទាន់ឬបណ្ដោះអាសន្នដើម្បីដោះស្រាយបញ្ហាជាក់លាក់មួយhttps://legaldictionary.thefreedictionary.com/ad+hoc

សហប្រជាជាតិនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៤៥ ដោយសមាជិកស្ថាបនិក ចំនួន៥១ប្រទេស និងចូលជាធរមាននៅថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៤៥ ដដែលនោះ។

ក្នុងសន្និសីទនោះមានការជម្រុញថាដើម្បីតម្កល់អភ័យឯកសិទ្ធរបស់តុលាការគឺ ចាំបាច់ទុកតុលាការថ្មីជាអង្គការគោលរបស់អង្គការសហប្រជាជាតិ។ ពោលជាលទ្ធផល តុលាការយុត្តិធម៌អន្តរជាតិគឺ ជាតុលាការថ្មីមួយដែលចូលខ្លួនមកជំនួសតុលាការអចិន្ត្រៃយ៍នៃយុត្តិធម៌អន្តរជាតិរបស់សម្ព័ន្ធប្រជាជាតិ ហើយមិនមានផ្លាស់ប្តូររចនាសម្ព័ន្ធច្រើនទេដោយវានៅតែមានមូលដ្ឋានរបស់លក្ខន្តិកៈតុលាការចាស់ស្រាប់ទៅហើយ។ តុលាការមួយនេះគឺ នៅតែជាតុលាការដែលបង្កើតឡើងសម្រាប់ដោះស្រាយជម្លោះអន្តរជាតិ អភិវឌ្ឍច្បាប់អន្តរជាតិតាមរយៈការវិនិច្ឆ័យ និងមតិយោបល់ ព្រមទាំងជួយអភិវឌ្ឍស្ថាប័នអន្តរជាតិដោយការផ្តល់មតិពិភាក្សាលើបញ្ហាច្បាប់នៅពេលអនុវត្តតាមតួនាទីរបស់ស្ថាប័ន។

មាត្រា១ នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិបានបញ្ជាក់ថា តុលាការនេះត្រូវបានបង្កើតឡើងដោយធម្មនុញ្ញអង្គការសហប្រជាជាតិដើម្បីជា អង្គការយុត្តិធម៌ចម្បងនៃអង្គការសហប្រជាជាតិដែលត្រូវមានធម្មនុញ្ញភាព និងតួនាទីស្របតាមបញ្ញត្តិដែលមានចែងក្នុងលក្ខន្តិកៈនោះ។ ខណៈមាត្រា៧(១) របស់ធម្មនុញ្ញអង្គការសហប្រជាជាតិបានរៀបរាប់ថា តុលាការនេះជាអង្គការគោលទាំង៦របស់អង្គការសហប្រជាជាតិ ជាមួយនឹងមហាសន្និបាត ក្រុមប្រឹក្សាសន្តិសុខ ក្រុមប្រឹក្សាសង្គមនិងសេដ្ឋកិច្ច ក្រុមប្រឹក្សាអាណាព្យាបាល លេខាធិការដ្ឋានរបស់អង្គការសហប្រជាជាតិ។

ក្នុងមាត្រា៩២ របស់ធម្មនុញ្ញUNគឺបានបញ្ជាក់ច្បាស់ៗថា តុលាការនេះដើរតួនាទីស្របតាមលក្ខន្តិកៈ និងផ្អែកតាមលក្ខន្តិកៈតុលាការអចិន្ត្រៃយ៍នៃយុត្តិធម៌អន្តរជាតិ និង តម្រង់រួមបញ្ចូលគ្នានៃធម្មនុញ្ញបច្ចុប្បន្ន។

តាមមាត្រា៩៣ នៃធម្មនុញ្ញអង្គការសហប្រជាជាតិបានចង្អុលថា សមាជិករដ្ឋអង្គការសហប្រជាជាតិគឺជា ភាគីជាក់ស្តែងដែលមិនអាចគេចរួច(Ipso Facto) របស់លក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ។ ដោយឡែកមាត្រា៣៨នៃធម្មនុញ្ញដដែលនោះកត់សម្គាល់ថា តួនាទីរបស់តុលាការមួយនេះគឺ អំពីការសម្រេចស្របទៅតាមច្បាប់ អន្តរជាតិនូវរាល់ជម្លោះដែលត្រូវបានដាក់មកជូនតុលាការ។

ក្នុងឋានៈជា អង្គការមួយរបស់អង្គការសហប្រជាជាតិ យុត្តាធិការរបស់តុលាការមួយនេះត្រូវបានចោទជាសំណួរថាត្រូវបានកំណត់ដោយធម្មនុញ្ញអង្គការសហប្រជាជាតិឬទេ។ ដោយពិនិត្យមើលលើមាត្រា២របស់ធម្មនុញ្ញអង្គការសហប្រជាជាតិចែងអំពីការមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃយុត្តាធិការរបស់រដ្ឋមួយ។ តាមមាត្រា២នោះគឺ ICJ មិនបានធ្វើការប្រកាសណាមួយអំពីសុពលភាពនៃការជំទាស់នេះទេព្រោះតុលាការនេះបានតម្កល់ការជំទាស់ថាខ្លួនមិនមានយុត្តាធិការដោយផ្អែកលើមូលដ្ឋាននៃការរក្សាទុកជាមុន។ ពេលនោះអ្នកច្បាប់អន្តរ

ជាតិក៏ចាប់ផ្តើមដេញដោលគ្នា អំពីការដែលធម្មនុញ្ញតម្រូវឱ្យមានការទទួលយកលក្ខន្តិកៈរបស់តុលាការដោយស្ម័យប្រវត្តិដែលមិនរារាំងធម្មនុញ្ញនិងលក្ខន្តិកៈពីការបង្កើតឧបករណ៍ដែលមានលក្ខណៈដាច់ ដោយឡែកពីគ្នាឡើយ។ លើសពីនេះអ្នកដែលគាំទ្រទស្សនៈប្រឆាំងយុត្តាធិការរបស់តុលាការគឺយល់ឃើញថាយុត្តាធិការត្រូវបានមកពីការយល់ព្រមពីរដ្ឋហើយធម្មនុញ្ញនិងលក្ខន្តិកៈមិនផ្តល់អំណាចវិនិច្ឆ័យបែបនេះដល់ ICJ ទេពោលគឺ មិនមានបទប្បញ្ញត្តិណាមួយនៅក្នុងធម្មនុញ្ញដែលកំណត់ដោយផ្ទាល់នូវយុត្តាធិការរបស់តុលាការឡើយ។

បើតាមសេចក្តីវិនិច្ឆ័យរបស់ ICJ ក្នុងឧបទ្ទវហេតុអាកាសចរណ៍ថ្ងៃទី ២៧ ខែកក្កដាឆ្នាំ ១៩៥៥ រវាងអ៊ីស្រាអែលនិងប៊ុលហ្គារី បានគូសបញ្ជាក់ថា មាត្រា៣៦ ផ្ទុយពីបំណងរបស់គណៈប្រតិភូមួយចំនួននៅសាន់ហ្វ្រាន់ស៊ីស្កូហើយថាយុត្តាធិការបាននាំមកនូវផលវិបាកភ្លាមៗ និងដោយផ្ទាល់នៃការធ្វើជាភាគីនៃលក្ខន្តិក។ ដូចនេះ ក្រុមអ្នកគស្ស៊ូមតិនៃទស្សនៈនេះសន្និដ្ឋានថា ដែនកំណត់ណាមួយនៃដែនសមត្ថកិច្ចក្នុងប្រទេសរបស់រដ្ឋគួរតែបានមកពីការប្រកាសរបស់រដ្ឋដែលពួកគេទទួលយកយុត្តាធិការកាតព្វកិច្ចរបស់តុលាការយុត្តិធម៌អន្តរជាតិ និងមិនមែនពីធម្មនុញ្ញអង្គការសហប្រជាជាតិឡើយ។ ដោយគ្មានការចែង ឬ បញ្ជាក់ច្បាស់លាស់អំពីរឿងនេះ រង្វង់អ្នកច្បាប់មួយចំនួនក៏នៅតែប្រឆាំងថា រដ្ឋដែលជា ភាគីលក្ខន្តិកៈតុលាការមានលេសបដិសេធលើបញ្ហាមួយចំនួនដែលប៉ះពាល់ផលប្រយោជន៍របស់ពួកគេដែលនាំឱ្យជជែកថាតើចងក្រងច្បាប់អន្តរជាតិមកធ្វើអ្វី។ ដូច្នោះហើយបញ្ហាណាមួយដែលត្រូវបានចាត់ទុកថាជាច្បាប់អន្តរជាតិជាកិច្ចការក្នុងប្រទេសគួរតែត្រូវបានកំណត់ដោយតុលាការថាស្ថិតនៅក្នុងយុត្តាធិការក្នុងរដ្ឋដែលពាក់ព័ន្ធ លុះត្រាតែមានកិច្ចព្រមព្រៀងផ្ទុយ។ សរុបសេចក្តីទៅយុត្តាធិការក្នុងស្រុកត្រូវបានគេចាត់ទុកថាជា គោលការណ៍មួយនៃគោលការណ៍អង្គការសហប្រជាជាតិខ្លួនឯងដែលរឹតត្បិតសមត្ថភាព និងសិទ្ធិអំណាចរបស់អង្គការសហប្រជាជាតិទាំងអស់រួមទាំងICJ ដែលមិនអាចលើសពីដែនកំណត់ដែលបានកំណត់ដោយអង្គការសហប្រជាជាតិបាន។ ជាលទ្ធផលយុត្តាធិការរបស់តុលាការគឺផ្តល់ប្រឹក្សានិងលើជម្លោះរបស់រដ្ឋដែលដាក់ជូន។ រដ្ឋមិនត្រូវបានទាមទារឱ្យរាប់បញ្ចូលការកំណត់ដាក់លាក់នៃដែនសមត្ថកិច្ចក្នុងប្រទេសមកទទួលយកយុត្តាធិការ ជាកាតព្វកិច្ចរបស់តុលាការឡើយបើទោះបីជារដ្ឋសមាជិករបស់លក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិក៏ដោយក្តី។

### កថាខណ្ឌទី១៖ យុត្តាធិការលើជម្លោះអន្តរជាត (Contentious Jurisdictions)

នៅក្នុងការអនុវត្តយុត្តាធិការរបស់ខ្លួននៅក្នុងសំណុំរឿងដែលមានជម្លោះរវាងរដ្ឋគឺ តុលាការយុត្តិធម៌អន្តរជាតិដោះស្រាយវិវាទដែលមានលក្ខណៈស្របច្បាប់តាមដែលរដ្ឋបានដាក់ជូនទៅ តុលាការដោយអនុលោមតាមច្បាប់អន្តរជាតិ។ ជម្លោះផ្នែកច្បាប់អន្តរជាតិអាចត្រូវបានកំណត់ថាជាការខ្វែងគំនិតគ្នាលើសំណួរអំពីច្បាប់ ឬ ការពិតជម្លោះឬការប៉ះទង្គិចនៃទស្សនៈឬផលប្រយោជន៍ផ្នែកច្បាប់។

មានតែរដ្ឋទេដែលអាចដាក់ពាក្យ និងបង្ហាញខ្លួននៅចំពោះមុខតុលាការយុត្តិធម៌អន្តរជាតិ។ អង្គការអន្តរជាតិ អាជ្ញាធរ និងបុគ្គលឯកជនផ្សេងទៀតមិនមានសិទ្ធិបង្កើតដំណើរការនីតិវិធីនៅចំពោះមុខតុលាការឡើយ។

មាត្រា ៣៥នៃលក្ខន្តិកៈតុលាការអន្តរជាតិគឺ កំណត់លក្ខខណ្ឌដែលរដ្ឋអាចចូលដំណើរការរឿងក្តីជាមួយតុលាការបាន។ មាត្រា៣៥(១) ចែងថាតុលាការបើកចំហចំពោះរដ្ឋភាគីចំពោះលក្ខន្តិកៈបច្ចុប្បន្ន។ មាត្រា៣៥(២) បញ្ជាក់ថាទោះរដ្ឋដែលមិនមែន ជាភាគីនៃលក្ខន្តិកៈក៏ដោយតែមានបំណងចូលមកកាន់តុលាការក៏តុលាការបើកឱកាសឱ្យដែរ ប៉ុន្តែត្រូវមានលក្ខខណ្ឌដែលលក្ខខណ្ឌនោះ មាននៅក្នុងប្បញ្ញត្តិពិសេសដែលមានក្នុងសន្ធិសញ្ញាជា ធរមានហើយយកទៅតម្កល់នៅអគ្គលេខាធិការដ្ឋាន។ បន្ថែមពីនេះ តាមមាត្រា៩៣(១)និង(២) នៃធម្មនុញ្ញអង្គការសហប្រជាជាតិ សមាជិកទាំងអស់នៃអង្គការសហប្រជាជាតិគឺជា ភាគីស្វ័យប្រវត្តិចំពោះលក្ខន្តិកៈរបស់តុលាការហើយរដ្ឋដែលមិនមែនជាសមាជិករបស់អង្គការសហប្រជាជាតិអាចក្លាយជា ភាគីនៃលក្ខន្តិកៈរបស់តុលាការ។

លក្ខខ័ណ្ឌដែលរដ្ឋទាំងនោះអាចចូលទៅតុលាការត្រូវបានកំណត់ដោយក្រុមប្រឹក្សាសន្តិសុខ។ ពោលក្រុមប្រឹក្សាសន្តិសុខបានកំណត់លក្ខខណ្ឌដែលតុលាការត្រូវបើកចំហចំពោះរដ្ឋដែលមិនមែនជា ភាគីនៃលក្ខន្តិកៈរបស់តុលាការក្នុងសេចក្តីសម្រេចលេខ៩ ចុះថ្ងៃទី ១៥ ខែតុលាឆ្នាំ ១៩៤៦ ដែលមាន៥ប្រការដូចជា៖

១. តុលាការយុត្តិធម៌អន្តរជាតិ ត្រូវបើកចំហចំពោះរដ្ឋមួយដែលមិនមែនជាភាគីនៃលក្ខន្តិកៈនៃតុលាការយុត្តិធម៌អន្តរជាតិតាមល័ក្ខខ័ណ្ឌដូចតទៅនេះគឺ ថារដ្ឋបែបនេះពីមុនត្រូវបានដាក់ជូនទៅអត្រានុកូលដ្ឋានតុលាការនូវសេចក្តីប្រកាសមួយ ដែលតុលាការនេះទទួលយកយុត្តាធិការរបស់តុលាការដោយអនុលោមតាមធម្មនុញ្ញអង្គការសហប្រជាជាតិ និងតាមល័ក្ខខ័ណ្ឌនៃលក្ខន្តិកៈនិងវិធានរបស់តុលាការ និងប្តេជ្ញាអនុវត្តដោយសុចរិតដោយសេចក្តីសម្រេចឬសេចក្តីសំរេចរបស់តុលាការ និងទទួលយកកាតព្វកិច្ចទាំងអស់របស់សមាជិកអង្គការសហប្រជាជាតិតាមមាត្រា៩៤ នៃធម្មនុញ្ញ។

២. សេចក្តីប្រកាសបែបនេះអាចជា លក្ខណៈពិសេសឬទូទៅ។ សេចក្តីប្រកាសជាក់លាក់មួយ គឺជាការទទួលយកយុត្តាធិការរបស់តុលាការដោយផ្អែកលើតែវិវាទ ឬ វិវាទជាក់លាក់ណាមួយដែលបានកើតឡើងរួចហើយ។ សេចក្តីប្រកាសទូទៅគឺជា ការទទួលយកយុត្តាធិការជាទូទៅទាក់ទងនឹងវិវាទទាំងអស់ ដែលបានកើតឡើងរួចហើយ ឬ ដែលអាចកើតឡើងនាពេលអនាគត។ រដ្ឋមួយធ្វើសេចក្តីប្រកាសទូទៅបែបនេះអាចស្របតាមមាត្រា៣៦ (២)នៃលក្ខន្តិកៈដែលទទួលស្គាល់ថាជាកាតព្វកិច្ចIpso Facto និងដោយមិនចាំបាច់មានកិច្ចព្រមព្រៀងពិសេសកំណត់យុត្តាធិការរបស់តុលាការទេ។ ការទទួលយកបែបនេះមិនចាំបាច់ត្រូវពឹង

ផ្អែកលើរដ្ឋភាគីដើម្បីធ្វើសេចក្តីប្រកាសស្របតាមមាត្រា៣៦(២) នៃលក្ខន្តិកៈនៃតុលាការយុត្តិធម៌អន្តរជាតិនោះដែរទេ។

៣. សេចក្តីប្រកាសដើមដែល ធ្វើឡើងក្រោមល័ក្ខខ័ណ្ឌនៃ ដំណោះស្រាយនេះត្រូវរក្សាទុកនៅអគ្រានុកូលដ្ឋានតុលាការស្របតាមការអនុវត្តរបស់តុលាការ។ ច្បាប់ចតចម្លងពិតដែលបានបញ្ជាក់នឹងត្រូវបញ្ជូនស្របតាមការអនុវត្តរបស់តុលាការទៅគ្រប់រដ្ឋភាគីនៃលក្ខន្តិកៈនៃតុលាការយុត្តិធម៌អន្តរជាតិនិងទៅរដ្ឋផ្សេងទៀតដែលបានដាក់សេចក្តីប្រកាសមួយតាមលក្ខខណ្ឌនៃដំណោះស្រាយនេះ និងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ។

៤. ក្រុមប្រឹក្សាសន្តិសុខរក្សាសិទ្ធិលុបចោល ឬ កែប្រែសេចក្តីសម្រេចនេះដោយដំណោះស្រាយដែលត្រូវទាក់ទងទៅតុលាការហើយនៅពេលទទួលបានការទំនាក់ទំនងបែបនេះ និងក្នុងកម្រិតដែលកំណត់ដោយដំណោះស្រាយថ្មីសេចក្តីប្រកាសដែលមានស្រាប់នឹងឈប់មានប្រសិទ្ធភាពលើកលែងតែទាក់ទងនឹងវិវាទដែលមាននៅចំពោះមុខតុលាការរួចហើយ។

៥. រាល់សំនួរទាក់ទងនឹងសុពលភាព ឬ ឥទ្ធិពលនៃសេចក្តីប្រកាសដែលធ្វើឡើងក្រោមល័ក្ខខ័ណ្ឌនៃដំណោះស្រាយនេះត្រូវសំរេចដោយតុលាការ។

បើតាមការទទួលយកយុត្តាធិការជាធរមានវិញគឺ ដោយផ្អែកលើបទប្បញ្ញត្តិពិសេសដែលមានចែងនៅក្នុងសន្ធិសញ្ញាជាធរមាននៅថ្ងៃដែលចូលជាធរមាននៃលក្ខន្តិកៈដោយមានចែងថាមិនស្ថិតក្នុងកាលៈទេសៈណាក៏ដោយ ភាគីក្នុងស្ថានភាពមិនស្មើភាពគ្នានៅចំពោះមុខតុលាការអាចដោះស្រាយបានលុះត្រាតែរដ្ឋដែលពាក់ព័ន្ធនោះគឺ បានទទួលស្គាល់យុត្តាធិការរបស់ខ្លួន។ ដូច្នេះគ្មានរដ្ឋណាមួយអាចជាភាគីក្នុងដំណើរការនីតិវិធីនៅចំពោះមុខតុលាការបានឡើយលុះត្រាតែមានលក្ខណៈណាមួយជាមុន ឬ ការយល់ព្រមផ្សេងទៀត។ ជារួមទៅមធ្យោបាយនៃការចូលទៅកាន់តុលាការដើម្បីដោះស្រាយជម្លោះរវាងរដ្ឋគឺ លុះត្រាតែតុលាការពិនិត្យថាខ្លួនមានយុត្តាធិការលើរដ្ឋនោះឬអត់ដរាបណារដ្ឋនោះធ្វើសេចក្តីប្រកាសឯកតោភាគី ឬ តាមរយៈកិច្ចព្រមព្រៀងពិសេស ឬ បន្ទាប់ពីតុលាការជំនុំជម្រះមុនអង្គសេចក្តីបង្ខំឱ្យទទួលយកយុត្តាធិការ។

## ១.ការទទួលយកយុត្តាធិការICJដោយឯកតោភាគី

### ១.១ បទប្បញ្ញត្តទូទៅ

យោងតាមមាត្រា៣៦(២) នៃលក្ខន្តិកៈតុលាការរដ្ឋអាចប្រកាសពេលណាក៏បានដែរ ក្នុងការទទួលស្គាល់យុត្តាធិការដាច់ខាត និងដោយគ្មានការព្រមព្រៀងពិសេសស្ថិតក្នុងទំនាក់ទំនងនឹងរដ្ឋណាមួយដែលបានទទួលស្គាល់កាតព្វកិច្ចដូចគ្នានោះ។ យុត្តាធិការរបស់តុលាការគឺ ទៅលើការបកស្រាយសន្ធិសញ្ញា ចំណោទ

ច្បាប់អន្តរជាតិ ការរំលោភបំពានកាតព្វកិច្ចអន្តរជាតិ និងលក្ខណៈ ឬ វិសាលភាពនៃសំណងដែលត្រូវធ្វើឡើងចំពោះការរំលោភលើកាតព្វកិច្ចអន្តរជាតិហើយរាល់សេចក្ដីប្រកាសដែលទទួលស្គាល់ថាជា យុត្តាធិការរបស់តុលាការគឺជា ទម្រង់នៃសកម្មភាពឯកតោភាគីរបស់រដ្ឋដែលពាក់ព័ន្ធ។ យោងតាមមាត្រា៣៦(៤) នៃលក្ខន្តិកៈតុលាការ សេចក្ដីប្រកាសនានា ត្រូវតម្កល់ទុកនៅអគ្គលេខាធិការអង្គការសហប្រជាជាតិដែលនឹងបញ្ជូនច្បាប់ចម្លងទាំងនោះទៅឱ្យភាគីក្នុងលក្ខន្តិកៈ និងទៅអគ្រានុកូលដ្ឋានតុលាការ។ ក្នុងករណីជាក់លាក់ណាមួយតុលាការនឹងមានយុត្តាធិការប្រសិនបើភាគីទាំងពីរបានធ្វើការប្រកាសទទួលស្គាល់យុត្តាធិការរបស់ តុលាការ ហើយប្រសិនបើភាគីក្នុងសេចក្ដីប្រកាសរៀងៗខ្លួនបានទទួលស្គាល់យុត្តាធិការនេះទាក់ទងនឹងប្រធានបទនៃកិច្ចដំណើរការនីតិវិធី។ វិវាទអាចត្រូវបានបញ្ជូនទៅតុលាការដោយពាក្យស្នើសុំជាលាយលក្ខណ៍អក្សរឯកតោភាគី។ តាមរបាយការណ៍របស់តុលាការនេះគឺ បច្ចុប្បន្នមានសេចក្ដីប្រកាសចំនួន៧០ ដែលមានសុពលភាពដែលផ្ដល់នូវយុត្តាធិការរបស់តុលាការហើយចាប់តាំងពីការបង្កើតតុលាការនៅឆ្នាំ១៩៤៥ ប្រហែល ៣០ភាគរយនៃសំណុំរឿងរបស់ខ្លួនត្រូវបានដាក់ជូនដោយផ្អែកលើសេចក្ដីប្រកាសបែបនេះ។

### ១.២ បទប្បញ្ញត្តិពិសេស

ជាទូទៅគឺ គេមិនមានតម្រូវការច្បាប់តឹងរ៉ឹងទាក់ទងនឹងទម្រង់និងខ្លឹមសារនៃសេចក្ដីប្រកាសដែលទទួលស្គាល់ថាជា យុត្តាធិការរបស់តុលាការឡើយ។ តែយ៉ាងហោចណាស់រាល់សេចក្ដីប្រកាសទទួលស្គាល់យុត្តាធិការដោយឯកត្តោភាគីគឺ ត្រូវមានចំណងជើង បុព្វកថា បញ្ជាក់ពីការប្រគល់អំណាចយុត្តាធិការ ប្រការចុងក្រោយ និងហត្ថលេខា។

#### ១.២.១ ការផ្ដល់ឱ្យនូវយុត្តាធិការ

សេចក្ដីប្រកាសភាគច្រើនប្រើពាក្យពេចន៍ដែលមានចែងនៅក្នុងមាត្រា៣៦(២) នៃលក្ខន្តិកៈតុលាការដើម្បីផ្ដល់យុត្តាធិការលើតុលាការ។ រដ្ឋាភិបាលនៃរដ្ឋទទួលស្គាល់យុត្តាធិការដោយបង្ខំ និងដោយគ្មានកិច្ចព្រមព្រៀងពិសេសទាក់ទងនឹងរដ្ឋផ្សេងទៀតដែលទទួលយកកាតព្វកិច្ចដូចគ្នា។ ដោយហេតុថាលក្ខណៈនៃយុត្តាធិការរបស់តុលាការមានការព្រមព្រៀងយ៉ាងតឹងរ៉ឹងក៏ដោយក្តីក៏រដ្ឋនៅតែមានសេរីភាពក្នុងការរួមបញ្ចូលការរក្សាទុក (Reservation)នៅក្នុងសេចក្ដីប្រកាសរបស់ពួកគេ។ ការរក្សាទុកគឺជា ការកំណត់ឬការលើកលែងចំពោះការប្ដេជ្ញាចិត្តនៅក្នុងសេចក្ដីប្រកាសដើម្បីទទួលស្គាល់យុត្តាធិការរបស់តុលាការ។ ជួនកាលរដ្ឋគឺ ប្រកាសប្រឆាំងមិនចូលរួមក្នុងដំណើរការតុលាការតាមកម្រិតដែលបានកំណត់។ ទោះយ៉ាងណាក៏ដោយសេចក្ដីប្រកាសត្រូវបានធ្វើឡើងដោយផ្អែកលើលក្ខខណ្ឌទៅវិញទៅមក។ ជាលទ្ធផលលើកលែងតែមានការផ្ដល់ជូនផ្សេងពីនេះ រាល់ការរក្សាទុកអាចនឹងចុះខ្សោយក្នុងឱកាសដូចគ្នាដែលរដ្ឋប្រកាស (Declaring State) នាំសំណុំរឿងទៅតុលាការ

ប្រឆាំងនឹងរដ្ឋមួយផ្សេងទៀត។ ដូច្នេះរដ្ឋជម្លោះណាមួយដែលរដ្ឋប្រកាសនាំសំណុំរឿងទៅតុលាការអាចស្នើសុំការរក្សាទុករបស់រដ្ឋដែលបានប្រកាសប្រឆាំងនឹងរដ្ឋដែលប្រកាសនោះបាន។

គោលបំណងនៃសេចក្ដីប្រកាសគឺ ដើម្បីផ្ដល់នូវវេទិកាមួយសម្រាប់ការដោះស្រាយវិវាទតាមផ្លូវច្បាប់។ ទោះយ៉ាងណាក៏ដោយតុលាការមិនមែនជា វេទិកាតែមួយគត់ដែលអាចរកបានសម្រាប់គោលបំណងនេះទេ។ ហេតុដូច្នេះ រដ្ឋមួយអាចរួមបញ្ចូលនៅក្នុងសេចក្ដីប្រកាសរបស់ខ្លួនអំពីលទ្ធភាពនៃការបញ្ជូនវិវាទទៅវិធីសាស្ត្រផ្សេងទៀតនៃការដោះស្រាយដោយសន្តិវិធីដូចដែលអាចត្រូវបានព្រមព្រៀងគ្នារវាងភាគី។

សេចក្ដីប្រកាសនេះមិនអនុវត្តចំពោះវិវាទណាដែលទាក់ទងនឹងភាគីដែលបានព្រមព្រៀង ឬ ត្រូវយល់ព្រមទទួលយកវិធីសាស្ត្រផ្សេងទៀតនៃការដោះស្រាយដោយសន្តិវិធីដើម្បីជា ការសម្រេចចិត្តចុងក្រោយនិងមានកាតព្វកិច្ច។ ការរក្សាទុកក៏អាចរាប់បញ្ចូលនៃការមិនចាត់បញ្ចូលលក្ខណៈឱ្យតុលាការមាន យុត្តាធិការនូវវិវាទជាក់លាក់ដូចជាជម្លោះទាក់ទងនឹងសន្ធិសញ្ញាជាក់លាក់ ស្ថានភាពជាក់ស្ដែងជាក់លាក់ ជម្លោះប្រដាប់អាវុធ ឬ វិស័យច្បាប់ជាក់លាក់ ដូចជាអធិបតេយ្យភាពដែនដីឬការកំណត់ព្រំដែនបានដែរ។

វិវាទមួយចំនួនដែលទាក់ទងនឹងយុត្តាធិការផ្ទៃក្នុងរដ្ឋគឺ មិនស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការទេពីព្រោះតុលាការអាចបើកសវនាការតែជម្លោះដែលគ្រប់គ្រងដោយច្បាប់អន្តរជាតិ។ បែបនេះក្ដីរដ្ឋ ជាច្រើនមាននិន្នាការចាត់ការរក្សាទុកបែបនេះក្រោមហេតុផលនយោបាយ។

សេចក្ដីប្រកាសនេះមិនអនុវត្តចំពោះវិវាទណាមួយដែលទាក់ទង នឹងបញ្ហាដែលស្ថិតនៅក្រោមច្បាប់អន្តរជាតិដែលមាននៅក្នុងដែនសមត្ថកិច្ចផ្ទៃក្នុងរដ្ឋទេ។ ការរក្សាទុកអាចមានដែនកំណត់បណ្ដោះអាសន្នលើ យុត្តាធិការរបស់តុលាការ ជាពិសេសដែនកំណត់ដែលមិនរាប់បញ្ចូលវិវាទដែលបានកើតឡើងមុនកាលបរិច្ឆេទជាក់លាក់ ឬ ទាក់ទងនឹងព្រឹត្តិការណ៍ដែលបានកើតឡើងមុនកាលបរិច្ឆេទជាក់លាក់ណាមួយ។

ដើម្បីចៀសវាងការប្រឈមមុខនឹងការដាក់ពាក្យសុំដោយរដ្ឋដែលបានធ្វើការប្រកាសជា ឯកតោភាគីដែលទទួលស្គាល់យុត្តាធិការរបស់តុលាការការរក្សាទុកអាចធ្វើឡើងដាច់ដោយឡែកពីគ្នា ឬ ដោយភ្ជាប់មកជាមួយ៖

- សេចក្ដីប្រកាសមិនអនុវត្តចំពោះវិវាទណាមួយដែលភាគីម្ខាងទៀតនៃវិវាទបានទទួលយក យុត្តាធិការរបស់តុលាការតែទាក់ទងនឹង ឬ ក្នុងគោលបំណងវិវាទនោះទេ។
- សេចក្ដីប្រកាសនេះមិនអនុវត្តចំពោះវិវាទណាមួយដែលការទទួលយកយុត្តាធិការជា កាតព្វកិច្ចរបស់តុលាការក្នុងនាមភាគីម្ខាងទៀតចំពោះវិវាទត្រូវបានតម្កល់ទុកតិចជាង ប៉ុន្មានខែមុនពេលដាក់ពាក្យបណ្ដឹងដែលនាំឱ្យមានជម្លោះនៅចំពោះមុខតុលាការ។

### ១.២.២ អវសានប្បញ្ញត្តិ

អវសានប្បញ្ញត្តិគឺជា ឃ្លាចុងក្រោយឬលក្ខខណ្ឌផ្លូវការពាក់ព័ន្ធនឹងការចាប់ផ្ដើមរយៈពេលនិងការបញ្ចប់នៃការប្ដេជ្ញាចិត្តរួមទាំងការរក្សាទុកដែលមានចែងនៅក្នុងសេចក្ដីប្រកាស។ គេអាចមើលឃើញពីច្បាស់លាស់ឃ្លានៃការចូលជាធរមាននៃសេចក្ដីប្រកាសតាមរយៈពាក្យសម្គាល់មួយចំនួនដូចឧទាហរណ៍ថា៖ ការប្រកាសនេះមានប្រសិទ្ធភាពភ្លាមៗ គិតត្រឹមថ្ងៃ។ ជាមួយគ្នានេះ រដ្ឋប្រកាសអាចសម្រេចចិត្តបញ្ជាក់ពីល័ក្ខខ័ណ្ឌដែលអាចធ្វើវិសោធនកម្មការរក្សាទុកបាន។

រដ្ឋាភិបាលរដ្ឋមួយមានសិទ្ធិរក្សាសិទ្ធិផងដែរនៅពេលផ្ដល់ការជូនដំណឹងចំនួនខែ ឬនៅក្នុងពេលវេលាណាមួយនៃវិសោធនកម្មតាមរយៈការជូនដំណឹងដែលបានផ្ញើទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ និងមានសុពលភាពចាប់ពីពេលជូនដំណឹង។ អវសានប្បញ្ញត្តិក៏បញ្ជាក់ផងដែរអំពីបញ្ចប់ឬការដកខ្លួនពីការទទួលយកយុត្តាធិការតុលាការដែរ។

សេចក្ដីប្រកាសបែបនេះគឺ មានសុពលភាពសម្រាប់រយៈពេល ៥ ឆ្នាំហើយត្រូវបញ្ជាក់ពីការបន្ត ឬមិនបន្តជាថ្មីដោយគ្មានល័ក្ខខ័ណ្ឌ ហើយដាក់ជូនទៅកាន់អគ្គលេខាធិការអង្គការសហប្រជាជាតិដោយមានការព្រមានជាមុនក្នុងរយៈពេលប៉ុន្មានខែ។ គួរបញ្ជាក់ថា សេចក្ដីប្រកាសនេះនឹងនៅតែមានសុពលភាពរហូតទាល់តែមានការជូនដំណឹងដល់អគ្គលេខាធិការអង្គការសហប្រជាជាតិដកសេចក្ដីប្រកាសនេះចេញ ដោយមានសុពលភាពចាប់ពីពេលជូនដំណឹងនេះតទៅ។

### ១.២.៣ ការចុះហត្ថលេខា

សេចក្ដីប្រកាសនេះត្រូវតែចុះហត្ថលេខាដោយរដ្ឋាភិបាលនៃរដ្ឋប្រកាស។ នៅក្នុងការអនុវត្តសេចក្ដីប្រកាសបែបនេះត្រូវតែចុះហត្ថលេខាដោយប្រមុខរដ្ឋ ឬ ប្រមុខរដ្ឋាភិបាល ឬ រដ្ឋមន្ត្រីការបរទេស ឬ តំណាងអចិន្ត្រៃយ៍នៃរដ្ឋដែលពាក់ព័ន្ធទៅនឹងអង្គការសហប្រជាជាតិនៅទីក្រុងញូវយ៉ក។

## ២.ការទទួលយកយុត្តាធិការICJដោយសន្ធិសញ្ញា

### ២.១ បទប្បញ្ញត្តិទូទៅ

មាត្រា ៣៦(១) នៃលក្ខន្តិកៈតុលាការបានចែងថាតុលាការមានយុត្តាធិការក្នុងគ្រប់បញ្ហាទាំងអស់ដែលមានចែងជាពិសេសនៅក្នុងសន្ធិសញ្ញានិងអនុសញ្ញាដែលមានសុពលភាព។

នៅក្នុងបរិបទនេះ សន្ធិសញ្ញាពីរប្រភេទអាចត្រូវបានកំណត់៖

(ក) សន្ធិសញ្ញាទ្វេភាគី ឬ ពហុភាគីដែលដោះស្រាយលើវិវាទបញ្ហាជាក់លាក់ណាមួយ តួយ៉ាង សន្ធិសញ្ញាបែបពាណិជ្ជកម្ម ឬ ការដឹកជញ្ជូនតាមផ្លូវអាកាស និង បានកំណត់ប្រយោគដែលផ្តល់យុត្តាធិការនៅតុលាការទាក់ទងនឹងវិវាទច្បាប់ស្តីពីការបកស្រាយឬការអនុវត្តសន្ធិសញ្ញានោះ។

(ខ) សន្ធិសញ្ញាទ្វេភាគី ឬ ពហុភាគីដែលបានបញ្ចូលជាពិសេសក្នុងគោលបំណងដោះស្រាយជម្លោះដោយសន្តិវិធី និងផ្តល់យុត្តាធិការរបស់តុលាការលើវិវាទផ្លូវច្បាប់ណាមួយរវាងភាគីដោយមិនខ្វល់ពីបញ្ហាចោទបែបណានោះទេ។

បច្ចុប្បន្ននេះសន្ធិសញ្ញាពហុភាគីនិងទ្វេភាគីជាង ៣០០ កំពុងអនុវត្តដែលផ្តល់យុត្តាធិការរបស់តុលាការទាំងក្នុងវិវាទទាក់ទងនឹងការបកស្រាយឬការអនុវត្តសន្ធិសញ្ញានេះជាសំណួរឬគ្រប់វិវាទរវាងភាគី។ ចាប់តាំងពីការបង្កើតឡើងនៅខែមិថុនា ឆ្នាំ១៩៤៥ ប្រហែល ៤០ភាគរយនៃសំណុំរឿងដែលត្រូវបានដោះស្រាយដោយតុលាការត្រូវបានដាក់ជូនដោយផ្អែកលើសន្ធិសញ្ញា។

## ២.២ បទប្បញ្ញត្តពិសេស

### ២.២.១ ភាគនៃសន្ធិសញ្ញាដែលផ្តល់យុត្តាធិការឱ្យICJលើជម្លោះបកស្រាយសន្ធិសញ្ញា

រដ្ឋអាចសម្រេចចិត្តបញ្ចូលក្នុងសន្ធិសញ្ញាទ្វេភាគីឬពហុភាគីលើប្រធានបទណាមួយ តាំងពីពាណិជ្ជកម្មឬការដឹកជញ្ជូនតាមផ្លូវអាកាស។ ប្រការដែលផ្តល់យុត្តាធិការលើតុលាការទាក់ទងនឹងវិវាទទាក់ទងនឹងការបកស្រាយ ឬ ការអនុវត្តសន្ធិសញ្ញាដដែលនោះ។

**(ក) សន្ធិសញ្ញាទ្វេភាគី**

នៅក្នុងសន្ធិសញ្ញាទ្វេភាគី មាត្រាយុត្តាធិការអាចសំដៅទៅលើសន្ធិសញ្ញាទាំងមូល ឬ ត្រូវបានកំណត់ចំពោះបទប្បញ្ញត្តិជាក់លាក់នៃសន្ធិសញ្ញា។ ឃ្លាយុត្តាធិការផ្តល់នូវវិធីសាស្ត្រមួយឬច្រើននៃដំណោះស្រាយដោយសន្តិវិធីដែលត្រូវប្រើមុនពេលមានវិវាទអាចត្រូវបានបញ្ជូនទៅតុលាការផងដែរ។

វិវាទណាមួយដែលទាក់ទងនឹងការបកស្រាយ ឬ ក៏ការអនុវត្តសន្ធិសញ្ញាបច្ចុប្បន្ននេះហើយ ដែលមិនអាចដោះស្រាយបានតាមរយៈ ការចរចាអាចត្រូវបានបញ្ជូនទៅកាន់តុលាការយុត្តិធម៌អន្តរជាតិស្របតាមលក្ខន្តិកៈនៃតុលាការនោះដោយភាគីទាំងសងខាងដរាបភាគីទាំងពីរ មិនយល់ព្រមដោះស្រាយដោយមធ្យោបាយសន្តិវិធីផ្សេងទៀត។

**(ខ) សន្ធិសញ្ញាពហុភាគី**

នៅក្នុងសន្ធិសញ្ញាពហុភាគីប្រការដែលមានយុត្តាធិការអាចសំដៅទៅលើសន្ធិសញ្ញាទាំងមូល ឬ ត្រូវបានកំណត់ចំពោះបទប្បញ្ញត្តិជាក់លាក់នៃសន្ធិសញ្ញា។ ឃ្លាយុត្តាធិការជាធម្មតាផ្តល់នូវវិធីសាស្ត្រមួយឬច្រើននៃ

ដំណោះស្រាយដោយសន្តិវិធីដែលត្រូវប្រើមុនពេលមានវិវាទអាចត្រូវបានបញ្ជូនទៅតុលាការ។ ឃ្លានោះក៏អាចត្រូវបានអមដោយបទប្បញ្ញត្តិដែល ផ្តល់ឱ្យភាគីនូវលទ្ធភាពនៃការជ្រើសរើសចេញពីរបបយុត្តាធិការរក្សាទុកដែរ តួយ៉ាងជម្លោះណាមួយរវាងភាគីចំពោះសន្ធិសញ្ញាបច្ចុប្បន្នទាក់ទងនឹងការបកស្រាយ ឬ ការអនុវត្តសន្ធិសញ្ញានេះដែលមិនអាចដោះស្រាយបានតាមរយៈការចរចាអាចត្រូវបញ្ជូនទៅតុលាការយុត្តិធម៌អន្តរជាតិតាម សេចក្តីសំរេច ដោយលក្ខន្តិកៈនៃតុលាការនោះដោយភាគីណាមួយនៃភាគីជម្លោះ។ ក៏ដូចជាភាគីនៃវិវាទអាចយល់ព្រមប្រើមធ្យោបាយផ្សេងទៀតនៃការដោះស្រាយវិវាទដោយសន្តិវិធី មុនពេលបញ្ជូនវិវាទនេះទៅតុលាការយុត្តិធម៌អន្តរជាតិ។

ភាគីនីមួយៗនៅពេលចុះហត្ថលេខាផ្តល់សច្ចាប័នការទទួលយក ឬ ការយល់ព្រម ឬ ការចូលជាសមាជិកនៃសន្ធិសញ្ញានេះអាចប្រកាសថាខ្លួនមិនទទួលអនុវត្តកថាខណ្ឌទី១នៃមាត្រានោះក៏បានដែរ។ភាគីនោះអាចធ្វើការរក្សាទុកបញ្ញត្តិនីមួយៗបានគ្រប់ពេលដោយគ្រាន់តែជូនដំណឹងទៅនាយកដ្ឋាន។

### ២.២.២ ភាគនៃសន្ធិសញ្ញាដែលផ្តល់យុត្តាធិការឱ្យICJលើជម្លោះផ្លូវច្បាប់រវាងភាគ

រដ្ឋអាចក្លាយជាភាគីនៃសន្ធិសញ្ញាពហុភាគីដែលមានស្រាប់ស្តីពីការដោះស្រាយវិវាទដែលផ្តល់ នូវយុត្តាធិការរបស់តុលាការដូចជា អនុសញ្ញាអឺរ៉ុបសម្រាប់ការដោះស្រាយជម្លោះដោយសន្តិវិធី ។

រដ្ឋក៏អាចមានបំណងចរចាអំពីសន្ធិសញ្ញាពហុភាគី ឬ ទ្វេភាគីថ្មីស្តីពីការដោះស្រាយវិវាទដែលផ្តល់យុត្តាធិការរបស់តុលាការក្នុងគ្រប់វិវាទរវាងភាគី។

គួរកត់សំគាល់ថា សាលក្រមនៃយុត្តាធិការនៅតុលាការដើម្បីជំនុំជម្រះរាល់វិវាទរវាងភាគីអាចត្រូវបានបញ្ចូលទៅក្នុងសន្ធិសញ្ញាពហុភាគី ឬ ទ្វេភាគីដែលមិនផ្តោតលើការដោះស្រាយវិវាទដោយសន្តិវិធី។ ឧទាហរណ៍សន្ធិសញ្ញាសន្តិភាពអាចរួមបញ្ចូលជំពូកមួយអំពីការដោះស្រាយជម្លោះដោយសន្តិវិធីនិងកត់ត្រាកិច្ចព្រមព្រៀងរបស់ភាគីដែលពួកគេទទួលយកយុត្តាធិការរបស់តុលាការទាក់ទងនឹងវិវាទទាំងអស់ ។

សន្ធិសញ្ញា (ពហុភាគី ឬ ទ្វេភាគី) ដែលផ្តល់នូវយុត្តាធិការរបស់តុលាការក្នុងគ្រប់វិវាទរវាងភាគីជា ធម្មតាមានធាតុផ្សំដូចជា ចំណងជើង បុព្វកថា ការប្រគល់អំណាចយុត្តាធិការ បញ្ហានីតិវិធី ការរៀបចំទូទៅ អវសានប្បញ្ញត្តិ និង ហត្ថលេខា។

## ៣.ការទទួលយកយុត្តាធិការតុលាការICJដោយកិច្ចព្រមព្រៀងពិសេស

### ៣.១ បទប្បញ្ញត្តទូទៅ

យោងតាមមាត្រា៣៦ (១) នៃលក្ខន្តិកៈតុលាការយុត្តាធិការរបស់តុលាការរួមមានសំណុំរឿងទាំងអស់ដែលភាគីសំដៅលើ។ ក្នុងករណីបែបនេះភាគីបង្ហាញការយល់ព្រមរបស់ពួកគេដោយផ្អែកលើមូលដ្ឋានពិសេស

ដោយកិច្ចព្រមព្រៀងពិសេសមួយដែលស្នើសុំឱ្យតុលាការជំនុំជម្រះក្តីលើវិវាទជាក់លាក់ណាមួយ។ យុត្តាធិការត្រូវបានប្រគល់ឱ្យតុលាការនៅពេលជូនដំណឹងដល់តុលាការអំពីកិច្ចព្រមព្រៀងពិសេសនោះហើយ។

ចាប់តាំងពីការបង្កើតឡើងនៅឆ្នាំ១៩៤៥ សំណុំរឿងចំនួន១៧ និងគិតជាភាគរយគឺប្រហែល ១៥ភាគរយនៃចំនួនករណីសរុបត្រូវបានបញ្ជូនទៅតុលាការតាមរយៈកិច្ចព្រមព្រៀងពិសេស។ ភាគច្រើន សំណុំរឿងទាំងនោះពាក់ព័ន្ធនឹងវិវាទច្បាប់ ទាក់ទងនឹងអធិបតេយ្យភាពទឹកដី ឬ ការកំណត់ព្រំដែនដីឬព្រំដែនសមុទ្រ។

នៅពេលកិច្ចព្រមព្រៀងពិសេសមួយត្រូវបានបញ្ចប់ និងជូនដំណឹងដល់តុលាការ យុត្តាធិការតុលាការត្រូវបានអនុវត្តដោយគ្រប់ភាគីនៃវិវាទ។ ជាគោលការណ៍ដោយសារភាគីទាំងពីរបានសម្តែងការចាប់អារម្មណ៍យ៉ាងពិតប្រាកដចំពោះតុលាការក្នុងការដោះស្រាយវិវាទរបស់ពួកគេគឺ គ្មានការជំទាស់ជាបឋមទាក់ទងនឹងយុត្តាធិការរបស់ខ្លួនឡើយហើយក៏មិនមានបញ្ហាទាក់ទងនឹងការអនុវត្តសាលក្រមដែរ។

### ៣.២ បទប្បញ្ញត្តិពិសេស

កិច្ចព្រមព្រៀងពិសេសគឺជា សន្ធិសញ្ញាដែលមានគោលបំណងតែមួយគត់គឺសំដៅលើវិវាទជាក់លាក់មួយទៅតុលាការ។ ដូចសន្ធិសញ្ញាផ្សេងទៀតដែរជាធម្មតាវាមានសមាសធាតុដូចជា៖ ចំណងជើង បុព្វកថា សាលក្រមនៃយុត្តាធិការ និយមន័យនៃជម្លោះ ឬ ការបង្កើតសំណួរ បញ្ហានីតិវិធី ការរៀបចំទូទៅ ឃ្លាចុងក្រោយ និងហត្ថលេខា។

ជាទូទៅ ចំណងជើងនៃកិច្ចព្រមព្រៀងពិសេសបង្ហាញពីគោលបំណងរបស់ខ្លួនដែលជាការដាក់ជូនតុលាការនូវវិវាទជាក់លាក់មួយរវាងរដ្ឋនិងកំណត់ភាគី។

**ឧទាហរណ៍**៖កិច្ចព្រមព្រៀងពិសេសសម្រាប់ការបញ្ជូនទៅតុលាការយុត្តិធម៌អន្តរជាតិនៃជម្លោះរវាងរដ្ឋAនិងរដ្ឋB។

ចំណែកនៅក្នុងបុព្វកថា ភាគីនៃកិច្ចព្រមព្រៀងពិសេសគឺ ភាគីជាទូទៅទទួលស្គាល់ពីអត្ថិភាពនៃវិវាទហើយបង្ហាញពីចេតនារបស់ពួកគេថាត្រូវដោះស្រាយដោយតុលាការរុញប្រយោជន៍ដែលភាគីទីបីបានដើរតួដើម្បីជួយសម្រួលដល់ការដោះស្រាយដោយសន្តិវិធី ឬ ជំហានវិជ្ជមានដែលត្រូវអនុវត្ត ចំពោះដំណោះស្រាយវិវាទ។

បន្ទាប់មកការប្រកាសប្រគល់យុត្តាធិការដល់តុលាការ។ នៅក្នុងសាលក្រមរបស់តុលាការគឺ តុលាការនឹងឆ្លើយសំនួរដែលគូភាគីដាក់ជូន។ ភាគីអាចស្នើសុំឱ្យតុលាការផ្តល់ចម្លើយចុងក្រោយចំពោះជម្លោះរបស់ពួកគេ។ ភាគីក៏អាចសុំឱ្យតុលាការបង្កើតច្បាប់អន្តរជាតិណាមួយអនុវត្តចំពោះជម្លោះបានដែរ។ វិវាទផ្លូវច្បាប់ទាក់ទងនឹងការទាមទារអធិបតេយ្យភាពលើទឹកដីព្រំដែនដែលភាគីទាំងពីរ មិនមានជម្លោះដូចជាការទាមទារអធិបតេយ្យភាពលើកោះអាចត្រូវបាននាំទៅតុលាការ។ សំណួរនៃការកំណត់ទិសដៅនៃព្រំដែនអាចត្រូវបានបញ្ជូនទៅតុលាការក្នុងករណីដែលភាគីមិនយល់ស្របអំពីដំណើរច្បាស់លាស់នៃព្រំដែនរវាងពួកគេ។ ជាទូទៅតុលាការត្រូវ

បានស្នើសុំដើម្បីកំណត់ថាតើអធិបតេយ្យភាពលើ (ឈ្មោះតំបន់ដែលលាតសន្ធឹងពីទីតាំងណាដល់ណា) ជាកម្មសិទ្ធិរបស់ រដ្ឋA ឬ រដ្ឋB។

ជំនួសឱ្យការស្នើសុំឱ្យតុលាការដោះស្រាយបញ្ហាជាក់លាក់មួយទាក់ទងនឹងអធិបតេយ្យភាព ឬ ការកំណត់ព្រំដែន ភាគីអាចស្នើសុំឱ្យតុលាការកំណត់ការវិនិច្ឆ័យរបស់ខ្លួនចំពោះការកំណត់ច្បាប់ដែលអនុវត្តចំពោះបញ្ហានេះ។

តុលាការត្រូវបានស្នើសុំដើម្បីកំណត់ថាតើគោលការណ៍ និង វិធាននៃច្បាប់អន្តរជាតិណាដែលអាចអនុវត្តចំពោះការកំណត់ព្រំដែនរវាងភាគីនៃបញ្ហាអធិបតេយ្យពួកគេ។

ក្នុងករណីពិសេសខ្លះគូភាគីអាចយល់ព្រមលើអត្ថិភាពនៃវិវាទ និងការបញ្ជូនខ្លួនទៅតុលាការប៉ុន្តែមិនអាចឯកភាពលើនិយមន័យច្បាស់លាស់នៃវិវាទ ឬ លើសំណួរជាក់ស្តែងដែលត្រូវតុលាការសម្រេច។ ដើម្បីចៀសវាងការជាប់គាំងភាគីអាចបញ្ចប់ជម្លោះតាមរយៈកិច្ចព្រមព្រៀងក្របខ័ណ្ឌ[3]។ បន្ទាប់មកតុលាការត្រូវកំណត់សំណួរពិតប្រាកដដែលត្រូវដោះស្រាយដោយផ្អែកលើការដាក់ស្នើរបស់ភាគី និងដើម្បីឆ្លើយសំណួរទាំងនោះ។ ទោះយ៉ាងណាក៏ដោយភាគីទាំងពីរគួរតែកំណត់ពីគោលបំណងនៃជម្លោះឱ្យបានច្បាស់លាស់តាមដែល អាចធ្វើទៅបាននៅក្នុងកិច្ចព្រមព្រៀងក្របខ័ណ្ឌ។

### ៣.២.១ នីតិវិធីផ្តល់យុត្តាធិការតាមរយៈកិច្ចព្រមព្រៀងពិសេស

នីតិវិធីត្រូវបានគ្រប់គ្រងដោយលក្ខន្តិកៈតុលាការ និងច្បាប់របស់តុលាការ។ ទោះយ៉ាងណាក៏ដោយប្រសិនបើភាគីចង់បានពួកគេអាចរួមបញ្ចូលធាតុនីតិវិធីមួយចំនួននៅក្នុងកិច្ចព្រមព្រៀងពិសេស។ នៅក្នុងដែនកំណត់ដែលកំណត់ដោយលក្ខន្តិកៈតុលាការ និងវិធាននៃតុលាការគឺ ភាគីអាចផ្តល់ការចង្អុលបង្ហាញអំពីសមាសភាពតុលាការការដោយសរសេរជាលាយលក្ខណ៍អក្សរការជជែកវែកញែកផ្ទាល់មាត់ភាសានៃដំណើរការ និងឥទ្ធិពលនៃសាលក្រម។

យោងតាមមាត្រា២៦ នៃលក្ខន្តិកៈរបស់តុលាការ អង្គជំនុំជម្រះអាចត្រូវបានបង្កើតឡើងដើម្បីដោះស្រាយករណីជាក់លាក់មួយប្រសិនបើភាគីស្នើសុំ។

ភាគីនានាត្រូវស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងបើកសវនាការលើសំណុំរឿងដែល មានមនុស្សចំនួនមួយចំនួននិងត្រូវបង្កើតឡើងបន្ទាប់ពីបានពិគ្រោះយោបល់ជាមួយភាគីដោយអនុលោមតាម មាត្រា២៦ និង មាត្រា៣១ នៃលក្ខន្តិកៈរបស់តុលាការ។

[3] កិច្ចព្រមព្រៀងក្របខ័ណ្ឌផ្តល់សិទ្ធិឱ្យភាគីនីមួយៗតាមឆន្ទានុសិទ្ធិឬអាស្រ័យលើលក្ខខណ្ឌជាក់លាក់ដើម្បីរឹបអូសយកតុលាការនៃជម្លោះ។

ប្រសិនបើតុលាការរួមបញ្ចូលចៅក្រមសញ្ជាតិនៃភាគីណាមួយភាគីណាមួយអាចជ្រើសរើសមនុស្សម្នាក់មកអង្គុយជាចៅក្រម[4] ។ ប្រសិនបើតុលាការមិនមានចៅក្រមសញ្ជាតិនៃភាគីទេភាគីនីមួយៗអាចបន្តជ្រើសរើសចៅក្រម[5] ។ ដូច្នេះកិច្ចព្រមព្រៀងពិសេសមួយអាចដោះស្រាយបញ្ហារបស់ចៅក្រមពិសេសបាន។

ភាគីនីមួយៗអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនតាមមាត្រា ៣១ នៃលក្ខន្តិកៈតុលាការដើម្បីជ្រើសរើសមនុស្សម្នាក់មកអង្គុយជា ចៅក្រមពិសេស។ ភាគីដែលជ្រើសរើសប្រើសិទ្ធិនេះត្រូវជូនដំណឹងទៅភាគីម្ខាងទៀតជាលាយលក្ខណ៍អក្សរមុននឹងអនុវត្ត។

យោងតាមមាត្រា៤៦ នៃវិធានតុលាការចំនួននិងលំដាប់នៃបណ្តឹងឧទ្ធរណ៍នឹងត្រូវគ្រប់គ្រងដោយបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងពិសេស[6]។ តុលាការលើកទឹកចិត្តភាគីឱ្យរួមបញ្ចូលនៅក្នុងបទប្បញ្ញត្តិកិច្ចព្រមព្រៀងពិសេសរបស់ពួកគេទាក់ទងនឹងចំនួន និងលំដាប់ការស្នើរើសចៅក្រម និងជ្រើសរើសយកការបញ្ជូនជាលាយលក្ខណ៍អក្សរជាបន្តបន្ទាប់ដោយភាគីម្ខាងបានប្តឹងឧទ្ធរណ៍។

ដោយគ្មានការរើសអើងចំពោះសំនួរណាមួយដែលជា បន្ទុកនៃភស្តុតាងភាគីត្រូវស្នើសុំឱ្យតុលាការអនុញ្ញាតនីតិវិធីដូចខាងក្រោមទាក់ទងនឹងការតវ៉ាលាយលក្ខណ៍អក្សរដែលរួមមាន៖

(ក) សារណានៃ រដ្ឋA ដែលត្រូវដាក់ជូនកំឡុងខែកំណត់ព្រៀងនៃ ការជូនដំណឹង អំពីកិច្ចព្រមព្រៀងពិសេសបច្ចុប្បន្ននេះទៅតុលាការ។

(ខ) ការតតាំងនឹងសារណារបស់រដ្ឋBដែលត្រូវដាក់ជូនក្នុងរយៈពេលប៉ុន្មានខែនៃការប្រគល់សារណារបស់ រដ្ឋA

(គ) ការឆ្លើយតបរបស់ រដ្ឋA អមដោយការរំលឹកឡើងវិញនៃ រដ្ឋB ដែលត្រូវបញ្ជូនក្នុងរយៈពេលដែលតុលាការអាចបង្គាប់។

[4] មាត្រា៣១(២) ប្រសិនបើតុលាការរួមបញ្ចូលចៅក្រមសញ្ជាតិរបស់ភាគីណាមួយនៃភាគីណាមួយផ្សេងទៀតភាគីអាចជ្រើសរើសមនុស្សម្នាក់ដើម្បីអង្គុយជាចៅក្រម។ ប្រធានតុលការត្រូវស្នើសុំមួយឬបើចាំបាច់ពីរសមាជិកនៃតុលាការបង្កើតអង្គជំនុំជម្រះដើម្បីផ្តល់កន្លែងដល់សមាជិកនៃតុលាការសញ្ជាតិរបស់ភាគីពាក់ព័ន្ធហើយបើពួកគេមិនអាចមានវត្តមានទេចៅក្រមត្រូវបានជ្រើសរើសជាពិសេសដោយភាគី។

[5] មាត្រា៣១(៣) ប្រសិនបើតុលាការរួមបញ្ចូលនៅលើតុចៅក្រមនៃសញ្ជាតិរបស់ភាគីនីមួយៗភាគីអាចបន្តជ្រើសរើសចៅក្រមដូចដែលបានផ្តល់ជូននៅក្នុងកថាខណ្ឌទី ២ នៃមាត្រានេះ។

[6] មាត្រា ៤៦នៃវិធានតុលាការបានកំណត់ថា ក្នុងករណីដែលចាប់ផ្តើមដោយការជូនដំណឹងអំពីកិច្ចព្រមព្រៀងពិសេសមួយចំនួននិងលំដាប់នៃការប្តឹងឧទ្ធរណ៍ត្រូវគ្រប់គ្រងដោយបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះលុះត្រាតែតុលាការបន្ទាប់ពីបានដឹងពីទស្សនៈរបស់ភាគីទាំងពីរដោយសម្រេចផ្សេងពីនេះ។ ប្រសិនបើកិច្ចព្រមព្រៀងពិសេសមិនមានប្បញ្ញតិបែបនោះទេហើយប្រសិនបើភាគីទាំងពីរមិនបានឯកភាពគ្នាជាបន្តបន្ទាប់អំពីចំនួននិងលំដាប់នៃការប្តឹងនោះពួកគេម្នាក់ៗត្រូវរៀបចំសារណាក្នុងរយៈពេលកំណត់តែមួយ។ តុលាការមិនអនុញ្ញាតឱ្យធ្វើបទបង្ហាញនៃការឆ្លើយតបទេលុះត្រាតែពួកគេយល់ឃើញថាចាំបាច់។

ទាក់ទងនឹងការជជែកវែកញែកដោយផ្ទាល់មាត់ ត្រូវផ្អែកលើមាត្រា ៥៨(២) នៃវិធានតុលាការ ផ្តល់ថាដីកាដែលភាគីនឹងត្រូវស្តាប់នឹងត្រូវដោះស្រាយដោយតុលាការបន្ទាប់ពីទស្សនៈរបស់ភាគីត្រូវបានបញ្ជាក់[7]។

គូភាគីត្រូវយល់ព្រមដោយមានការយល់ព្រមពីតុលាការលើដីកាបង្គាប់ឱ្យបើកសវនាការ។ ប្រសិនបើភាគីមិនឯកភាពទេដីកានេះត្រូវចេញដោយតុលាការ។

មាត្រា៣៩ នៃលក្ខន្តិកៈតុលាការ និងមាត្រា៥១ នៃវិធានតុលាការផ្តល់ថាភាគីអាចយល់ព្រមអំពីដំណើរការនីតិវិធីត្រូវធ្វើឡើងជាភាសាផ្លូវការតែមួយគត់របស់តុលាការ។ ក្នុងករណីគ្មានកិច្ចព្រមព្រៀងភាគីនីមួយៗអាចប្រើភាសាដែលខ្លួនពេញចិត្ត។

ភាគីយល់ស្របថាការតវ៉ាជាលាយលក្ខណ៍អក្សរនិងអំណះអំណាងផ្ទាល់មាត់របស់ពួកគេនឹងត្រូវបង្ហាញជាភាសាអង់គ្លេសឬភាសាបារាំង។

ភាគីអាចយល់ព្រមលើកិច្ចការពិសេស ដើម្បីចៀសវាងអំពើណាមួយដែលអាចធ្វើឱ្យអន្តរាយដល់ដំណោះស្រាយដោយសន្តិវិធីនៃជម្លោះឬគំរាមកំហែងដល់សន្តិភាពរវាងភាគី។ ពេលចាប់ពីពេលជូនដំណឹងអំពីកិច្ចព្រមព្រៀងពិសេសទៅតុលាការភាគីណាមួយអាចដាក់ពាក្យស្នើសុំវិធានការណ៍បណ្តោះអាសន្ន បាន។

ភាគីនានានឹងទទួលយកជាស្ថាពរនិងមានកាតព្វកិច្ចលើគូភាគីចំពោះការសម្រេចរបស់តុលាការ។ភាគីត្រូវអនុវត្តសេចក្តីសម្រេចរបស់តុលាការទាំងស្រុងនិងដោយសុចរិត។

ភ្លាមៗបន្ទាប់ពីការបញ្ជូនសាលក្រមទៅភាគីនានា ត្រូវធ្វើការចរចាអំពីបែបបទសម្រាប់ការប្រតិបត្តិរបស់ខ្លួន។ ប្រសិនបើភាគី មិនអាចឈានដល់កិច្ចព្រមព្រៀងក្នុងរយៈពេលកំណត់ទេភាគីណាមួយអាចស្នើសុំឱ្យតុលាការចេញសាលក្រមបន្ថែមដើម្បីកំណត់ពីរបៀបនៃការអនុវត្តសាលក្រមរបស់ខ្លួន។

### ៤. ការទទួលយកយុត្តាធិការICJដោយសេចក្តីប្រកាសរបស់រដ្ឋឆ្លើយតប

វិធីសាស្ត្រនៃការទទួលយកយុត្តាធិការខាងលើគឺ សុទ្ធទាក់ទងនឹងស្ថានភាពដែលរដ្ឋបានទទួលយកយុត្តាធិការ របស់តុលាការមុនពេលដែលតុលាការត្រូវតុលាការត្រូវរឹបអូសនីតិវិធីនៅពេលដែលឯកសារដែលត្រូវការដើម្បីបង្កើតដំណើរការត្រូវបានបញ្ជូនទៅតុលាការ ដោយជាក់លាក់ជម្លោះផ្លូវច្បាប់។

ទោះយ៉ាងណាក៏ដោយរដ្ឋមួយអាចដាក់ពាក្យសុំឯកតោភាគីដើម្បីរៀបចំដំណើរការ នីតិវិធីនៅចំពោះមុខតុលាការដោយមិនមានការធានាពីការយល់ព្រមពីរដ្ឋដែលឆ្លើយតប។ នៅដំណាក់កាលនេះតុលាការមិនមាន

[7] មាត្រា ៥៨កថាខណ្ឌទី២ នៃវិធានតុលាការកំណត់ថា បទបញ្ជាដែលភាគីនឹងត្រូវស្តាប់នៃវិធីដោះស្រាយភស្តុតាងនិងការពិនិត្យសាក្សីនិងអ្នកជំនាញព្រមទាំងចំនួនអ្នកប្រឹក្សានិងអ្នកតស៊ូមតិដែលត្រូវស្តាប់ជំនួសភាគីនីមួយៗនឹងត្រូវតុលាការសម្រេចបន្ទាប់ពី ទស្សនៈរបស់ភាគីត្រូវបានកំណត់ដោយអនុលោមតាមមាត្រា ៣១ នៃវិធានទាំងនេះ។ មាត្រា ៣១បានពន្យល់ថា នៅក្នុងគ្រប់ករណីដែលបានបញ្ជូនទៅតុលាការប្រធានត្រូវបញ្ជាក់ពីទស្សនៈរបស់ភាគីទាក់ទងនឹងសំណួរអំពីនីតិវិធី។ ចំពោះគោលបំណងនេះតុលាការនឹងកោះហៅភ្នាក់ងាររបស់ភាគីដើម្បីជួបឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

យុត្តាធិការក្នុងការដោះស្រាយពាក្យស្នើសុំនេះទេ។ យោងតាមមាត្រា ៣៨(៥) នៃវិធានតុលាការគឺ តុលាការបញ្ជូនពាក្យសុំទៅរដ្ឋដែលមានសក្តានុពលឆ្លើយតប[៨]។ តុលាការមិនអាចចាត់វិធានការអ្វីផ្សេងទៀតបានឡើយលុះត្រាតែ ឬ រហូតដល់រដ្ឋដែលប្រឆាំងនឹងការស្នើសុំនេះយល់ព្រមពីយុត្តាធិការរបស់តុលាការក្នុងគោលបំណងនៃសំណុំរឿង។ រដ្ឋនោះអាចទទួលយកយុត្តាធិការរបស់តុលាការដោយសេចក្តីប្រកាសដោយផ្ទាល់ប៉ុន្តែក៏តាមរយៈការប្រព្រឹត្តជាបន្តបន្ទាប់ដែលបញ្ជាក់ពីការព្រមព្រៀងឧទាហរណ៍ដោយការដាក់ពាក្យជាលាយលក្ខណ៍អក្សរនៃការប្តឹងបក ឬ បង្ហាញខ្លួននៅចំពោះមុខតុលាការ។ ក្នុងករណីបែបនេះតុលាការទទួលបានយុត្តាធិការហើយអាចបន្តជំនុំជម្រះក្តីលើវិវាទបាន។

### កថាខណ្ឌទី២៖ យុត្តាធិការប្រឹក្សាយោបល់

ដោយសារមានតែរដ្ឋទេដែលមានសិទ្ធិបង្ហាញខ្លួននៅចំពោះមុខតុលាការអង្គការអន្តរជាតិសាធារណៈគឺអង្គការអន្តរជាតិនឹងមិនអាចជាភាគី នៃសំណុំរឿងមួយនៅចំពោះមុខតុលាការបានឡើយ។ ទោះយ៉ាងណាក៏ដោយនីតិវិធីពិសេសដែលជានីតិវិធីផ្តល់ប្រឹក្សាគឺអាចធ្វើឱ្យអង្គការទាំងនោះមានទំនាក់ទំនងនឹងតុលាកាយុត្តិធម៌អន្តរជាតិបាន។

ទោះបីជាផ្អែកលើដំណើរការវិវាទក៏ដោយ ក៏ដំណើរការស៊ើបអង្កេតមានលក្ខណៈពិសេស ដោយឡែកដែលបណ្តាលមកពីលក្ខណៈពិសេសនិងគោលបំណងនៃមុខងារប្រឹក្សានេះតែម្តងរបស់អង្គការ។

ថ្វីត្បិតតែគ្មានចរិតបង្ខិតបង្ខំក៏ដោយក៏យោបល់របស់តុលាការនៅតែមានទំងន់ផ្អែកច្បាប់ និងអំណាចសីលធម៌ខ្ពស់។ ភាគច្រើនគឺនឹងក្លាយជាឧបករណ៍ការពារការទូត និងជួយរក្សាសន្តិភាព។ តាមវិធីផ្ទាល់ខ្លួនមតិយោបល់ក៏រួមចំណែកដល់ការបំភ្លឺនិងការអភិវឌ្ឍច្បាប់អន្តរជាតិ និងដើម្បីពង្រឹងទំនាក់ទំនងដោយសន្តិវិធីរវាងរដ្ឋ។

ការប្រឹក្សាយោបល់ បានក្លាយជា យុត្តាធិការទី២របស់តុលាការ យុត្តិធម៌អន្តរជាតិនេះ ដូចដែលមានចែងរៀបរាប់នៅជំពូកទី៤នៃ លក្ខន្តិកៈរបស់តុលាការ ។ មាត្រា៦៥(១) បានចែងថា តុលាការអាចផ្តល់យោបល់ប្រឹក្សាលើបញ្ហាច្បាប់ តាមសំណើរបស់អង្គភាពណាមួយដែលមានសមត្ថកិច្ចស្របតាមធម្មនុញ្ញអង្គការសហប្រជាជាតិផ្តល់ឱ្យក្នុងការដាក់សំណើ។

[៨] មាត្រា៣៨ នៃកថាខណ្ឌទី៥នៃវិធានតុលាការបញ្ជាក់ថា នៅពេលដែលរដ្ឋដាក់ពាក្យឱ្យស្នើរកយុត្តាធិការរបស់តុលាការតាមការយល់ព្រមតែមិនទាន់ត្រូវបានផ្តល់ឱ្យឬបង្ហាញដោយរដ្ឋដែលប្រឆាំងនឹងការដាក់ពាក្យសុំបែបនេះនោះពាក្យសុំនឹងត្រូវបញ្ជូនទៅរដ្ឋនោះ។ ទោះយ៉ាងណាក៏ដោយវានឹងមិនត្រូវបានបញ្ចូលទៅក្នុងបញ្ជីទូទៅឡើយហើយក៏មិនមានសកម្មភាពណាមួយនៅក្នុងដំណើរការជំនុំជម្រះដែរលុះត្រាតែនិងរហូតដល់រដ្ឋប្រឆាំងដែលការស្នើសុំបែបនេះត្រូវបានយល់ព្រមដោយយុត្តាធិការរបស់តុលាការសម្រាប់គោលបំណងនៃសំណុំរឿង។

តាមការបកស្រាយរបស់បណ្ឌិតMohamed Sameh Ahmed Mohamed នៃនិក្ខេបបទរបស់លោកស្តីពីតួនាទីរបស់តុលាការICJគឺលោករកឃើញថាមានបុព្វហេតុពីរដែលជម្រុញឱ្យតុលាការនេះត្រូវបានគេផ្តល់ យុត្តាធិការប្រឹក្សាយោបល់គឺ ហេតុផលទីមួយ ដើម្បីជាជំនួយអង្គការនិងភ្នាក់ងារក្នុងការសម្រេចចិត្តដែលពួកគេគួរតែដើរតាម និងទីពីរគឺដើម្បីជាជំហានសម្រួលនូវករណីជម្លោះដាក់ជូននាពេលអនាគត ឬ ជាការសម្រេចចិត្តបន្ទាន់។

## ផ្នែកទី១៖ អង្គការមានសមត្ថកិច្ចដាក់សំណើសុំការប្រឹក្សាយោបល់

មាត្រា៩៦ នៃធម្មនុញ្ញអង្គការសហប្រជាជាតិបានគូសបញ្ជាក់ថា មហាសន្និបាត និងក្រុមប្រឹក្សាសន្តិសុខ ក៏ដូចជា អង្គការនយោបាយដទៃ និងភ្នាក់ងារពិសេសផ្សេងទៀតដែលស្ថិតក្រោមអាជ្ញាធររបស់មហាសន្និបាតមានសិទ្ធិក្នុងការស្នើមតិយោបល់ប្រឹក្សាពីតុលាការយុត្តិធម៌អន្តរជាតិ។ នីតិវិធីនេះមានផ្តល់ជូនដល់អង្គការសហប្រជាជាតិចំនួន ៥ ទីភ្នាក់ងារឯកទេសចំនួន ១៥ និងអង្គការពាក់ព័ន្ធ១។ តទៅទៀត យើងនឹងពន្យល់លម្អិតអំពីអង្គការដែលមានសមត្ថកិច្ចដាក់សំណើ តែមានរបៀបពីរយ៉ាងគឺ មានតែអង្គការមួយចំនួនប៉ុណ្ណោះដែលអាចដាក់សំណើដោយផ្ទាល់ និងមួយចំនួនទៀតអាចដាក់សំណើបានតែដោយប្រយោលប៉ុណ្ណោះ។ តាមកំណត់ហេតុរបស់អង្គការសហប្រជាជាតិ គិតត្រឹមឆ្នាំ២០១៧មានសំណើ២៨ប៉ុណ្ណោះដែលបានស្នើមកកាន់តុលាការយុត្តិធម៌អន្តរជាតិ ក្នុងនោះច្រើនបំផុតដល់ទៅ១៧សំណើបានមកពីមហាសន្និបាត ១ មកពីក្រុមប្រឹក្សាសន្តិសុខ ២ មកពីក្រុមប្រឹក្សាសេដ្ឋកិច្ច និង សង្គម ៣ សំណើបានមកពី គណៈកម្មាធិការសម្រាប់ការត្រួតពិនិត្យវិនិច្ឆ័យកិច្ចរដ្ឋបាល និង ៥សំណើទៀតមកពី សំណើមកពីអង្គការអប់រំ វិទ្យាសាស្ត្រ និង វប្បធម៌អង្គការសហប្រជាជាតិUNESCO, អង្គការសុខភាពពិភពលោក WHO, អង្គការសមុទ្រអន្តរជាតិ IMO, អង្គការមូលនិធិសម្រាប់ការអភិវឌ្ឍកសិកម្ម IFAD។

### ១.១ អង្គការមានសមត្ថកិច្ចដោយផ្ទាល់

#### ១.១.១ មហាសន្និបាត

ដូចដែលបានចែងនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ មុខងាររបស់មហាសន្និបាតគឺពិភាក្សា និងផ្តល់អនុសាសន៍លើប្រធានបទទាក់ទងនឹងសន្តិភាពនិងសន្តិសុខអន្តរជាតិរួមទាំងការអភិវឌ្ឍ ការដកហូតអាវុធ សិទ្ធិមនុស្ស ច្បាប់អន្តរជាតិនិងការធ្វើមជ្ឈត្តកម្មដោយសន្តិវិធី ជម្លោះរវាងប្រជាជាតិ។ រដ្ឋជាសមាជិកអង្គការសហប្រជាជាតិនីមួយៗទទួលបានការបោះឆ្នោតមួយនៅក្នុងសភា។ បច្ចុប្បន្នអង្គការនេះ មានរដ្ឋជាសមាជិកអង្គការសហប្រជាជាតិចំនួន ១៩៣ ។ ប្រធានមហាសន្និបាតផ្លាស់ប្តូរតាមសម័យប្រជុំនីមួយៗហើយត្រូវបានជ្រើសរើសដោយស្ថាប័នផ្ទាល់តែម្តង។ ក្នុងចំណោមអង្គការ៥ដទៃទៀតនៃអង្គការសហប្រជាជាតិ គឺមានតែមហាសន្និបាត និង ក្រុមប្រឹក្សាសន្តិសុខប៉ុណ្ណោះដែលមានសមត្ថកិច្ចក្នុងការដាក់សំណើដោយផ្ទាល់។ នេះដោយផ្អែកលើ

៩៦(១)។ អនុលោមតាមមាត្រានៃធម្មនុញ្ញអង្គការសហប្រជាជាតិនោះហើយ គឺថែមទាំងបញ្ជាក់ថាមានតែមហាសន្និបាតឬក្រុមប្រឹក្សាសន្តិសុខអាចស្នើសុំឱ្យតុលាការយុត្តិធម៌អន្តរជាតិផ្តល់យោបល់លើបញ្ហាច្បាប់។

### ១.១.២ ក្រុមប្រឹក្សាសន្តិសុខ

ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិបានធ្វើឱ្យយើងអាចប្រមើលមើលពីទំនាក់ទំនងស៊ីមេទ្រី គ្នារវាងក្រុមប្រឹក្សាសន្តិសុខនិងតុលាការយុត្តិធម៌អន្តរជាតិ ដែលជាស្ថាប័នតុលាការសំខាន់របស់អង្គការនេះ។ ទំនាក់ទំនងនោះគឺក្រុមប្រឹក្សាអាចប្រើតុលាការនេះជាឧបករណ៍ ក្នុងការអនុវត្តការទទួលខុសត្រូវរបស់ខ្លួនចំពោះការថែរក្សាសន្តិភាពនិងសន្តិសុខអន្តរជាតិ។

ឧបករណ៍មួយក្នុងចំណោមមធ្យោបាយដែលក្រុមប្រឹក្សាអាចដោះស្រាយដោយសន្តិវិធីនូវវិវាទ អន្តរជាតិដែលប៉ះពាល់ដល់សន្តិភាពនិងសន្តិសុខអន្តរជាតិគឺការប្រើប្រាស់យុត្តាធិការរបស់ ICJ ក្នុងករណីដូចបានចែងក្នុងមាត្រា៣៦(៣)នៃធម្មនុញ្ញអង្គការសហប្រជាជាតិ[9]។ ក្រុមប្រឹក្សានេះក៏មានសមត្ថកិច្ចបរិបូរណ៍ក្នុងការសុំឱ្យផ្តល់ការប្រឹក្សាយោបល់ផ្នែកច្បាប់[10]។ ក្នុងពេលជាមួយគ្នានេះធម្មនុញ្ញក៏ផ្តល់ឱ្យក្រុមប្រឹក្សានូវការទទួលខុសត្រូវចំពោះការដោះស្រាយករណីដែលមិនត្រូវបានអនុវត្តដោយរដ្ឋដោយការវិនិច្ឆ័យរបស់តុលាការ ដែលបាននាំមកនៅចំពោះមុខក្រុមប្រឹក្សាផងដែរ[11]។ លើសពីនេះក្រុមប្រឹក្សា រួមជាមួយមហាសន្និបាតនេះហើយគឺជា អង្គនៃការជ្រើសរើសចៅក្រមនៃ ICJ ហើយប្រធាន ICJ ត្រូវសង្ខេបកិច្ចការជូនក្រុមប្រឹក្សានៅក្នុងកិច្ចប្រជុំឯកជនជារៀងរាល់ឆ្នាំ។

រហូតមកដល់បច្ចុប្បន្ននេះក្រុមប្រឹក្សាបានផ្តល់អនុសាសន៍ តែប៉ុណ្ណោះថារដ្ឋទាំងឡាយបញ្ជូនជម្លោះរបស់ពួកគេទៅឱ្យ ICJ ស្របតាមធម្មនុញ្ញអង្គការសហប្រជាជាតិ។ តួយ៉ាងនៅឆ្នាំ១៩៤៧ប្រទេសអាល់បានី និងចក្រភពអង់គ្លេសបានបញ្ជូនជម្លោះរបស់ពួកគេភ្លាមៗទៅកាន់តុលាការក្រោយពីទទួលបានការដំណោះស្រាយពីក្រុមប្រឹក្សា។ ដំណោះស្រាយនេះត្រូវបានអនុម័តដោយមានសម្លេងគាំទ្រចំនួន ៨ និងអនុប្បវាទចំនួនពីរគឺមកពីប្រទេសប៉ូឡូញនិងសហភាពសូវៀតខណៈដែលចក្រភពអង់គ្លេសដែលជា ភាគីនៃជម្លោះនេះបានបដិសេធមិនចូលរួមបោះឆ្នោតស្រប។ ដូចគ្នានេះដែរក្រុមប្រឹក្សាបានស្នើសុំយោបល់ប្រឹក្សាតែមួយគត់ពីតុលាការគឺ នៅថ្ងៃទី ២៩ ខែកក្កដាឆ្នាំ ១៩៧០ ក្នុងសេចក្តីសម្រេចលេខ២៨៤ គឺសុំយោបល់ផលប៉ះពាល់ផ្នែកច្បាប់ចំពោះរដ្ឋដែល

---

[9] មាត្រា ៣៦កថាខណ្ឌទី៣កំណត់ថា ក្នុងការផ្តល់អនុសាសន៍ក្រោមមាត្រានេះក្រុមប្រឹក្សាសន្តិសុខគួរពិចារណាផងដែរថាវិវាទតាមច្បាប់គួរតែជាវិធានទូទៅមួយដែលភាគីទាំងពីរត្រូវបញ្ជូនទៅតុលាការយុត្តិធម៌អន្តរជាតិស្របតាមបទប្បញ្ញត្តិនៃលក្ខន្តិកៈតុលាការ។

[10] មហាសន្និបាតឬក្រុមប្រឹក្សាសន្តិសុខអាចស្នើសុំតុលាការយុត្តិធម៌អន្តរជាតិផ្តល់យោបល់ប្រឹក្សាលើសំណួរផ្លូវច្បាប់ណាមួយ។

[11] ប្រសិនបើភាគីណាមួយនៃសំណុំរឿងបរាជ័យក្នុងការបំពេញកាតព្វកិច្ចដែលមានស្រាប់តាមសាលក្រមដែលផ្តល់ដោយតុលាការនោះភាគីម្ខាងទៀតអាចមានសិទ្ធិប្តឹងទៅក្រុមប្រឹក្សាសន្តិសុខដែលបើចាំបាច់យល់ស្របផ្តល់អនុសាសន៍ឬសម្រេចចិត្តលើវិធានការដែលត្រូវអនុវត្ត ដើម្បីផ្តល់ឥទ្ធិពលដល់សាលក្រម។

មានវត្តមានបន្តរបស់អាហ្វ្រិកខាងត្បូងនៅណាមីប៊ី។ ក្រុមប្រឹក្សាក៏បានធ្វើការប៉ុនប៉ងមួយដើម្បីអនុវត្តសិទ្ធិអំណាចនោះគឺ នៅពេលនីការ៉ាហ្កាបានស្នើសុំនៅក្នុងលិខិតមួយផ្ញើទៅប្រធានក្រុមប្រឹក្សានៅថ្ងៃទី ១៧ ខែតុលា ឆ្នាំ១៩៨៦ ឱ្យមានកិច្ចប្រជុំបន្ទាន់មួយដើម្បីពិចារណាអំពីការបរាជ័យរបស់អាមេរិកក្នុងការអនុវត្តសាលក្រមរបស់តុលាការអន្តរជាតិនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨៦ ប្រឆាំងនឹងសកម្មភាពយោធាករណីនីការ៉ាហ្កា។ សហរដ្ឋអាមេរិកបានបដិសេធមិនទទួលយកសេចក្តីព្រាង មួយដែលទាមទារឱ្យមានការអនុលោមតាមច្បាប់ពេញលេញ និងភ្លាមៗចំពោះសាលក្រមរបស់តុលាការយុត្តិធម៌អន្តរជាតិនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៦ ។

## ១.២ អង្គការមានសមត្ថកិច្ចដោយប្រយោល

ដូចដែលបានរៀបរាប់ខាងលើសិល្បៈ។ អង្គការសហប្រជាជាតិផ្តល់អំណាចដល់ GA តែមួយគត់ដើម្បីផ្តល់សិទ្ធិដល់អង្គការផ្សេងទៀត និង ទីភ្នាក់ងារជំនាញដើម្បីស្នើសុំយោបល់ពីតុលាការយុត្តិធម៌អន្តរជាតិ។ ការណ៍នេះបានធ្វើឱ្យមានចំណោទថាហេតុអ្វីបានជាមានការរឹតត្បិតដូចនេះ ?

ការដាក់កំហិតអាចមានភាពត្រឹមត្រូវដោយឈរលើមូលដ្ឋានដែល ធម្មនុញ្ញពិចារណាថាមហាសន្និបាតគឺជាអង្គការពេញអង្គរបស់អង្គការសហប្រជាជាតិហើយមានតំណែងពិសេស។ វាមានសមត្ថកិច្ចលើអង្គការផ្សេងទៀតដោយសារតែ ៖

(ក) មហាសន្និបាតជ្រើសរើសសមាជិកនៃអង្គការផ្សេងទៀត

(ខ) មហាសន្និបាតអនុម័តលើលិខិតបទដ្ឋាន និង សេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ និងទីភ្នាក់ងារជំនាញរបស់ខ្លួន

(គ) មហាសន្និបាតគ្រប់គ្រងថវិកា និង ពិនិត្យទិដ្ឋភាពរដ្ឋបាលរបស់អង្គការ

(ឃ)មហាសន្និបាតស្តាប់ និង ទទួលរបាយការណ៍ពីអង្គការនានា ផ្តល់នូវកិច្ចពិភាក្សា និង អនុសាសន៍ ដោយសារតែសិទ្ធិរបស់អង្គការសហប្រជាជាតិ និងទីភ្នាក់ងារឯកទេសដទៃទៀតក្នុងការស្នើសុំយោបល់គឺផ្អែកលើការអនុញ្ញាតពីមហាសន្និបាតនោះបង្កើតឱ្យមានចំណោទសំណួរ ថាតើមហាសន្និបាតអាចដកហូតការអនុញ្ញាតជាឯកតោភាគីនៅពេលណាក៏បានមែន ឬ មតិនេះត្រូវបានគេយកទៅជជែកដាក់ជូនគណៈកម្មាធិការទី៤ និងទី៦របស់មហាសន្និបាត។

គណៈកម្មការបញ្ជាក់ថាអាកប្បកិរិយាខាងលើមិនអាចទទួលយកបានដោយងាយទេហើយ គួរតែត្រូវបានពិនិត្យ។ពោលគឺ អនុញ្ញាតឱ្យមហាសន្និបាតដកហូតការអនុញ្ញាតរបស់ខ្លួននៅពេលណាដែលអង្គការនេយល់ថាសមស្រប រវាំងអង្គការ និង ទីភ្នាក់ងារអង្គការសហប្រជាជាតិក្នុងការសម្រេចគោលបំណងរបស់ពួកគេ។ លើសពីនេះការអនុញ្ញាតភាគច្រើនត្រូវបានបញ្ចូលក្នុងសន្ធិសញ្ញារវាងអង្គការសហប្រជាជាតិ និងទីភ្នាក់ងារឯក

ទោស។ ដូច្នេះការដកហូតការអនុញ្ញាតទាំងនេះអាចជាចាត់ទុកថាជាការកែប្រែឯកតោភាគីដោយមហាសន្និបាត គឺជា ការបំពានច្បាប់ បំពានកិច្ចព្រមព្រៀងរបស់អង្គការសហប្រជាជាតិ ការរំលោភលើកាតព្វកិច្ចសន្ធិសញ្ញា។

### ១.២.១ អង្គការសំខាន់ៗដទៃទៀតរបស់អង្គការសហប្រជាជាតិ

អនុលោមតាមមាត្រា៧(១) និង មាត្រា៩៦ (២) នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គម និង អគ្គលេខាធិការដ្ឋាន មានសមត្ថកិច្ចសុំយោបល់ពីតុលាការយុត្តិធម៌អន្តរជាតិ។

#### ១.២.១.១ ក្រុមប្រឹក្សាសេដ្ឋកិច្ច និង សង្គម

ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម គឺជាស្ថាប័នដំបូងដែលទាមទារការអនុញ្ញាតពីមហាសន្និបាតដើម្បីស្នើសុំយោបល់ពីតុលាការយុត្តិធម៌អន្តរជាតិ[12]។ តាមកិច្ចព្រមព្រៀងរបស់អង្គការទាំងពីរ ខែធ្នូ ឆ្នាំ១៩៤៦ បានអនុញ្ញាតឱ្យក្រុមប្រឹក្សាសន្តិសុខស្នើសុំយោបល់ពីតុលាការយុត្តិធម៌អន្តរជាតិ លើសំណួរផ្នែកច្បាប់ណាមួយនៅក្នុងវិសាលភាព ផ្នែកច្បាប់ទាក់ទងនឹងទំនាក់ទំនងទៅវិញទៅមករបស់អង្គការសហប្រជាជាតិនិងទីភ្នាក់ងារឯកទេស។ករណីមានការខ្វែងគំនិតគ្នាណាមួយទាក់ទងនឹងបញ្ហានេះគួរតែតុលាការសំរេចដោយផ្អែកលើសមត្ថភាពរបស់ខ្លួនដើម្បីកំណត់យុត្តាធិការរបស់ខ្លួន។ នៅក្នុងការអនុវត្តជាក់ស្តែង ECOSOC បានស្នើសុំយោបល់ពី ICJជាលើកដំបូងនៅ ឆ្នាំ១៩៨៩ ទាក់ទងនឹងការអនុវត្តច្បាប់ក្នុងជំពូកទី៦ ផ្នែកទី២២ នៃអនុសញ្ញាស្តីពីឯកសិទ្ធិ និងអភ័យឯកសិទ្ធិរបស់អង្គការសហប្រជាជាតិ។

#### ១.២.១.២ អគ្គលេខាធិការ

អនុលោមតាមមាត្រា៧ ធម្មនុញ្ញអង្គការសហប្រជាជាតិគឺ លេខាធិការដ្ឋានត្រូវបានចាត់ទុកថាជាអង្គការដ៏សំខាន់មួយរបស់អង្គការសហប្រជាជាតិ។ អគ្គលេខាធិការជាប្រធានរដ្ឋបាលនៃអង្គការនេះ។

អគ្គលេខាធិការបានផ្តល់យោបល់ដល់មហាសន្និបាតស្តីអំពីភាពចាំបាច់នៃការផ្តល់ជំនួយពី តុលាការមកកាន់ខ្លួន។ នៅដើមឆ្នាំ១៩៥០ នៅក្នុងអគ្គលេខាធិការរាយការណ៍ថាតើគណៈកម្មាធិការសិទ្ធិមនុស្សអាចទទួលបានការអនុញ្ញាតពីស្នើសុំយោបល់ពី ICJ អគ្គលេខាធិការបានសន្និដ្ឋានថានេះគណៈកម្មាធិការគ្មានសិទ្ធិក្រោមមាត្រា៩៦(២) ដើម្បីទទួលបានការអនុញ្ញាតបែបនេះពីព្រោះគណៈកម្មាធិការនេះមិនមែនជា អង្គការរបស់អង្គការសហប្រជាជាតិឬទីភ្នាក់ងារឯកទេសណាមួយឡើយ។ ដូច្នោះហើយទើបមានការចោទសួរអំពីសមត្ថកិច្ច

[12] អង្គការដទៃទៀតនៃអង្គការសហប្រជាជាតិនិងទីភ្នាក់ងារជំនាញដែលអាចត្រូវបានអនុញ្ញាតដោយមហាសន្និបាតនៅពេលណាមួយក៏អាចស្នើសុំយោបល់ពីតុលាការអំពីសំណួរផ្លូវច្បាប់ដែលកើតឡើងក្នុងវិសាលភាពនៃសកម្មភាពរបស់ពួកគេ។

ឆ្លងកាត់អគ្គលេខាធិការវិញ។ លុះក្រោយមកទើបមានសាលក្រមរបស់សាលាក្តីរដ្ឋបាល ដែលបញ្ជាក់ន័យសង្ខេបថា[13]៖

ខ្ញុំសូមផ្តល់អនុសាសន៍ថាអគ្គលេខាធិការត្រូវបាន អនុញ្ញាតស្របទៅតាមប្បញ្ញត្តិដែលមានចែងនៅមាត្រា៩៦(២) នៃធម្មនុញ្ញដើម្បីទាញយកផលប្រយោជន៍ពីសមត្ថភាពប្រឹក្សារបស់តុលាការប៉ុន្តែមិនទទួលយកការផ្តល់យោបល់ទាំងនេះរបស់អគ្គលេខាធិការព្រោះវាពុំមែនជាអង្គការនយោបាយ។ លើសពីនេះអគ្គលេខាធិការមិនមែនជា អង្គការដែលផ្តល់អំណាចដោយផ្ទាល់ដោយធម្មនុញ្ញទេ។ លើសពីនេះការបើកឱ្យអគ្គលេខាធិការស្នើសុំយោបល់ផ្តល់យោបល់អាចជួយដកចេញនូវភាពមិនច្បាស់លាស់ណាមួយអំពីមុខងារនៃការសម្រេចចិត្ត។

### ១.២.២ ភ្នាក់ងារពិសេស

យោងតាមធម្មនុញ្ញអង្គការសហប្រជាជាតិមានសិទ្ធិបង្កើតអង្គការបុត្រសម្ព័ន្ធ។ ចំពោះបញ្ហានេះសំណួរត្រូវបានចោទឡើងថាតើស្ថាប័នបុត្រសម្ព័ន្ធទាំងនោះមានសិទ្ធិទទួលបានការអនុញ្ញាតពីមហាសន្និបាតដើម្បី ស្នើសុំយោបល់ពី តុលាការយុត្តិធម៌អន្តរជាតិ ឬ ថាតើពួកគេអាចទទួលបានអំណាចនេះតែតាមរយៈការធ្វើប្រតិភូកម្មពីស្ថាប័នមេរបស់ពួកគេ។ មាត្រា៩៦ បញ្ជាក់ថាពុំមានទេនូវការ លើកឡើងអំពីលទ្ធភាពនៃការប្រគល់អំណាចនេះទៅឱ្យស្ថាប័នបុត្រសម្ព័ន្ធផងដែរ តែមិនបញ្ជាក់ពីអំណាចហាមមិនឱ្យមានដែរ។ ក្រុមអ្នកច្បាប់ទទូចឱ្យអង្គការសហប្រជាជាតិគួរតែត្រូវបានអនុញ្ញាតឱ្យអង្គការបុត្រសម្ព័ន្ធធ្វើការស្នើសុំយោបល់។

ក្រៅពីអង្គការបុត្រសម្ព័ន្ធទីភ្នាក់ងារពិសេសដែលមានទំនាក់ទំនងនឹងអង្គការសហប្រជជាតិគឺ មានសិទ្ធិស្នើសុំយោបល់ពីតុលាការយុត្តិធម៌អន្តរជាតិ បន្ទាប់ពីទទួលបានការអនុញ្ញាតពីមហាសន្និបាត។ ទីភ្នាក់ងារជំនាញភាគច្រើនមានអំណាចដើម្បីស្នើសុំយោបល់ពីតុលាការលើសំណួរផ្លូវច្បាប់ណាមួយដែលកើតឡើងក្នុងវិសាលភាពនៃសកម្មភាពរបស់ពួកគេ ក៏ដូចជាអត្ថបទពាក់ព័ន្ធនៅក្នុងរដ្ឋធម្មនុញ្ញរបស់ខ្លួនបន្ថែមលើមាត្រាពាក់ព័ន្ធនៅក្នុងកិច្ចព្រមព្រៀងរវាងទីភ្នាក់ងារនេះ និងអង្គការសហប្រជាជាតិ។

## ២. លក្ខខណ្ឌក្នុងការស្នើសុំយោបល់

### ២.១ ដែនសិទ្ធិនៃការស្នើសុំរបស់អង្គការ

តុលាការយុត្តិធម៌អន្តរជាតិគឺជា ស្ថាប័នមានសមត្ថកិច្ចដើម្បីសម្រេចថាតើអង្គការដែលស្នើសុំមានសិទ្ធិស្នើសុំ ឬទេ។ ក្នុងន័យនេះបញ្ហាមួយចំនួនដែលទាក់ទងទៅនឹងសមត្ថភាពរបស់អង្គការស្នើសុំគួរតែត្រូវបានដោះស្រាយ។ បញ្ហាទាំងនោះរួមមាន៖

[13] Judicial Review of UNAT’s Judgments, working paper submitted by the SecretaryGeneral. See UN Doc. A/AC. 78/L.l and Corr. 1 (1955).

ដែនកំណត់នៃសមត្ថភាពក៏ដូចជាឥទ្ធិពល នៃការស្នើសុំរបស់អង្គការមួយទៅលើសមត្ថភាពនៃអង្គការដទៃទៀតឥទ្ធិពលនៃការបដិសេធចំពោះការស្នើសុំរបស់អង្គការមួយទៅលើសមត្ថភាពរបស់អង្គការ ដទៃទៀតដើម្បីកំណត់វិសាលភាពនៃសកម្មភាព ឬ តំបន់ដែលមានសមត្ថកិច្ចតុលាការត្រូវពិនិត្យលើវិធានពាក់ព័ន្ធរបស់អង្គការជាពិសេសរដ្ឋធម្មនុញ្ញរបស់ខ្លួនដែលគោលបំណង និងមុខងាររបស់អង្គការត្រូវបានចងក្រងឡើង នៅក្នុងការអនុវត្តជាក់ស្តែងតុលាការបានបដិសេធសំណើសុំយោបល់ពី អង្គការសុខភាពពិភពលោកអំពីភាពស្របច្បាប់នៃការប្រើប្រាស់អាវុធនុយក្លេអ៊ែរនៅក្នុងករណីជម្លោះប្រដាប់អាវុធពីព្រោះតុលាការបានរកឃើញថាមុខងាររបស់WHO មិនមានទំនាក់ទំនងគ្រប់គ្រាន់ជាមួយសំណួរដែលមិនស្ថិតក្នុងវិសាលភាព សកម្មភាពរបស់ WHO ដូចដែលបានកំណត់ដោយរដ្ឋធម្មនុញ្ញរបស់ខ្លួន។

បន្ថែមពីលើដែនកំណត់នេះវាត្រូវបានគេកត់សម្គាល់ថាមហាសន្និបាតជាអង្គការដែលមានអំណាចផ្តល់សិទ្ធិអំណាចដល់អង្គការ និង ទីភ្នាក់ងារដទៃទៀតមានអំណាចបង្កប់នូវលក្ខខណ្ឌបន្ថែមពីរទៀតគឺទីមួយអង្គការ និងទីភ្នាក់ងារទាំងនេះគួរតែជូនដំណឹងដល់ក្រុមប្រឹក្សាសង្គមនិងសេដ្ឋកិច្ចនៅពេលពួកគេស្នើសុំយោបល់ពីតុលាការ។

ទីពីរស្ថាប័ន និងទីភ្នាក់ងារទាំងនេះមិនអាចស្នើសុំយោបល់ពីតុលាការទាក់ទងនឹងទំនាក់ទំនងរបស់ពួកគេជាមួយអង្គការសហប្រជាជាតិ ឬជាមួយទីភ្នាក់ងារដទៃទៀតទេពីព្រោះសំណើបែបនេះអាចត្រូវបានធ្វើឡើងដោយក្រុមប្រឹក្សាសេដ្ឋកិច្ច និង សង្គម តែប៉ុណ្ណោះដែលមានមុខងារសម្របសម្រួលសកម្មភាពរបស់ទីភ្នាក់ងារឯកទេស។

## ២.២ ការបោះឆ្នោត និង ប្រធានបញ្ហានៃសំណើ

គ្មានសំណើណាមួយអាចធ្វើទៅតុលាការដើម្បីសុំយោបល់បានទេលុះត្រាតែ ការសម្រេចចិត្តធ្វើសំណើបែបនេះត្រូវបានធ្វើឡើងដោយមតិភាគច្រើននៅក្នុងអង្គភាពពាក់ព័ន្ធ។ នីតិវិធីនៃការបោះឆ្នោតដែលអង្គការ ឬទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិអាចស្នើសុំមតិយោបល់មិនត្រូវបានបញ្ជាក់ដោយច្បាស់លាស់នៅក្នុងធម្មនុញ្ញឬនៅក្នុងលក្ខន្តិកៈរបស់តុលាការឡើយ។ ដូច្នេះនីតិវិធីនៃការបោះឆ្នោតសម្រាប់ការស្នើសុំមតិរបស់តុលាការត្រូវតែកំណត់ដោយអនុលោមតាមវិធានទូទៅនៃការបោះឆ្នោតរបស់ស្ថាប័ន ឬទីភ្នាក់ងារទាំងនោះ។

ឧទាហរណ៍៖ ទាក់ទងនឹងមហាសន្និបាតនីតិវិធីនៃការបោះឆ្នោតត្រូវបានកំណត់ដោយមាត្រា ១៨ នៃធម្មនុញ្ញ និងថាតើបញ្ហាចោទជាប្រភេទអ្វី

- បើជាបញ្ហាសំខាន់ គឺអនុលោមតាមមតិភាគច្រើន២ភាគ៣ដូចជាបញ្ហា សន្តិភាព សន្តិសុខ ថវិកាការព្យួរ ការបណ្តេញសមាជិកជាអាទិ៍

- បើជាបញ្ហាធម្មតាគឺ អនុលោមតាមមតិភាគច្រើនដាច់ខាត៥០%បូក១សំឡេង អនុលោមតាមមាត្រា៩៦ នៃធម្មនុញ្ញ រួមនឹងមាត្រា៦៥ នៃលក្ខន្តិកៈអង្គការមានតែសំនួរផ្នែកច្បាប់ដែល អាចស្វែងរកការផ្តល់យោបល់។ ក្រុមអ្នកច្បាប់ចាត់ទុកថា សំណួរផ្នែកច្បាប់មួយប្រយោគនេះ មានលក្ខណៈទូលំទូលាយល្មមដើម្បីរួមបញ្ចូលបញ្ហាផ្លូវច្បាប់នៅក្នុងជម្លោះនៅមុខអង្គការ។

## ២.៣ បែបបទក្នុងការរៀបចំសំណើសុំយោបល់

ដំណើរការប្រឹក្សាយោបល់ចាប់ផ្តើមដោយការដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរសម្រាប់មតិប្រឹក្សាដែលបានផ្ញើទៅអគ្រានុកូលដ្ឋានដោយអគ្គលេខាធិការអង្គការសហប្រជាជាតិឬនាយក ឬអគ្គលេខាធិការអង្គភាពដែលស្នើសុំយោបល់។ ក្នុងករណីបន្ទាន់តុលាការអាចចាត់វិធានការសមស្របទាំងអស់ដើម្បីពន្លឿនដំណើរការនីតិវិធី។ ដើម្បីប្រមូលព័ត៌មានចាំបាច់ទាំងអស់អំពីសំណួរដែលបានដាក់ជូនតុលាការត្រូវបានផ្តល់អំណាចឱ្យដំណើរការនីតិវិធីជាលាយលក្ខណ៍អក្សរនិងផ្ទាល់មាត់។

ពីរបីថ្ងៃបន្ទាប់ពីការស្នើសុំត្រូវបានដាក់ជូនតុលាការបានរៀបចំបញ្ជីឈ្មោះរដ្ឋ និងអង្គការអន្តរជាតិដែលទំនងជាអាចផ្តល់ព័ត៌មានអំពីសំណួរនេះនៅចំពោះមុខតុលាការ។ ជាធម្មតារដ្ឋដែលបានចុះបញ្ជីគឺជា រដ្ឋជាសមាជិកនៃអង្គការដែលស្នើសុំយោបល់ខណៈពេលដែលពេលខ្លះរដ្ឋផ្សេងទៀតដែលតុលាការបើកចំហ នៅក្នុងដំណើរការវិវាទដែលត្រូវបានរួមបញ្ចូលផងដែរ។ តាមក្បួនអង្គការ និងរដ្ឋដែលមានសិទ្ធិចូលរួមក្នុងដំណើរការជំនុំជម្រះអាចបញ្ជូនសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរតាមក្រោយប្រសិនបើតុលាការយល់ឃើញថាចាំបាច់ដោយការសរសេរជា លាយលក្ខណ៍អក្សរលើសេចក្តីថ្លែងការណ៍របស់អ្នកដទៃ។ សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរទាំងនេះជាទូទៅត្រូវបានបង្ហាញជា សាធារណៈនៅដើមដំបូងនៃដំណើរការសវនាការផ្ទាល់មាត់ប្រសិនបើតុលាការពិចារណាថាដំណើរការនីតិវិធីបែបនេះគួរតែប្រព្រឹត្តទៅ។

# ផ្នែកទី២៖ យុត្តាធិការតុលាការព្រហ្មទណ្ឌអន្តរជាតិ

## កថាខណ្ឌទី១៖ យុត្តាធិការលើកម្មវត្ថុនៃវិវាទ(Subject-matter Jurisdiction)

យុត្តាធិការលើកម្មវត្ថុនៃវិវាទរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិគឺ មានន័យជាការកំណត់ប្រភេទនៃបទល្មើសព្រហ្មទណ្ឌដែលបុគ្គលអាចត្រូវបានផ្តន្ទាទោសចំពោះបទល្មើព្រហ្មទណ្ឌទាំងឡាយណាខ្លួនបាន ប្រព្រឹត្តិដូចដែលមានចែងក្នុងលក្ខន្តិកៈទីក្រុងរ៉ូម។ ដោយយុត្តាធិការតុលាការត្រូវបានកំរិតដែនកំណត់ចំពោះបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរបំផុតដែលធ្វើឱ្យមានការព្រួយបារម្ភដល់សហគមងន្តរជាតិទាំងមូល។ មែនទែនទៅតុលាការព្រហ្មទណ្ឌអន្តរជាតិគឺ មានយុត្តាធិការអនុលោមតាមច្បាប់លក្ខន្តិកៈក្រុងរ៉ូមនេះចំពោះរាល់បទល្មើសព្រហ្មទណ្ឌទាំងឡាយណាដូចដែលមានបញ្ញតិនៅក្នុងមាត្រា៥ នៃលក្ខន្តិកៈដូចជា៖ បទល្មើសព្រហ្មទណ្ឌប្រល័យពូជ

សាសន៍ បទល្មើសព្រហ្មទណ្ឌប្រឆាំងនឹងមនុស្សជាតិ បទល្មើសព្រហ្មទណ្ឌសង្គ្រាម និងបទល្មើសព្រហ្មទណ្ឌនៃការការឈ្លានពាន។ លើសពីនេះមាត្រា៧០ កំណត់ពីបទល្មើសប្រឆាំងនឹងរដ្ឋបាលយុត្តិធម៌ដែលជាប្រភេទឧក្រិដ្ឋកម្មប្រភេទទី៥ ដែលបុគ្គលជាអ្នកប្រព្រឹត្តអាចត្រូវបានផ្តន្ទាទោស។[14][15]

## ១.ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

ដោយអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈក្រុងរ៉ូមបានផ្តល់និយមន័យពាក្យ "ប្រល័យពូជសាសន៍" មានន័យថា អំពើណាមួយដូចខាងក្រោមនេះ ដែលបានប្រព្រឹត្តឡើងដោយមានចេតនាបំផ្លិចបំផ្លាញ ទោះបីទាំងមូលក្តី ឬផ្នែកខ្លះក្តី នូវក្រុមជាតិសាសន៍ ក្រុមជាតិពន្ធ ក្រុមពូជសាសន៍ ឬក្រុមសាសនាជាអាទិ៍[16]៖

ក. ការសម្លាប់សមាជិកទាំងឡាយនៃក្រុមនោះ

ខ. ការបង្ករអោយមានការរងគ្រោះថ្នាក់ដល់រូបកាយ ឬ ដល់បញ្ញាស្មារតីយ៉ាធ្ងន់ធ្ងរចំពោះសមាជិកទាំងឡាយនៃក្រុមនោះ

គ. ការដាក់ដោយផ្ចិតផ្ចង់នូវលក្ខខ័ណ្ឌជីវិតដល់ក្រុមនោះ ក្នុងកម្រិតមួយដែលប្រុងនឹងនាំដល់ ការបំផ្លិចបំផ្លាញជាក់ស្តែងនូវក្រុមនោះ ទោះបីទាំងមូលក្តី ឬ ផ្នែកខ្លះក្តី

ឃ. ការដាក់ចេញវិធានការដោយមានចេតនាទប់ស្កាត់ការចាប់កំណើតនៅក្នុងក្រុមនោះ

ង. ការផ្លាស់ទីកុមារពីក្រុមមួយទៅក្រុមមួយទៀតដោយបង្ខិតបង្ខំ។

ទាក់ទងនឹងការផ្តល់និយមន័យនៃឧក្រិដ្ឋកម្មនៃច្បាប់ស្តីពីលក្ខខន្តិកៈក្រុងរ៉ូមនេះគឺ វាដូចគ្នាទៅនឹងអ្វីដែលមានចែងនៅក្នុងអនុសញ្ញាស្តីពីការការពារ និងការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឆ្នាំ១៩៤៨។ ជាឧទាហរណ៍នៅក្នុងសំណុំរឿង Akayesu តុលាការបានសន្និដ្ឋានថារាល់ការញុះញង់ឱ្យអ្នកដទៃទៀតប្រព្រឹត្តដោយផ្ទាល់ និងជាសាធារណៈដើម្បីប្រព្រឹត្តអំពើប្រល័យពូជសាសន៍គឺជាការបង្កើតឧក្រិដ្ឋកម្មមួយផងដែរ។

## ២.ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

បទល្មើប្រឆាំងមនុស្សជាតិ មានន័យថា អំពើណាមួយដែលបានប្រព្រឹត្តឡើងជាផ្នែកមួយនៃការវាយប្រហារដ៏សុះសាយ ឬ ដែលមានលក្ខណៈជាប្រព័ន្ធមួយ ដោយផ្ទាល់ប្រឆាំងនឹងប្រជាពលរដ្ឋស៊ីវិលណាម្នាក់ដែលស្របតាម ឬស្ថិតក្នុងការធ្វើឱ្យជឿនលឿនទៅមុខរបស់រដ្ឋមួយ ឬគោលនយោបាយចាត់តាំងដើម្បីប្រព្រឹត្តការវាយប្រហារបែបនោះ ហើយដោយមានការដឹងពីការវាយប្រហារនោះដូចជា[17]៖

---

[14] មាត្រា៥៖ អំពីបទល្មើព្រហ្មទណ្ឌស្ថិតក្នុងយុត្តាធិការតុលាការ

[15] មាត្រា៧០៖ អំពីបទល្មើសប្រឆាំងនឹងរដ្ឋបាលយុត្តិធម៌

[16] មាត្រា៦៖ អំពីការប្រល័យពូជសាសន៍

[17] មាត្រា៧៖ អំពីបទល្មើសព្រហ្មទណ្ឌប្រឆាំងមនុស្សជាតិ

ក. "ឃាតកម្ម" ជាការរៀបគម្រោងសម្លាប់ពលរដ្ឋស៊ីវិលដែលប្រឆាំងនឹងគោលនយោបាយដឹកនាំរបស់ខ្លួន។

ខ. "ការធ្វើឱ្យសាបសូន្យ" ដែលក្នុងនោះរួមបញ្ចូល ទាំងការដាក់លក្ខខណ្ឌលើជីវិតដោយចេតនា ដែលក្នុងចំណោមនោះមានការដកហូតសិទ្ធិទទួលបានអាហារ និងថ្នាំពេទ្យក្នុងកម្រិតមួយដែលប្រុងនឹងនាំដល់មានការបំផ្លិចបំផ្លាញផ្នែកមួយនៃប្រជាពលរដ្ឋ។

គ. "ការដាក់មនុស្សឱ្យធ្វើជាទាសករ" ជាការប្រើអំណាចណាមួយ ឬអំណាចទាំងអស់ដែលមានជាប់នឹងសិទ្ធិកម្មសិទ្ធិទៅលើជនម្នាក់ និងរួមទាំងការប្រើសិទ្ធិក្នុងដំណើរការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ។

ឃ. "ការនិរទេស ឬ ការផ្លាស់ទីប្រជាពលរដ្ឋដោយបង្ខិតបង្ខំ"គឺជា ការផ្លាស់ទីកន្លែងរបស់ជនដែលពាក់ព័ន្ធដោយបង្ខំដោយការបណ្តេញ ឬ ដោយអំពើបង្ខិតបង្ខំផ្សេងទៀត ចេញពីតំបន់ដែលពួកគេមានវត្តមាននៅដោយស្របច្បាប់ ដោយគ្មានមូលដ្ឋានដូចបានអនុញ្ញាតក្នុងច្បាប់អន្តរជាតិ។

ង. ការដាក់ពន្ធធនាគារ ឬ ការដកហូតសេរីភាពខាងរូបកាយដែលជា ការបំពានលើវិធានជាមូលដ្ឋាននៃច្បាប់អន្តរជាតិ។

ច. "ការធ្វើទារុណកម្ម" គឺជា ការធ្វើឱ្យមានការចុកចាប់ ឬ ការរងគ្រោះជាទម្ងន់ដោយចេតនា ទោះជាដល់រូបកាយក្តី ឬដល់បញ្ញាស្មារតីក្តី ទៅលើជនដែលនៅក្នុងការឃុំឃាំង ឬ ក្រោមការត្រួតត្រាដែលកើតចេញតែពីការដាក់ទណ្ឌកម្មស្របច្បាប់ដែលមានជាប់នឹងអំពើនោះ ឬ ដែលមានជាយថាហេតុទេ។

ឆ. ការចាប់រំលោភ ទាសកម្មផ្លូវភេទ ពេស្យាកម្មដោយការដាក់បង្ខំ ការមានគភ៌ដោយបង្ខំវណ្ណកម្មដោយដាក់បង្ខំ ឬការបំពានផ្លូវភេទក្នុងទ្រង់ទ្រាយផ្សេងទៀតដែលមានការធ្ងន់ធ្ងរប្រហែលគ្នានេះ។ ដោយការមានគភ៌ដោយបង្ខំ ត្រង់នេះមានន័យថា ការបង្ខាំងដោយខុសច្បាប់នូវស្ត្រីដែលត្រូវធ្វើឱ្យមានគភ៌ ដោយបង្ខំដោយមានចេតនាចង់ឱ្យមានការប៉ះពាល់ដល់សមាសភាពជាតិពន្ធនៃពលរដ្ឋណាមួយ ឬ ការអនុវត្តន៍ការបំពានដ៏ធ្ងន់ធ្ងរ ដទៃទៀតលើច្បាប់អន្តរជាតិ។

ជ. ការធ្វើទុក្ខបុកម្នេញលើក្រុម ឬលើសមូហភាពជាក់លាក់ណាមួយ លើមូលដ្ឋាននយោបាយ ពូជសាសន៍ជាតិសាសន៍ ជាតិពន្ធ វប្បធម៌ សាសនា យែនឌ័រ។ មែនទែនទៅការធ្វើទុក្ខបុកម្នេញ គឺមានន័យថា ជាការដកហូតសិទ្ធិជាមូលដ្ឋានដោយចេតនា និងយ៉ាងធ្ងន់ធ្ងរដែលផ្ទុយនឹងច្បាប់អន្តរជាតិ ដោយមូលហេតុនៃអត្តសញ្ញាណនៃក្រុម ឬសមូហភាព។

ឈ."ការបាត់ខ្លួនមនុស្សដោយដាក់បង្ខំ" សំដៅដល់ការចាប់ខ្លួន ការឃុំឃាំង ឬការចាប់ពង្រត់មនុស្សដោយមានការអនុញ្ញាត ការគាំទ្រ ឬការយល់ព្រមរបស់រដ្ឋ ឬអង្គការនយោបាយ បន្ទាប់មកមានការបដិសេធ មិនទទួល

ដឹងឮពីការដកហូតសេរីភាពនោះ ឬមិនផ្តល់ព័ត៌មានអំពីជោគវាសនា ឬទីសំចតនៃជនទាំងនោះដោយមានចេតនាដកពួកគេចេញពីការការពារតាមផ្លូវច្បាប់ក្នុងរយៈពេលពន្យាយូរមួយ។

ញ. "បទល្មើសប្រល័យពូជសាសន៍អាប៉ាថេដ" មានន័យថា អំពើអមនុស្សធម៌ដែលមានចរិតលក្ខណៈស្រដៀងគ្នាទៅនឹងអំពើទាំងឡាយណាដែលបញ្ញត្តិនៅក្នុងកថាខណ្ឌទី១ ដែលបានប្រព្រឹត្តក្នុងបរិបទនៃរបបគ្រប់គ្រងជា ស្ថាប័ននៃការសង្កត់សង្កិតជាលក្ខណៈប្រព័ន្ធ និង ការគ្របសង្កត់របស់ក្រុមពូជសាសន៍មួយទៅលើក្រុមពូជសាសន៍មួយ ឬច្រើនដទៃទៀត ហើយដែលបានប្រព្រឹត្តក្នុងចេតនារក្សាទុករបបនោះ។

ដ. អំពើអមនុស្សធម៌ដែលមានលក្ខណៈជា អន្តរជាតិស្រដៀងគ្នាដទៃទៀត ដែលមានចេតនាបង្កឱ្យមានការរងគ្រោះដ៏ធំធេង ឬគ្រោះថ្នាក់ធ្ងន់ធ្ងរដល់រូបកាយ ឬដល់សុខភាពខាងបញ្ញាស្មារតី ឬសុខភាពខាងរូបកាយ។

## ៣. ឧក្រិដ្ឋកម្មសង្គ្រាម

មែនទែនទៅនៅក្នុងមាត្រា៨ នៃច្បាប់ស្តីពីលក្ខន្តិកៈក្រុងរ៉ូម បានធ្វើការកំណត់ឧក្រិដ្ឋកម្មសង្គ្រាមអាស្រ័យទៅលើថាតើជម្លោះប្រដាប់អាវុធជាលក្ខណៈអន្តរជាតិ (ដែលជាទូទៅមានន័យថាការប្រយុទ្ធគ្នារវាងរដ្ឋ) ឬមិនមែនជាអន្តរជាតិ (ដែលជាទូទៅមានន័យថាវាត្រូវបានប្រយុទ្ធគ្នារវាងតួអង្គមិនមែនរដ្ឋដូចជាក្រុមឧទ្ទាម ឬក៏រវាងរដ្ឋ និងតួអង្គមិនមែនរដ្ឋ)។ ជាការពិតណាស់ថាតុលាការព្រហ្មទណ្ឌអន្តរជា ត្រូវមានយុត្តាធិការលើបទល្មើសព្រហ្មទណ្ឌសង្គ្រាម ជាពិសេសនៅពេលដែលអំពើនោះបានប្រព្រឹត្តឡើងជា ផ្នែកមួយនៃផែនការឬនយោបាយ ឬជាផ្នែកមួយនៃការប្រព្រឹត្តក្នុងទំហំដ៏ធំធេញនៃបទល្មើសព្រហ្មទណ្ឌបែបនេះ[18]។

សរុបទៅមានឧក្រិដ្ឋកម្មសង្គ្រាមចំនួន៧៤ ដែលមានចែងក្នុងមាត្រា៨ នៃច្បាប់ស្តីពីលក្ខន្តិកៈក្រុងរ៉ូមតែទោះយ៉ាងណាក៏ដោយឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតគឺ ឧក្រិដ្ឋកម្មដែលជាការបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងសឺណែវ ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ អំពីការប្រឆាំងនឹងមនុស្ស ឬទ្រព្យសម្បត្តិដែលត្រូវការពារតាមបទបញ្ញត្តិទាំងឡាយនៃអនុសញ្ញាទីក្រុងសឺណែវដែលទាក់ទងទៅនឹងការអនុវត្តចំពោះតែជម្លោះអន្តរជាតិ ហើយបង្កើតជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងអាចអនុវត្តចំពោះតែជម្លោះប្រដាប់អាវុធអន្តរជាតិប៉ុណ្ណោះ៖

- ការសម្លាប់ដោយឆន្ទៈ
- ទារុណកម្ម ឬការប្រព្រឹត្តអំពើអមនុស្សធម៌ រួមទាំងការពិសោធជីវសាស្ត្រ
- ការបង្កការរងគ្រោះយ៉ាងធ្ងន់ធ្ងរ ឬគ្រោះថ្នាក់ដល់រូបការ ឬសុខភាពយ៉ាងធ្ងន់ធ្ងរដោយឆន្ទៈ

[18] មាត្រា៨៖ អំពីបទល្មើសព្រហ្មទណ្ឌសង្គ្រាម

- ការបំផ្លិចបំផ្លាញ និងការដកហូតយកទ្រព្យសម្បត្តិដ៏ធំធេញដែលមិនមែនធ្វើឡើយដោយមកពីមានមូលេហេតុនៃភាពចាំបាច់ខាងយោធា និងធ្វើឡើងដោយខុសច្បាប់ និងដោយព្រៃផ្សៃ
- ការបង្ខំអ្នកទោសឈ្លើយសង្គ្រាម ឬជនដែលត្រូវការពារដទៃទៀតឱ្យបំរើការក្នុងកងកម្លាំងរបស់សត្រូវ
- ការដកហូតសិទ្ធិរបស់អ្នកទោសឈ្លើយសង្គ្រាម និងជនដែលត្រូវការពារដទៃទៀតដោយឆន្ទៈ ពីការជំនុំជម្រះទោសត្រឹមត្រូវ និងតាមប្រក្រតី
- ការនិរទេសដោយខុសច្បាប់ ឬការបញ្ជូនផ្លាស់ទីដោយខុសច្បាប់ ឬការបង្ខាំងមនុសសដោយខុសច្បាប់
- ការចាប់មនុស្សធ្វើជាចំណាប់ខ្មាំង។

ដោយឡែកការបំពានលើច្បាប់ និងទំនៀមទម្លាប់ដ៏ធ្ងន់ធ្ងរដទៃទៀត ដែលអាចអនុវត្តបាននៅក្នុងជម្លោះប្រដាប់អាវុធជាលក្ខណៈអន្តរជាតិ នៅក្នុងគម្រោងដែលបានបង្កើតឡើងតាមច្បាប់អន្តរជាតិនូវអំពើណាមួយដូចខាងក្រោម៖

- ការដឹកនាំដោយចេតនានូវការវាយប្រហារប្រឆាំងនឹងពលរដ្ឋស៊ីវិល ឬប្រឆាំងនឹងឯកត្តជនស៊ីវិលដែលមិនចូលរួមដោយផ្ទាល់នៅក្នុងការប្រទូសរាគ្នានោះទេ។
- ការដឹកនាំដោយចេតនានូវការវាយប្រហារប្រឆាំងនឹងវត្ថុស៊ីវិល ដែលនោះជាវត្ថុដែលមិនមែនជាចំណុចគោលដៅខាងយោធាទេ។
- ការដឹកនាំដោយចេតនានូវការវាយប្រហារប្រឆាំងនឹង មន្ត្រីប៉ុស្ដិ៍ទីតាំង សម្ភារៈ អង្គភាព ឬយានជំនិះពាក់ព័ន្ធនឹងជំនួយមនុស្សធម៌ ឬបេសកកម្មរក្សាសន្តិភាព អនុលោមតាមធម្មនុញ្ញនៃអង្គការសហប្រជាជាតិ ដរាបណាពួកគេមានសិទ្ធិចំពោះការការពារដែលផ្តល់ឱ្យដល់ជនស៊ីវិល ឬដល់វត្ថុស៊ីវិលតាមច្បាប់អន្តរជាតិស្តីពីជម្លោះប្រដាប់អាវុធ។
- ការបើការការវាយប្រហារដោយចេតនា ដោយដឹងថាការវាយប្រហារនឹងបង្កឱ្យបាត់បង់អាយុជីវិត ឬគ្រោះថ្នាក់ដល់ជនស៊ីវិល ឬធ្វើឱ្យខូចខាតវត្ថុស៊ីវិលជាយថាហេតុ ឬការខូចខាតដ៏សុះសាយរយៈពេលវែងឆ្ងាយ និងដ៏ធំធេញចំពោះបរិស្ថានធម្មជាតិដែលពិតជាមានលក្ខណៈហួសហេតុក្នុងទំនាក់ទំនងទៅនឹងប្រយោជន៍យោធាទាំងមូលដោយផ្ទាល់ និងដោយច្បាប់លាស់។
- ការវាយប្រហារ ឬការទម្លាក់គ្រាប់បែកតាមមធ្យោបាយណាក៏ដោយ ទៅលើទីក្រុង ភូមិ លំនៅដ្ឋាន ឬអាគារ ដែលមិនត្រូវបានការពារ និងដែលមិនមែនជាចំណុចគោលដៅយោធា។
- ការសម្លាប់ ឬការធ្វើឱ្យរបួសដល់យុទ្ធជនដែលបានទម្លាក់អាវុធរបស់ខ្លួនចុះ ឬជនដែលគ្មានមធ្យោបាយការពារខ្លួនតទៅទៀត ដែលបានចុះចាញ់ព្រមតាមខ្លួន។

- ធ្វើការប្រើប្រាស់មិនសមស្របនូវទង់ផ្អាកសង្គ្រាម ទង់ជាតិ សញ្ញាសម្គាល់យោធា និងឯកសណ្ឋានសត្រូវ ឬឯកសណ្ឋានរបស់អង្គការសហប្រជាជាតិ ក៏ដូចជានិមិត្តសញ្ញាដោយឡែកៗនៃអនុសញ្ញាទីក្រុងសឺណែវ ដែលបណ្តាលឱ្យមានការស្លាប់ ឬគ្រោះថ្នាក់ដល់មនុស្សយ៉ាងធ្ងន់ធ្ងរ។
- ការបញ្ជូនផ្លាស់ទីកន្លែងដោយផ្ទាល់ ឬដោយប្រយោល នូវកម្លាំងដែលកំពុងកាន់កាប់ផ្នែកខ្លះនៃពលរដ្ឋស៊ីវិលរបស់ខ្លួនផ្ទាល់ ចូលទៅក្នុងទឹកដីដែលខ្លួនចូលកាន់កាប់ ឬការនិរទេស ឬការបញ្ជូនផ្លាស់ទីពលរដ្ឋខ្លះ ឬទាំងអស់នៃទឹកដីដែលបានចូលកាន់កាប់ទៅក្នុងទឹកដីនោះ ឬចេញក្រៅទឹកដីនោះ។
- ការដឹកនាំដោយចេតនានូវការវាយប្រហារប្រឆាំងនឹងអាគារ ដែលបានសង់ឡើយសម្រាប់គោលបំណងសាសនា ការអប់រំ សិល្បៈ វិទ្យាសាស្ត្រ ឬគោលបំណងសប្បុរធម៌ វិមានប្រវត្តិសាស្ត្រ មន្ទីរពេទ្យ និងទីកន្លែនទាំងឡាយដែលអ្នកជម្ងឺ និងអ្នករងរបួសប្រមូលផ្តុំ ដោយកន្លែងទាំងនេះមិនមែនជាចំណុចគោលដៅយោធាទេ។
- ការដាក់ជនទាំងឡាយដែលស្ថិតនៅក្នុងអំណាចរបស់គូបដិបក្សឱ្យរងការធ្វើកាយវិកលកម្ម ឬការពិសោធន៍ខាងវេជ្ជសាស្ត្រ ឬខាងវិទ្យាសាស្ត្រប្រភេទណាមួយ ដែលមិនធ្វើយុត្តិកម្មដោយការព្យាបាលខាងវេជ្ជសាស្ត្រ ទន្តសាស្ត្រ ឬការដេកពេទ្យ ដល់ជនពាក់ព័ន្ធនោះទេ ឬដែលមិនធ្វើឡើងដើម្បីជាប្រយោជន៍របស់ជននោះ និងដែលបណ្តាឱ្យជននោះស្លាប់ ឬធ្វើឱ្យជននោះរងគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរដល់សុខភាព។
- ការសម្លាប់ ឬការធ្វើឱ្យរបួសដោយចិត្តក្បត់ដល់ជនទាំងឡាយដែលជាមនុស្សរបស់ប្រទេស ឬរបស់យោធាបច្ចាមិត្ត។
- ការប្រកាសថានឹងមិនផ្តល់ការត្រាប្រណីណាមួយឡើយ។
- ការបំផ្លាញ ឬការរឹបអូសយកទ្រព្យសម្បត្តិរបស់សត្រូវ លើកលែងតែការបំផ្លាញនោះ ឬការរឹបអូសយកនោះត្រូវទាមទារបញ្ជាឱ្យធ្វើដោយសារភាពចាំបាច់នៃសង្គ្រាម។
- ការប្រកាសលុបចោល ពន្យា ឬមិនទទួលយកនៅក្នុងតុលាការនៃច្បាប់ (Court of Law) នូវសិទ្ធិ និងសកម្មភាពទាំងឡាយរបស់ពលរដ្ឋនៃភាគីបច្ចាមិត្ត។
- ការបង្ខំឱ្យពលរដ្ឋនៃភាគីបច្ចាមិត្តចូលរួមក្នុងប្រតិបត្តិការសឹកសង្គ្រាមដឹកនោះធ្វើឡើងប្រឆាំងនឹងប្រទេសរបស់ពួកគេផ្ទាល់ ទោះបីជាពួកគាបានបំរើការប្រទូសរាយមុនការចាប់ផ្តើមសង្គ្រាមក៏ដោយ។
- ការចូលលួចប្លន់ទីក្រុង ឬទីកន្លែងណាមួយទោះបីធ្វើឡើងដោយការវាយតប់ក៏ដោយ។
- ការប្រើប្រាស់ជាតិពុល ឬអាវុធជាតិពុល។

- ការប្រើប្រាស់ឧស្ម័នស្ទះដង្ហើម ឧស្ម័នពុល ឬឧស្ម័នដទៃទៀត និងថ្នាំទឹក ឧបករណ៍ ឬគ្រឿងស្រដៀងគ្នានេះដទៃទៀត។
- ការប្រើប្រាស់គ្រាប់កាំភ្លើងដែលអាចរីក ឬផ្ទុះបែកនៅក្នុងខ្លួនមនុស្សបានយ៉ាងងាយដូចជា គ្រាប់កាំភ្លើងដែលមានស្រទាប់ស្រោបពីក្រៅយ៉ាងរឹងមាំតែមិនមានស្រោបត្រង់បណ្តូលវាទាំងមូលទេ ឬដែលមានច្រៀកដោយស្នាមវះ។
- ការប្រើប្រាស់អាវុធ កាំភ្លើងធ្លោង ព្រមទាំងឧបរកណ៍ និងវិធីសាស្ត្រធ្វើសង្គ្រាមសឹកដែលមានលក្ខណៈបណ្តាលឱ្យរងគ្រោះថ្នាក់ដ៏លើសលប់ ឬគ្រោះថ្នាក់ដែលមិនចាំបាច់ ឬដែលមិនរើសមុខយ៉ាងជាប់នៅក្នុងការបំពានច្បាប់អន្តរជាតិស្តីពីជម្លោះប្រដាប់អាវុធដោយលក្ខខ័ណ្ឌថាអាវុធ កាំភ្លើងធ្លោង ព្រមទាំងឧបករណ៍ និងវិធីសាស្ត្រធ្វើសង្គ្រាមសឹកនោះ គឺជាកម្មវត្ថុនៃការហាមឃាត់ដ៏ទូលំទូលាយមួយ ហើយត្រូវបានដាក់បញ្ចូលក្នុងឧបសម្ព័ន្ធនៃច្បាប់លក្ខន្តិកៈនេះដោយការធ្វើវិសោធនកម្ម អនុលោមតាមបទបញ្ញត្តិពាក់ព័ន្ធដូចមានចែងក្នុងមាត្រា១២១ និង១២៣។
- ការប្រព្រឹត្តអំពើយង់ឃ្នងខ្លាំងលើសេចក្តីថ្លៃថ្នូររបស់បុគ្គល ជាពិសេស ការប្រព្រឹត្តដែលធ្វើឱ្យអាម៉ាស និងបាត់បង់តម្លៃជាមនុស្ស។
- ការប្រព្រឹត្តអំពើចាប់រំលោភ ទាសកម្មផ្លូវភេទ ពេស្យាកម្មដោយដាក់បង្ខំ ការមានគភ៌ដោយបង្ខំ ដូចមានកំណត់និយមន័យនៅមាត្រា៧(២) វណ្ណកម្មដោយដាក់បង្ខំ ឬការបំពានផ្លូវភេទក្នុងទ្រង់ទ្រាយផ្សេងទៀត ក៏បង្កើយជាការបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងសឺណែវដែរ។
- ការប្រើប្រាស់វត្តមាននៃជនស៊ីវិល ឬជនដែលត្រូវការពារដទៃទៀត ដើម្បីទទួលបានអភ័យឯកសិទ្ធិលើតំបន់ ឬលើកម្លាំងយោធាជាក់លាក់ដើម្បីឱ្យរួចផុតពីប្រតិបត្តិការសឹក។
- ការដឹកនាំដោយចេតនានូវការប្រហារប្រឆាំងនឹងអាគារ ឧបករណ៍ សម្ភារៈសុខាភិបាល ឧបករណ៍ដឹកជញ្ជូនវិជ្ជសាស្ត្រ បុគ្គលិកពេទ្យ ដោយការប្រើប្រាស់និម្មិត្តិសញ្ញាដោយឡែកៗនៃអនុសញ្ញាទីក្រុងសឺណែវស្របតាមច្បាប់អន្តរជាតិ។
- ការប្រើប្រាស់ការបង្អត់អាហារឱ្យស្លាប់ដោយចេតនាដល់ជនស៊ីវិលធ្វើជាមធ្យោបាតសឹកសង្គ្រាម ដោយការដកហូតយកពីពួកគេនូវវត្ថុដែលមានចាំបាច់សម្រាប់ការរស់នៅរបស់ពួកគេ រួមទាំងការរាំងបង្អាក់ដោយឆន្ទៈនូវការផ្គត់ផ្គង់ជំនួយសង្គ្រោះ ដូចមានចែងក្នុងអនុសញ្ញាទីក្រុងសឺណែវ។
- ការកេណ្ឌ ឬការបញ្ចូលកុមារក្រោមអាយុដប់ប្រាំឆ្នាំឱ្យចូលបំរើកងទ័ពជាតិ ឬប្រើប្រាស់ពួកគេឱ្យចូលរួមយ៉ាងសកម្មក្នុងការប្រទូសរាយគ្នា។

- ក្នុងករណីជម្លោះយោធាដែលមិនមានចរិកលក្ខណៈជាអន្តរជាតិមិនមានការបំពានដ៏ធ្ងន់ធ្ងរលើមាត្រា៣ រួមនៃអនុសញ្ញាទីក្រុងសឺណែវទាំងបួនចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ សកម្មភាពណាមួយដូចខាងក្រោម ដែលបានប្រព្រឹត្តិឡើងប្រឆាំងនឹងជនទាំងឡាយដែលមិនបានចូលរួមសកម្មក្នុងការប្រទូសរាយទេ រួមទាងសមាជិកនៃពលទាហានដែលបានទម្លាក់អាវុធរបស់ខ្លួនចុះ និងអ្នកដែលស្ថិតនៅក្នុងទីលានប្រយុទ្ធ ដោយមានជំងឺ ដោយមានរបួស ដោយការឃុំឃាំង ឬដោយមូលហេតុ ដទៃទៀត៖
- អំពើហិង្សាដល់ជីវិត ឬមនុស្ស ជាពិសេសអំពើមនុស្សឃាតគ្រប់ប្រភេទទាំងអស់ ការធ្វើកាយវិកលការប្រព្រឹត្តឃោរឃៅ និងអំពើទារុណកម្ម
- ការប្រព្រឹត្តអំពើយង់ឃ្នងខ្លាំងទៅលើសេចក្ដីថ្លៃថ្នូររបស់បុគ្គល ជាពិសេសការប្រព្រឹត្តអំពើដែលនាំឱ្យមានភាពអាម៉ាស់ និងអស់តម្លៃជាមនុស្ស។
- ការចាប់ធ្វើជាចំណាប់ខ្មាំង។
- ការកាត់ទោស និងការអនុវត្តន៍ការកាត់ទោសដោយគ្មានសាលក្រមកាត់ទោសចេញដោយតុលាការដែលត្រូវបានបង្កើតឡើងជាប្រក្រតីដែលផ្ដល់ការធានាខាងតុលាការដែលជាទូទៅត្រូវបានទទួលស្គាល់ថាមានភាពសំខាន់ខានមិនបាន។

កថាខណ្ឌទី២ខាងលើ អនុវត្តចំពោះជម្លោះប្រដាប់អាវុធដែលមិនមានចរិកលក្ខណៈជាអន្តរជាតិ ដូច្នេះហើយមិនអនុវត្តលើស្ថានភាពនៃការរំខាន និងភាពតានតឹងផ្ទៃក្នុង ដូចជាកុប្បកម្ម អំពើហិង្សាមិនទៀងទាត់ និងដាច់ឯកកោពីគេ ឬសកម្មភាពដទៃទៀតដែលមានលក្ខណៈស្រដៀងគ្នានោះទេ។

- ចំពោះការបំពានដ៏ធ្ងន់ធ្ងរដទៃទៀតលើច្បាប់ និងទំនៀងទម្លាប់ដែលយកមកអនុវត្តចំពោះជម្លោះប្រដាប់អាវុធដែលមិនមានចរិកលក្ខណៈជាអន្តរជាតិ ដែលស្ថិនក្នុងក្របខណ្ឌនៃច្បាប់អន្តរជាតិ នូវអំពើដូចខាងក្រោម៖
- ការដឹកនាំដោយចេតនានូវការវាយប្រហារប្រឆាំងនឹងពលរដ្ឋស៊ីវិលទូទៅ ឬប្រឆាំងនឹងពលរដ្ឋស៊ីវិលឯកត្តជនដែលមិនចូលរួមដោយផ្ទាល់ក្នុងការប្រទូសរាយ។
- ការដឹកនាំដោចេតនានូវការវាយប្រហារនឹងអាគារ ឧបករណ៍ សម្ភារៈសុខាភិបាល និងឧបករណ៍ដឹកជញ្ជូនវេជ្ជសាស្ត្រ ព្រមទាំងបុគ្គលិកពេទ្យ ដោយប្រើប្រាស់និម្មិត្តសញ្ញាដោយឡែកៗនៃអនុសញ្ញាទីក្រុងសឺណែវតាមច្បាប់អន្តរជាតិ។
- ការដឹកនាំដោយចេតនានូវការវាយប្រហារប្រឆាំងនឹងមន្ត្រី ប៉ុស្តិ៍ទីតាំង ឧបករណ៍ សម្ភារៈ ឬយានជំនិះពាក់ព័ន្ធនឹងជំនួយមនុស្សធម៌ ឬបេសកកម្មរក្សាសន្តិភាព ស្របតាមធម្មនុញ្ញអង្គការសហប្រជាជាតិ ដរា

ណាពួកគេមានសិទ្ធិទទួលបានការការពារដែលមានឱ្យដល់ពលរដ្ឋស៊ីវិល ឬវត្ថុស៊ីវិល តាមច្បាប់ស្តីពីជម្លោះប្រដាប់អាវុធ។

- ការដឹកនាំដោយចេតនានូវ ការវាយប្រហារប្រឆាំងនឹងអាគារដែលប្រើប្រាស់សម្រាប់គោលបំណងសាសនា ការអប់រំ សិល្បៈ វិទ្យាសាស្ត្រ ឬគោលបំណងសប្បុរសធម៌ វិមានប្រវត្តិសាស្ត្រ មន្ទីរពេទ្យ និងទីកន្លែងដែលមានអ្នកជំងឺ និងអ្នករបួសប្រមូលផ្តុំដោយទីកន្លែងនេះមិនមែនជាចំណុចគោលដៅរបស់យោធានោះឡើយ។
- ការចូលលួចប្លន់ទីក្រុង ឬកន្លែងណាមួយទោះបីជាធ្វើឡើងដោយការវាយតបក៏ដោយ។
- ការប្រព្រឹត្តិការចាប់រំលោភ ទាសកម្មផ្លូវភេទ ពេស្យាកម្មដោយដាក់បង្ខំ ការមានគភ៌ដោយបង្ខំដូចកំណត់និយមន័យនៅក្នុងមាត្រា៧ វណ្ណកម្មដោយដាក់បង្ខំ និងអំពើបំពានផ្លូវភេទក្នុងទ្រង់ទ្រាយណាផ្សេងទៀតក៏បង្កើតបាន ជាការបំពានដ៏ធ្ងន់ធ្ងរលើមាត្រា៣ រួមនៃអនុសញ្ញាទីក្រុងសឺណែវទាំងបួនដែរ។
- ការកេណ្ឌ និងបញ្ចូលកុមារអាយុក្រោមដប់ប្រាំឆ្នាំឱ្យចូលក្នុងកម្លាំងប្រដាប់អាវុធ ឬក្រុមប្រដាប់អាវុធ ឬការប្រើប្រាស់ពួកគេឱ្យបម្រើកការយ៉ាងសកម្មក្នុងការប្រទូសរាយ។
- ការដាក់បញ្ជាឱ្យពលរដ្ឋស៊ីវិលផ្លាស់ទីលំនៅ ដោយសារមូលហេតុពាក់ព័ន្ធនឹងជម្លោះនោះលើកលែងតែមានការពាក់ព័ន្ធនឹងសុវត្ថិភាពនៃពលរដ្ឋស៊ីវិល ឬមានមូលហេតុមកពីភាពចាំបាច់ខាងយោធាតម្រូវឱ្យធ្វើដូច្នោះ។
- ការសម្លាប់ ឬការធ្វើឱ្យរងរបួសដល់ពលទាហានដែលក្បត់។
- ការប្រកាសថានឹងមិនផ្តល់ការត្រាប្រណីណាមួយឡើយ។
- ការដាក់ជនដែលស្ថិតនៅក្នុងអំណាចនៃភាពីមួយទៀតនៃជម្លោះឱ្យរងការធ្វើកាយវិកល ឬការពិសោធន៍ខាងវេជ្ជសាស្ត្រ ទន្តសាស្ត្រ ឬការដកពេទ្យ ដល់ជនពាក់ព័ន្ធនោះទេ ដែលមិនធ្វើឡើងក្នុងប្រយោជន៍របស់ជននោះ និងដែលបណ្តាលឱ្យជននោះស្លាប់ ឬធ្វើឱ្យជននោះរងគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាព។
- ការបំផ្លាញ ឬការរឹបអូសយកទ្រព្យសម្បត្តិរបស់បច្ចាមិត្ត លើកលែងតែការបំផ្លាញ ឬការរឹបអូសយកនោះត្រូវទាមទារបញ្ជាឱ្យធ្វើដោយសារភាពចាំបាច់នៃជម្លោះនោះ។

កថាខណ្ឌទី២ អនុវត្តចំពោះជម្លោះប្រដាប់អាវុធដែលមិនមានចរិកលក្ខណៈជាអន្តរជាតិ ដូច្នេះហើយមិនអនុវត្តចំពោះស្ថានភាពនៃការរំខាន និងភាពតានតឹងផ្ទៃក្នុង ដូចជាកុប្បកម្ម អំពើហិង្សាម្តងម្កាល និងដាច់ឯកកោពីគេ ឬអំពើដទៃទៀតដែលមានលក្ខណៈស្រដៀងគ្នានេះទេ។ អនុវត្តចំពោះជម្លោះប្រដាប់អាវុធដែលកើតឡើងក្នុង

ទឹកដីនៃរដ្ឋមួយនៅពេលមានជម្លោះប្រដាប់អាវុធដែលមានការបែងចែករវាងអាជ្ញាធររដ្ឋាភិបាល និងក្រុមប្រដាប់អាវុធដែលត្រូវបានរៀបចំឡើង ឬរវាងក្រុមប្រដាប់អាវុធ និងក្រុមប្រដាប់អាវុធនានានោះ។

ជារួមមកគ្មានអ្វីមួយក្នុងកថាខណ្ឌទី២ ខាងលើត្រូវមានឥទ្ធិពលលើការទទួលខុសត្រូវរបស់រដ្ឋាភិបាល ដើម្បីរក្សា ឬបង្កើតច្បាប់ និងសណ្តាប់ធ្នាប់នៅក្នុងរដ្ឋនោះឡើងវិញ ឬដើម្បីការពារឯកភាពជាតិ និងបូរណភាពដែនដីនៃរដ្ឋនោះ ដោយមធ្យោបាយស្របច្បាប់ទាំងអស់ឡើយ។

## ៤. ឧក្រិដ្ឋកម្មឈ្លានពាន

នេះបើយោងតាមមាត្រា៨ ចែងអំពីឧក្រិដ្ឋកម្មនៃការឈ្លានពាន លក្ខន្តិកៈដើមឡើយបានផ្តល់ថា តុលាការមិនអាចអនុវត្តយុត្តាធិការរបស់ខ្លួនលើឧក្រិដ្ឋកម្មនៃការឈ្លានពានបានទេ រហូតដល់ពេលដែលរដ្ឋភាគីបានឯកភាពគ្នាលើនិយមន័យនៃឧក្រិដ្ឋកម្ម និងកំណត់លក្ខខណ្ឌដែលអាចត្រូវបានចោទប្រកាន់វិសោធនកម្មបែបនេះត្រូវបានអនុម័តនៅក្នុងសន្និសីទពិនិត្យឡើងវិញលើកដំបូងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) នៅទីក្រុងកាំប៉ាឡា (Kampala) ប្រទេសអ៊ូហ្គង់ដាក្នុងខែមិថុនា ឆ្នាំ២០១០។ ទោះយ៉ាងណាវិសោធនកម្មនេះបានបញ្ជាក់ថា ICC នឹងមិនត្រូវបានអនុញ្ញាតឱ្យអនុវត្តយុត្តាធិការនៃឧក្រិដ្ឋកម្មនៃការឈ្លានពានឡើយរហូតដល់លក្ខខណ្ឌពីរបន្ថែមទៀតត្រូវបានបំពេញ ហើយដោយលក្ខខណ្ឌទាំងពីរនោះរួមមាន (១) វិសោធនកម្មនេះបានចូលជាធរមានដោយមានការឯកភាពពីរដ្ឋចំនួន ៣០ ហើយ (២) នៅឬបន្ទាប់ពីថ្ងៃទី១ ខែមករាឆ្នាំ ២០១៧ សភានៃរដ្ឋភាគីបានបោះឆ្នោតគាំទ្រអនុញ្ញាតឱ្យតុលាការអនុវត្តយុត្តាធិការ។ ប៉ុន្តែនៅថ្ងៃទី ២៦ ខែមិថុនាឆ្នាំ ២០១៦ លក្ខខណ្ឌទី ១ បានពេញចិត្ត ហើយរដ្ឋភាគីបានបោះឆ្នោតគាំទ្រអនុញ្ញាតឱ្យតុលាការអនុវត្តយុត្តាធិការនៅថ្ងៃទី ១៤ ខែធ្នូឆ្នាំ ២០១៧ ។ ដូច្នេះយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) មានសមត្ថកិច្ចក្នុងការកាត់ទោសឧក្រិដ្ឋកម្មនៃការឈ្លានពានមានអនុភាពកាលពីថ្ងៃទី ១៧ ខែកក្កដាឆ្នាំ ២០១៨។

## ៥. បទល្មើសប្រឆាំងនឹងរដ្ឋបាលយុត្តធម៌

អនុលោមតាមមាត្រា៧០ នៃច្បាប់ស្តីពីលក្ខន្តិកៈក្រុងរ៉ូមបានបញ្ញត្តិថា បទឧក្រិដ្ឋជាអំពើចេតនាជាក់លាក់ដែលរំខានដល់ការស៊ើបអង្កេត និងដំណើរការនីតិវិធីនៅចំពោះមុខតុលាការរួមទាំងការផ្តល់សក្ខីកម្មក្លែងក្លាយ ការបង្ហាញភស្តុតាងក្លែងក្លាយ ការធ្វើឱ្យខូចខាតដល់សាក្សី ឬមន្ត្រីតុលាការ អំពើពុករលួយ ការសងសឹកមន្ត្រីតុលាការ និងការទាមទារ ឬទទួលសំណូក របស់មន្ត្រីតុលាការ។

ដោយឡែកគោលការណ៍ និងនីតិវិធីគ្រប់គ្រងការអនុវត្តន៍យុត្តាធិការរបស់តុលាការលើបទល្មើសនៅក្រោមមាត្រានេះត្រូវតែជាគោលការណ៍ និងនីតិវិធីទាំងឡាយដែលមានចែងនៅក្នុងវិធាននៃនីតិវិធី និងភស្តុតា

ង។ ហើយលក្ខខ័ណ្ឌដើម្បីផ្តល់ការសហការជាអន្តរជាតិជាមួយតុលាការលើដំណើរការជំរះរឿងក្តីរបស់ខ្លួនតាមមាត្រា៧០នេះ ត្រូវគ្រប់គ្រងដោយច្បាប់ក្នុងស្រុកនៃរដ្ឋដែលស្នើសុំ[19]។

### កថាខណ្ឌទី២៖ យុត្តាធិការលើដែនដី ឬបុគ្គល (Territorial or Personal Jurisdiction)

ជាការពិតណាស់ថាបុគ្គលអាចត្រូវបានតុលាការចោទប្រកាន់ទាំងយុត្តាធិការដែនដី ឬយុត្តាធិការផ្ទាល់ខ្លួន។ ដូច្នេះបុគ្គលអាចត្រូវបានផ្តន្ទាទោសប្រសិនបើពួកគេបាន (១) ប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្នុងដែនសមត្ថកិច្ចរបស់តុលាការឬ (២) បានប្រព្រឹត្តបទឧក្រិដ្ឋខណៈពេលដែលគាត់ជាជនជាតិនៃរដ្ឋដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់តុលាការ។

### ១.យុត្តាធិការដែនដី

យុត្តាធិការដែនដីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ICC គឺមានសមត្ថកិច្ចចាត់ការលើដែនដី ដែនទឹកដែលបានចុះបញ្ជី និងផងដែរ គឺដែនអាកាសដែលបានចុះបញ្ជីរបស់រដ្ឋដែលមានទាំង (១) ក្លាយជាភាគីនៃលក្ខន្តិកៈទីក្រុងរ៉ូមឬ (២) បានទទួលយុត្តាធិការរបស់តុលាការដោយដាក់សេចក្តីប្រកាសជាមួយតុលាការ។នៅក្នុងស្ថានភាពដែលត្រូវបានបញ្ជូនទៅតុលាការដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិយុត្តាធិការដែនដីត្រូវបានកំណត់ដោយក្រុមប្រឹក្សាសន្តិសុខដែលអាចមានទំហំធំជាងយុត្តាធិការដែនដីធម្មតារបស់តុលាការ។

ឧទាហរណ៍៖ ប្រសិនបើក្រុមប្រឹក្សាសន្តិសុខសំដៅលើស្ថានការណ៍ដែលបានកើតឡើងនៅក្នុងទឹកដីនៃរដ្ឋដែលទាំងពីរមិនបានក្លាយជាភាគីនៃលក្ខន្តិកៈក្រុងរ៉ូម និង មិនដាក់សេចក្តីប្រកាសជាមួយតុលាការទេ តុលាការនៅតែអាចផ្តន្ទាទោសឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងរដ្ឋនោះ។

### ២. យុត្តាធិការសញ្ជាត

យុត្តាធិការសញ្ជាតិ ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិពង្រីកដល់រូបវន្តបុគ្គលទាំងឡាយណាដែលប្រព្រឹត្តឧក្រិដ្ឋកម្មដោយពុំគិតពីទីកន្លែងដែលពួកគេស្ថិតនៅ ឬកន្លែងដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តនោះឡើយ ដរាបណាបុគ្គលទាំងនោះជាជនជាតិនៃរដ្ឋ (១) ដែលជាភាគីនៃលក្ខន្តិកៈទីក្រុងរ៉ូមឬ (២) រដ្ឋដែលបានទទួលយុត្តាធិការរបស់តុលាការដោយការដាក់សេចក្តីប្រកាសជាមួយតុលាការ។

ដូចគ្នាទៅនឹងយុត្តាធិការដែនដីដែរ យុត្តាធិការសញ្ញាតិអាចត្រូវបានពង្រីកដោយក្រុមប្រឹក្សាសន្តិសុខប្រសិនបើវាសំដៅលើស្ថានភាពណាមួយដែលពាក់ព័ន្ធនឹង សន្តិសុខសណ្តាប់ធ្នាប់ពិភពលោក និង តុលាការ។ តុលាការនឹងមិនមានយុត្តាធិការលើជនណាដែលមានអាយុក្រោម១៨ឆ្នាំ នៅពេលនៃការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌដែលត្រូវចោទនោះឡើយ។

[19] មាត្រា៧០៖ អំពីបទល្មើសប្រឆាំងនឹងរដ្ឋបាលយុត្តិធម៌

**កថាខណ្ឌទី៣៖ យុត្តាធិការលើពេលវេលា**(Temporal Jurisdiction)

យុត្តាធិការលើពេលវេលា គឺជារយៈពេលដែលតុលាការអាចអនុវត្តអំណាចរបស់ខ្លួន។ គ្មានលក្ខន្តិកៈនៃដែនកំណត់អនុវត្តចំពោះឧក្រិដ្ឋកម្មណាមួយដែលមានចែងក្នុងលក្ខន្តិកៈ។ តែទោះយ៉ាងណាយុត្តាធិការរបស់តុលាការគឺមិនមានដំណើរការឡើងវិញទេ។ បុគ្គលម្នាក់ៗអាចត្រូវបានកាត់ទោសចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅ ឬក្រោយថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០២ ដែលជាកាលបរិច្ឆេទដែលលក្ខន្តិកៈទីក្រុងរ៉ូមចូលជាធរមាន។ ប្រសិនបើរដ្ឋមួយបានក្លាយជាភាគីនៃលក្ខន្តិកៈហើយដូច្នេះរដ្ឋនោះផងដែរក៏ជា សមាជិករបស់តុលាការបន្ទាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០២ នោះតុលាការមិនអាចអនុវត្តយុត្តាធិការមុនកាលបរិច្ឆេទនៃសមាជិកភាពចំពោះករណីជាក់លាក់ណាមួយឡើយ។ ឧទាហរណ៍៖ ប្រសិនបើលក្ខន្តិកៈចូលជាធរមានសម្រាប់រដ្ឋនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០០៣ តុលាការអាចអនុវត្តយុត្តាធិការបណ្តោះអាសន្នចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងរដ្ឋនោះ ឬ ត្រូវបានប្រព្រឹត្តដោយជនជាតិនៃរដ្ឋនោះនៅ ឬក្រោយថ្ងៃទី០១ ខែមករា ឆ្នាំ២០០៣ ។

ជារួមមានន័យតុលាការព្រហ្មទណ្ឌអន្តរជាតិអនុវត្តយុត្តាធិការ ឬ ដែនអំណាចដោះស្រាយតែលើឧក្រិដ្ឋកម្មទាំងឡាយណា ដែលកើតមានបន្ទាប់ពីលក្ខន្តិកៈក្រុងរ៉ូម ( Rome Statute ) ចូលជាធរមានប៉ុណ្ណោះ ពោលគឺមិនអនុវត្តថយក្រោយឡើយ។

# ជំពូកទី២៖ ការប្រៀបធៀបយុត្តាធិការតុលាការយុត្តិធម៌អន្តរជាតិ និងយុត្តាធិការតុលាការព្រហ្មទណ្ឌអន្តរជាតិ

## ផ្នែកទី១៖ ភាពដូចគ្នា

### កថាខណ្ឌទី១៖ វិសាលភាពនៃយុត្តាធិការ

វិសាលភាពនៃយុត្តាធិការនៅត្រង់ចំណុចនេះ មានន័យសំដៅដល់សមត្ថកិច្ច និងអំណាចក្នុងការអនុវត្តយុត្តាធិការរបស់ខ្លួន។ ដោយឡែកលក្ខណៈពិសេសរបស់យុត្តាធិការរបស់តុលាការយុត្តិធម៌អន្តរជាតិ ICJ ឬយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) គឺមានអំណាចទូលំទូលាយ និងមានដែនយុត្តាធិការទូទាំងសាកលលោក។

### ១.ចរិតលក្ខណៈនិងសមាជិកភាព

### ១.១ យុត្តាធិការដែលបានព្រមព្រៀង

ជាគោលការណ៍ យុត្តាធិការដែលបានព្រមព្រៀង គឺជាការព្រមទទួលយកយុត្តាធិការនោះ។ អាចនិយាយបានម៉្យាងទៀត ថារដ្ឋមួយមិនអាចត្រូវគេប្តឹងទៅកាន់តុលាការបានឡើយ ប្រសិនបើរដ្ឋនោះមិនយល់ព្រមទទួលយកយុត្តាធិការនោះទេ។ ដូចគ្នាផងដែរយុត្តាធិការរបស់តុលាការយុត្តិធម៌អន្តរជាតិ (ICJ) ក៏ដោយយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ក៏ដោយសុទ្ធតែមិនមានអានុភាពអនុវត្តដែនយុត្តាធិការរបស់ខ្លួនប្រសិនបើរដ្ឋបដិសេធមិនព្រមទទួលយកយុត្តាធិការនោះ។

### ១.២ យុត្តាធិការដែលមានគូវិវាទតែមួយប្រភេទ (ICJ &ICC)

មាត្រា៣៤ នៃលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ (ICJ) មានបញ្ជាក់យ៉ាងច្បាស់លើចំណុចនេះថា៖ មានតែរដ្ឋប៉ុណ្ណោះដែល អាចជាភាគីនៅចំពោះមុខតុលាការ។ យើងអាចនិយាយម៉្យាងទៀតថា បុគ្គលឯកជន ឬអង្គការអន្តរជាតិមិនអាចជាភាគីនៃកិច្ចដំណើរការនីតិវិធីដោះស្រាយវិវាទនៅចំពោះមុខតុលាការយុត្តិធម៌អន្តរជាតិបានឡើយ។ ជាទូទៅគេអាចពន្យល់បានថា មូលហេតុដែលបុគ្គលឯកជន ឬអង្គការអន្តរជាតិ មិនអាចជាភាគីនៅចំពោះមុខតុលាការនោះ គឺដោយសាររដ្ឋមិនទុកចិត្តចំពោះអង្គការអន្តរជាតិនានា ជាពិសេសមានការបារម្ភថា ពួកគេអាចបង្កឱ្យមានវិវាទដែលរដ្ឋមិនចង់ឱ្យកើតមាន។ ក្រៅពីតុលាការយុត្តិធម៌អន្តរជាតិ (ICJ) តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ក៏ជាឧទាហរណ៍មួយទៀតនៃយុត្តាធិការដែលមានគូវិវាទតែមួយប្រភេទពោលគឺភាគី គឺជាបុគ្គលពុំមែនជារដ្ឋឡើយ។

## កថាខណ្ឌទី២៖ ការបង្ហាញឆន្ទៈរបស់រដ្ឋក្នុងការទទួលយកយុត្តាធិការ

### ១. ភាគពួកច្ចរបស់រដ្ឋ

មិនថាយុត្តាធិការរបស់តុលាការយុត្តិធម៌អន្តរជាតិ ( ICJ ) ឬតុលាការព្រហ្មទណ្ឌអន្តរជាតិ ( ICC )នោះទេ បណ្ដារដ្ឋសុទ្ធតែអាចបដិសេធក្នុងការទទួលយកសន្និសញ្ញាមកអនុវត្តនៅក្នុងប្រទេសរបស់ខ្លួនបាន ហើយរាល់ការសម្រេចរបស់រដ្ឋក្នុងការទទួលយក ឬមិនទទួលយកគឺសុទ្ធតែជាជម្រើស មិនថាតុលាការ ឬស្ថាប័នអន្តរជាតិណាមួយនោះឡើយ គឺពុំមានសិទ្ធិចាប់បង្ខំ ឬអនុវត្តដែនសមត្ថកិច្ចរបស់ខ្លួនលើបណ្ដារដ្ឋ ឬពលរដ្ឋនៃរដ្ឋនោះបានឡើយ។

## ផ្នែកទី២៖ ភាពខុសគ្នា

ចាប់ពីចំណុចកកើតមកICC និង ICJមានលក្ខណៈខុសគ្នាច្រើន បើទោះបីលក្ខណៈអរូបីរបស់វាជាប្រភេទ តុលាការអន្តរជាតិដែលមានអំណាចទូលំទូលាយយុត្តាធិការសកលក៏ដោយក្ដី។ ចាប់តាំងពីឆ្នាំ២០០២មក ICCបានក្លាយជាតួអង្គដ៏គួរឱ្យកោតខ្លាចក្នុងការតតាំងនឹងបញ្ហាសិទ្ធិមនុស្ស អយុត្តិធម៌ ខណៈ ICJ គឺជាតួអង្គដែលមានប្រាជ្ញាវាងវៃក្នុងវិស័យគាំពារសន្តិសុខអន្តររដ្ឋ និង ការសិក្សាសង្គម និង សេដ្ឋកិច្ចសកល។ ប្រមើមើលតែមួយភ្លែត យើងអាចដឹងបានថា តុលាការនេះមានភាពខុសគ្នាច្រើនដូចជា ICJមានទំនាក់ទំនងជិតស្និទ្ធឬស្ថិតក្នុងឆ័ត្ររបស់អង្គការសហប្រជាជាតិខណៈICCជាតួអង្គឯករាជ្យជាតុលាការរបស់ពិភពលោកមិនចំណងនឹងអង្គការនានានោះទេ។ បច្ចុប្បន្ននេះICCមានសមាជិកក៏មិនតិចជាងICJដែលមាន១៩៣ប្រទេសដែរ គឺអង្គការនេះមានប្រទេសជាសមាជិកដល់ទៅ១២៣រដ្ឋណោះ។ កាលពីឆ្នាំ២០១៧ សហភាពអាហ្វ្រិកមានគោលបំណងប្រមូលផ្ដុំគ្នាដើរចេញពីICCដោយយល់ថា តុលាការនេះផ្ដោតលើប្រទេសកំពុងអភិវឌ្ឍយកក្ដីក្ដាំងឧក្រិដ្ឋមកបង្អាក់ការអភិវឌ្ឍប្រទេសរបស់ពួកគេ[20] ខណៈហ្វីលីពីនបានដកសមាជិកភាពចេញពីតុលាការនេះ និង ប្រទេសជាច្រើនទៀតតាំងពីអាមេរិកឡើងមិនជាសមាជិកអង្គការនេះទេដោយមានការលើកឡើងថា ពួកគេគ្មានបំណងប្រគល់អធិបតេយ្យភាពផ្ដល់ឱ្យតុលាការនោះមានយុត្តាធិការលើប្រទេសពួកគេទេ។ ភាពខុសគ្នាលើទំហំនៃការងារវិញគឺតុលាការឧក្រិដ្ឋកម្មអន្តរជាតិដោះស្រាយរឿងក្ដីព្រហ្មទណ្ឌតាំងពីវាត្រូវបានបង្កើតដោយលក្ខន្តិកៈក្រុងរ៉ូមហើយស៊ើបអង្កេតនិងកាត់ទោសបុគ្គលចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប្រល័យពូជសាសន៍ និង ឧក្រិដ្ឋកម្មសង្គ្រាមដោយគ្មានអាជ្ញាយុកាលឡើយ។ ជារឿយឧក្រិដ្ឋកម្មប្រភេទនេះតែងតែប្រព្រឹត្តឡើងដោយមន្ត្រីជាន់ខ្ពស់នៃថ្នាក់ដឹកនាំប្រទេសជាសមាជិក។ អ្វីដែលគួរឱ្យកត់សម្គាល់គឺថា ICCជាតុលាការចុងក្រោយតែមួយគត់អនុវត្ត

---

[20] ចូលអានលម្អិតBBC. (2017, February 1). African Union backs mass withdrawal from ICC. BBC News. https://www.bbc.com/news/world-africa-38826073.

អំណាចនៅពេលដែលប្រព័ន្ធយុត្តិធម៌ប្រទេសមួយដួលរលំហើយរដ្ឋាភិបាលក្លាយជាចារីក្នុងឧក្រិដ្ឋកម្មអន្តរជាតិនោះ។ ឯតុលាការICJវិញមានទម្រង់ជា តុលាការស៊ីវិលដោះស្រាយជម្លោះរដ្ឋនិងរដ្ឋហើយនិងផ្តល់យោបល់លើបញ្ហាច្បាប់រដ្ឋ ក្នុងទម្រង់មហាសន្និបាតអង្គការសហប្រជាជាតិ។ បញ្ហាដែលវាដោះស្រាយរួមមានបញ្ហាអធិបតេយ្យ ទឹកដី ការបំពានសន្ធិសញ្ញា បញ្ហាសមុទ្រជំនួញជាអាទិ៍។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិមានសមាសភាពចៅក្រម១៨រូបដែលមានរូបៗមានអាណត្តិ៩ឆ្នាំមកពីប្រទេសនានាជាសមាជិករបស់ICC និងមិនអាចមានចៅក្រមពីររូបមកពីប្រទេសតែមួយទេ។ តុលាការនេះក៏មានរដ្ឋអាជ្ញាដែលស៊ើបអង្កេតឧក្រិដ្ឋកម្មហើយប្រសិនបើរដ្ឋអាជ្ញារកឃើញភស្តុតាងដែលបង្ហាញថាឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តគាត់សុំឱ្យចៅក្រមចាប់ផ្តើមសវនាការ។

សម្រាប់តុលាការយុត្តិធម៌អន្តរជាតិមានចៅក្រម ១៥ រូបដែលពួកគេម្នាក់ៗដូចនៅក្នុងអង្គជំនុំជម្រះតុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICC) ក៏មានអាណត្តិ ៩ឆ្នាំ ដែរ។ ពួកគេត្រូវបានជ្រើសរើសដោយមហាសន្និបាតអង្គការសហប្រជាជាតិនិងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិដោយមានចៅក្រម ៥ រូបត្រូវបានជ្រើសរើសរៀងរាល់ ៣ ឆ្នាំម្តងដើម្បីធានានិរន្តរភាពនៅក្នុងតុលាការ។ ដូចគ្នានេះដែរគ្មានចៅក្រមពីររូបអាចមកពីប្រទេសតែមួយបានទេ។ អាសនៈសម្រាប់ចៅក្រមនឹងត្រូវបែងចែកទៅតាមតំបន់ភូមិសាស្ត្រហេតុដូចនេះមាន ៥ អាសនៈសម្រាប់បស្ចិមប្រទេស ៣ សំរាប់រដ្ឋអាហ្វ្រិក ២ សំរាប់រដ្ឋនៅអឺរ៉ុបខាងកើត ៣ សំរាប់រដ្ឋអាស៊ី និង ២ សំរាប់អាមេរិកឡាទីននិងការ៉ាអ៊ីប រដ្ឋ។

ដូចអង្គការដទៃទៀតដែរស្ថាប័នច្បាប់អន្តរជាតិទាំងពីរនេះក៏ត្រូវការថវិកាដើម្បីអនុវត្តកិច្ចការ។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិដែលជាស្ថាប័នឯករាជ្យមួយមានតួនាទីសំខាន់លើការរួមចំណែកដែលធ្វើឡើងដោយ ភាគីរដ្ឋចំពោះលក្ខន្តិកៈទីក្រុងរ៉ូម និងការរួមចំណែកដោយស្ម័គ្រចិត្តពីអង្គការសហប្រជាជាតិ។ ទន្ទឹមនឹងនេះតុលាការយុត្តិធម៌អន្តរជាតិដែលជា ផ្នែកមួយនៃ អង្គការសហប្រជាជាតិត្រូវបានផ្តល់មូលនិធិដោយរដ្ឋជាសមាជិក។

ភាពខុសគ្នាដែលយើងបានពិភាក្សាខាងលើនេះនៅមិនទាន់លម្អិតចូលក្នុងសាច់រឿងពិតនៃ ប្រធានបទសារណានោះទេ។ បន្ទាប់នេះហើយ ដោយយើងផ្អែកលើមូលដ្ឋានវែកញែកជារួមពីលើយុត្តាធិការលើជម្លោះអន្តរជាតិ និងការប្រឹក្សាយោបល់របស់តុលាការICJ និង យុត្តាធិការដែនដី យុត្តាធិការពេលវេលា និងយុត្តាធិការលើកម្មវត្ថុនៃវិវាទរបស់តុលាការICC បានរកឃើញថាយុត្តាធិការរបស់តុលាការទាំងពីរគឺវាមានលក្ខណៈខុសគ្នាដល់ទៅ៣ចំណុច។

### កថាខណ្ឌទី១៖ ភាគីនៃវិវាទ

យុត្តាធិការរបស់តុលាការយុត្តិធម៌អន្តរជាតិគឺ សំរេចដោយអនុលោមតាមច្បាប់អន្តរជាតិវិវាទដែលមានលក្ខណៈស្របច្បាប់ដែលត្រូវបានដាក់ជូនដោយរដ្ឋដែលគេហៅថាយុត្តាធិការក្នុងករណីមានជម្លោះ។ នេះបើ

យោងតាមមាត្រា ៣៥(១) នៃលក្ខន្តិកៈចែងថាតុលាការត្រូវបើកចំហចំពោះរដ្ឋភាគីចំពោះលក្ខន្តិកៈ និងមាត្រា ៩៣(១) នៃធម្មនុញ្ញអង្គការសហប្រជាជាតិចែងថា សមាជិកទាំងអស់នៃអង្គការសហប្រជាជាតិគឺជា ភាគីតុលាការជាក់ស្តែងនៃលក្ខន្តិកៈនេះ។ មានតែរដ្ឋទេដែលអាចដាក់បណ្តឹង និងបង្ហាញខ្លួនចំពោះមុខតុលាការយុត្តិធម៌អន្តរជាតិ អាជ្ញាធរផ្សេងទៀតបុគ្គលឯកជនមិនមានសិទ្ធិក្នុងការពាក់ព័ន្ធនៃនីតិវិធីតុលាការនោះទេ។ នៅក្នុងដំណើរការវិវាទដែលមានជម្លោះនៅពេលដែលវិវាទត្រូវបាននាំយកទៅតុលាការ ដោយពាក្យស្នើសុំឯកតោភាគីដែលបានប្តឹងដោយរដ្ឋមួយប្រឆាំងនឹងរដ្ឋមួយផ្សេងទៀតឈ្មោះរបស់ភាគីនៅក្នុងចំណងជើងផ្លូវការនៃសំណុំរឿងត្រូវបានបំបែកដោយអក្សរកាត់ v e.g., Cameroon v. Nigeria។ នៅពេលជម្លោះត្រូវបានបញ្ជូនទៅតុលាការដោយផ្អែកលើកិច្ចព្រមព្រៀងពិសេសរវាងរដ្ឋពីរឈ្មោះរបស់ភាគីគឺគេត្រូវបានបំបែកដោយសញ្ញាដាច់ៗ ដោយឧទាហរណ៍គឺ Indonesia/Malaysia។

ចំណែកតុលាការព្រហ្មទណ្ឌអន្តរជាតិវិញគឺ មានសមត្ថកិច្ចលើបុគ្គលនៃរដ្ឋទាំងឡាយដែលជាសមាជិករបស់តុលាការចាប់ពីថ្ងៃដែលច្បាប់លក្ខន្តិកៈចូលជាធរមាន ហើយរដ្ឋនោះអាចទទួលយកយុត្តាធិការនូវចំណោទបញ្ហាមុនបានតាមរយៈការធ្វើសេចក្តីប្រកាសករណីរដ្ឋនោះមិនបានចូលជាភាគី នៃច្បាប់លក្ខន្តិកៈដើម្បីអនុវត្តយុត្តាធិការរបស់ខ្លួនចំពោះបទល្មើសព្រហ្មទណ្ឌដែលបានប្រព្រឹត្តក្រោយច្បាប់លក្ខន្តិកៈចូលជាធរមាន។

រដ្ឋភាគីមិនអាចជ្រៀតជ្រែកជាមួយមុខងារតុលាការរបស់តុលាការឡើយ។ វិវាទទាក់ទងនឹងសំណុំរឿងបុគ្គលត្រូវបានដោះស្រាយដោយការបែងចែកតុលាការ។ ក្នុងអត្ថបទកម្រងសំណួរចម្លើយរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិក៏បានឆ្លើយបញ្ជាក់ថា ICC កាត់ក្តីលើបុគ្គលខុសពីតុលាការយុត្តិធម៌អន្តរជាតិដែលជា តុលាការសំខាន់អង្គការសហប្រជាជាតិសម្រាប់ការដោះស្រាយវិវាទរវាងរដ្ឋ។ ICC កាត់ទោសបុគ្គលម្នាក់ៗ មិនមែនក្រុម ឬរដ្ឋទេ។ បុគ្គលណាដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់ ICC អាចត្រូវបាននាំមកនៅចំពោះមុខ ICC ។ ICC មិនជំនួសប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌជាតិទេ។ ផ្ទុយទៅវិញវាបំពេញបន្ថែមហើយធានាការចោទប្រកាន់និងកាត់ក្តីបុគ្គលប្រសិនបើរដ្ឋពាក់ព័ន្ធមិនមិនអាច ឬ មិនមានឆន្ទៈពិតប្រាកដក្នុងការធ្វើដូច្នេះតួយ៉ាងប៉ុនប៉ងការពារបុគ្គលពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ពួកគេ។ នេះត្រូវបានគេស្គាល់ថាជាគោលការណ៍។ ប៉ុន្តែការបំពេញបន្ថែមដែលជាអាទិភាពត្រូវបានផ្តល់ឱ្យប្រព័ន្ធជាតិ។ពោលម្តងទៀតគឺ នៅពេលរដ្ឋមួយក្លាយជា ភាគីនៃលក្ខន្តិកៈទីក្រុងរ៉ូម ប្រទេសនេះយល់ព្រមប្រគល់ខ្លួនទៅយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិទាក់ទងនឹង ឧក្រិដ្ឋកម្មដែលមានចែងក្នុងលក្ខន្តិកៈតុលាការអាចអនុវត្តយុត្តាធិការរបស់ខ្លួនក្នុង កាលៈទេសៈដែលជនល្មើសជាជនជាតិនៃរដ្ឋភាគីឬកន្លែងដែលឧក្រិដ្ឋកម្មនោះមានបានប្ដេជ្ញាចិត្តនៅក្នុងទឹកដីរបស់រដ្ឋភាគី។ ម្យ៉ាងទៀតរដ្ឋដែលមិនមែនជាភាគីនៃលក្ខន្តិកៈអាចសម្រេចចិត្តទទួលយកយុត្តាធិការរបស់ ICC

។ ល័ក្ខខ័ណ្ឌទាំងនេះមិនត្រូវបានអនុវត្តទេនៅពេលដែលក្រុមប្រឹក្សាសន្តិសុខធ្វើសកម្មភាពក្រោមជំពូកទី៧ នៃធម្មនុញ្ញអង្គការសហប្រជាជាតិសំដៅលើស្ថានភាពមួយទៅការិយាល័យព្រះរាជអាជ្ញា។

### កថាខណ្ឌទី២៖ ប្រភេទនៃវិវាទ

តុលាការឧក្រិដ្ឋកម្មអន្តរជាតិមានយុត្តាធិការស៊ើបអង្កេតលើឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតដែល មានការព្រួយបារម្ភចំពោះសហគមន៍អន្តរជាតិទាំងមូលពោលគឺ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្ម សង្គ្រាមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មនៃការឈ្លានពាននៅពេលមានលក្ខខណ្ឌ។ ចំណែកការអនុវត្តយុត្តាធិការរបស់តុលាការលើបណ្តឹងចុងក្រោយត្រូវបានបំពេញចំពោះឧក្រិដ្ឋកម្មចំនួន ៣ គឺ៖

- ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងប្រទេសសមាជិក។
- ឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តដោយប្រជាជនមកពីប្រទេសជាសមាជិក។
- ឧក្រិដ្ឋកម្មដែលក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិចង់ឱ្យតុលាការព្រហ្មទណ្ឌអន្តរជាតិធ្វើការស៊ើបអង្កេត។

ICC ក៏អាចដាក់ការជំនុំជម្រះបុគ្គលដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តឧក្រិដ្ឋកម្មអន្តរជាតិដែរ។ យុត្តាធិការដែនដីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិគឺ មានវិសាលភាពធំលើសពីICJទៅទៀតព្រោះវាអាចដោះស្រាយបញ្ហានៃរដ្ឋមួយដោយពន្លាតសមត្ថកិច្ចរបស់វា តែវាមិនអាចផ្តល់ឱ្យពួកគេនូវដំបូន្មានផ្នែកច្បាប់ដល់អាជ្ញាធរអន្តរជាតិណានោះទេ។

យោងតាមបញ្ជីរបស់តុលាការយុត្តិធម៌អន្តរជាតិវិញគឺ ទាំងលើបណ្តឹងជម្លោះរវាងរដ្ឋនិងប្រឹក្សាយោបល់ចាប់ពីបង្កើតមកមាន១៧៩ករណីមកហើយ[21]។ ខុសពីICC វាល់វិវាទរបស់ICJអាចត្រូវបានដោះស្រាយតាមមធ្យោបាយមួយក្នុងចំណោមវិធីបីយ៉ាង៖ (១) ពួកគេអាចដោះស្រាយដោយភាគីបានគ្រប់ពេលក្នុងពេលដំណើរការនីតិវិធី។ (២) រដ្ឋមួយអាចបញ្ឈប់ដំណើរការនីតិវិធីនិងដកខ្លួនចេញនៅចំណុចណាមួយ ឬ (៣) តុលាការអាចប្រកាសសាលក្រម។

### កថាខណ្ឌទី៣៖ ការអនុវត្តយុត្តាធិការ

មាត្រា១៣ នៃលក្ខន្តិកៈក្រុងរ៉ូមបានបញ្ជាក់ថា តុលាការនេះអាចអនុវត្តយុត្តាធិការរបស់ខ្លួនចំពោះបទល្មើសព្រហ្មទណ្ឌមានចែងក្នុងមាត្រា៥អនុលោមតាមបទបញ្ញត្តិទាំងឡាយនៃច្បាប់លក្ខន្តិកៈនេះបើ៖

ក) ស្ថានភាពដែលបទល្មើសព្រហ្មទណ្ឌមួយឬច្រើនបង្ហាញថាត្រូវបានប្រព្រឹត្តឡើង ត្រូវបានដាក់ជូនទៅព្រះរាជអាជ្ញាដោយរដ្ឋភាគីមួយអនុលោមតាមមាត្រា១៤។

[21] ចូរអានលម្អិតនៅគេហទំព័រ https://www.icj-cij.org/en/cases

ខ) ស្ថានភាពដែលបទល្មើសព្រហ្មទណ្ឌមួយ ឬច្រើនបង្ហាញថាត្រូវបានប្រព្រឹត្តឡើងត្រូវបានដាក់ជូនដោយព្រះរាជអាជ្ញាដោយក្រុមប្រឹក្សាសន្តិសុខតាមជំពូក៧នៃធម្មនុញ្ញអង្គការសហប្រជាជាតិ។

គ) ព្រះរាជអាជ្ញាបានផ្តួចផ្តើមការស៊ើបអង្កេតមួយពាក់ព័ន្ធ នឹង បទល្មើសព្រហ្មទណ្ឌនោះដោយអនុលោមតាមមាត្រា១៥នៃលក្ខន្តិកៈនេះ។

ចំពោះលក្ខខណ្ឌកគឺរដ្ឋភាគីអាំចដាក់ជូនព្រះរាជអាជ្ញានូវស្ថានភាពនៃបទល្មើសព្រហ្មទណ្ឌមួយឬ ច្រើនក្នុងដែនយុត្តាធិការតុលាការដែលបង្ហាញថា ត្រូវបានប្រព្រឹត្តឡើងដើម្បីស្នើព្រះរាជអាជ្ញាឱ្យធ្វើការស៊ើបអង្កេតក្នុងស្ថានភាពនោះក្នុងគោលបំណងជាក់លាក់លើនរណាម្នាក់ ឬ ច្រើននាក់ដើម្បីចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ។

ការដាក់ជូននោះត្រូវបញ្ជាក់ស្ថានភាពពាក់ព័ន្ធាមលទ្ធភាពធ្វើបានជាមួយសំអាងហេតុ។

តុលាការជា អ្នកកំណត់ករណីមួយមិនអាចទទួលយកបានទេបើ៖

ក) ករណីនោះត្រូវបានស៊ើបអង្កេត ឬនាំយកមកជំនុំជម្រះដោយរដ្ឋដែលមានយុត្តាធិការលើករណីនោះរួចហើយ លើកលែងតែរដ្ឋគ្មានឆន្ទៈ ឬលទ្ធភាពបើកការស៊ើបអង្កេតឬការនាំយកមកជំនុំជម្រះដោយពិតប្រាកដ

ខ) ករណីនេះត្រូវបានស៊ើបអង្កេតដោយ រដ្ឋដែលមានយុត្តាធិការលើករណីនោះហើយហើយរដ្ឋនោះបានសម្រេចមិននាំយកជនពាក់ព័ន្ធមកជំនុំជម្រះទេ លើកលែងតែសេចក្តីសម្រេចនោះកើតចេញពីលទ្ធផលនៃភាពគ្មានឆន្ទៈនិងអសមត្ថភាពរបស់រដ្ឋពិតប្រាកដ

គ) ជនពាក់ព័ន្ធត្រូវបានជំនុំជម្រះចំពោះអំពើដែលជាកម្មវត្ថុនៃពាក្យបណ្តឹងរួចហើយ ហើយការជំនុំជម្រះដោយតុលាការមិនត្រូវបានអនុញ្ញាត

ឃ) ករណីនោះមិនធ្ងន់ធ្ងរគ្រប់គ្រាន់ល្មមសម្រាប់ធ្វើយុត្តិកម្មសកម្មភាពបន្ត។

ចំណោទបញ្ហាគឺ ថាតើធ្វើដូចម្តេចដើម្បីកំណត់ពីភាពគ្មានឆន្ទៈរបស់រដ្ឋមួយ តាមលក្ខន្តិកៈនេះគេតម្រូវឱ្យតុលាការពិនិត្យមើល០៣លក្ខខណ្ឌគឺ៖

- តើករណីទាំងនោះបាន ឬ កំពុងយកដំណើរការ ឬ សេចក្តដីសម្រេចថ្នាក់ជាតិបានធ្វើឡើងក្នុងគោលបំណងបិទបាំងជនពាក់ព័ន្ធពីការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើសដែល ស្ថិតក្នុងយុត្តាធិការរបស់តុលាការទេ។
- តើមានការពន្យារពេលមិនសមហេតុផលក្នុងករណីរឿងក្តីនោះដែល ក្នុងស្ថានភាពនោះមិនស្របនឹងចេតនានាំយកជនពាក់ព័ន្ធមករកយុត្តិធម៌។

- តើករណីទាំងនោះបានដំណើរការដោយឯករាជ្យឬមិនលំអៀងហើយករណីរឿងក្តីទាំងនោះបាន ឬកំពុងដំណើរការដោយឯករាជ្យ ឬ មិនលំអៀងហើយករណីនោះកំពុងស្ថិតក្នុងរបៀបមួយដែលស្ថានភាពនោះមិនស្របនឹងចេតនានៃការនាំយកជនពាក់ព័ន្ធមករកយុត្តិធម៌។

រីឯការកំណត់អលទ្ធភាពក្នុងករណីជាក់លាក់មួយ តុលាការត្រូវ ពិចារណាថាដោយយោងលើការដួលរលំទាំងស្រុង ឬ ជាសារវន្ត ឬ អលទ្ធភាពនៃប្រព័ន្ធតុលាការជាតិមួយ ដូចថា រដ្ឋនោះគ្មានលទ្ធភាពទទួលបានជនជាប់ចោទ ឬ គ្មានភស្តុតាង និង សក្ខីកម្មចាំបាច់ ឬ បើមិនដូច្នោះទេ គ្មានលទ្ធភាពដំណើរការជម្រះករណីរឿងក្តីរបស់ខ្លួនបានទេឬ។

នៅពេលដែលស្ថានភាពមួយត្រូវបានដាក់ជូនទៅតុលាការស្របតាមមាត្រា១៣ ហើយព្រះរាជអាជ្ញាបានកំណត់ថា មានមូលដ្ឋានសមហេតុផលដើម្បីចាប់ផ្តើមការស៊ើបអង្កេត ឬ ក៏ព្រះរាជអាជ្ញាផ្តើមគំនិតធ្វើការស៊ើបអង្កេតពេលនោះព្រះរាជអាជ្ញាត្រូវជូនដំណឹងទៅគ្រប់រដ្ឋភាគីទាំងអស់ និង ទៅរដ្ឋទាំងឡាយណាដែលយកចិត្តទុកដាក់ចំពោះព័ត៌មានដែល មាននោះជាធម្មតាអាចអនុវត្តយុត្តាធិការលើរឿងនោះ បានព្រះរាជអាជ្ញារៀបជូនដំណឹងទៅរដ្ឋទាំងនោះដោយឈរលើមូលដ្ឋានជាសំងាត់ ដើម្បីការពារការបំផ្លាញចោលនូវភស្តុតាង ទប់ស្កាត់ការគេចខ្លួន ព្រះរាជអាជ្ញាអាចដាក់កំរិតដែនកំណត់នូវវិសាលភាពព័ត៌មានដែលត្រូវផ្តល់ទៅឱ្យរដ្ឋទាំងឡាយបាន។ នៅក្នុងរយៈពេលមួយខែ បន្ទាប់ពីទទួលបានសេចក្តីជូនដំណឹងនោះ រដ្ឋអាចជំរាបជូនទៅតុលាការថាខ្លួនកំពុងធ្វើការស៊ើបអង្កេត ឬ បានស៊ើបអង្កេតលើពលរដ្ឋរបស់ខ្លួន ឬ អ្នកផ្សេងដែលបានស្ថិតនៅក្នុងយុត្តាធិការរបស់ខ្លួនទាក់ទងនឹងអំពើល្មើសព្រហ្មទណ្ឌដែលអាចបង្កើតជា បទល្មើសព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា៥។

តាមការស្នើសុំរបស់រដ្ឋនោះ ព្រះរាជអាជ្ញាត្រូវទុកការស៊ើបអង្កេតទៅលើជនទាំងឡាយឱ្យរដ្ឋដែលស្នើសុំនោះជាអ្នកធ្វើការស៊ើបអង្កេត លើកលែងតែតាមការស្នើសុំរបស់ព្រះរាជអាជ្ញា សភាមុនការជំនុំជម្រះ (Pre-trial chamber) សំរេចអនុញ្ញាតឱ្យព្រះរាជអាជ្ញាធ្វើការស៊ើបអង្កេត។ ការទុកឱ្យព្រះរាជអាជ្ញាធ្វើការស៊ើបអង្កេតរបស់រដ្ឋត្រូវបើកឱ្យត្រួតពិនិត្យមើលដោយព្រះរាជអាជ្ញាក្នុងរយៈពេល៦ខែ នៃការទុកពេលដោយផ្អែកលើឆន្ទៈ ឬ គ្មានលទ្ធភាពរបស់រដ្ឋ។

ចំពោះតុលាការយុត្តិធម៌អន្តរជាតិវិញ តុលាការនេះបែងចែកពីររបៀបដាច់ពីគ្នា នៃការអនុវត្តយុត្តាធិការតុលាការគឺ របៀបលើបណ្តឹងរវាងរដ្ឋ និង ការសុំយោបល់។

ករណីបណ្តឹងអន្តររដ្ឋអ្នកដែលអាចចាប់ផ្តើមពាក្យបណ្តឹងបានមានតែរដ្ឋនៃជម្លោះប៉ុណ្ណោះគឺ មិនដូចICC ដែលផ្តល់សិទ្ធិអំណាចដែលរដ្ឋផ្សេង ដល់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិនិងដោយរដ្ឋអាជ្ញានោះទេ។

តុលាការមានសមត្ថកិច្ច ក្នុងការដោះស្រាយជម្លោះតែប្រសិនបើរដ្ឋទទួលយកយុត្តាធិការរបស់វាតាមវិធានរៀបរាប់។ រដ្ឋគ្មានតំណាងនៅតុលាការទេ ដូចនេះរដ្ឋត្រូវទាក់ទងជាមួយនឹងបញ្ជីកាតាមរយៈក្រសួងការបរទេសឬក៏ស្ថានទូតរបស់ពួកគេនៅហូឡង់។ នៅពេលដែលពួកគេបានក្លាយជា ភាគីនៃបណ្តឹងចំពោះមុខតុលាការពួកគេមានតំណាងដោយអន្តរការីដែលមានសិទ្ធិកាតព្វកិច្ចដូចជាមេធាវីនៅតុលាការជាតិ និងជាប្រមុខបេសកម្មការទូតពិសេសជាមួយនឹងអំណាចប្រព្រឹត្តលើរដ្ឋដើម្បីធ្វើការបញ្ជូនបន្តនូវការឆ្លើយតប និងឆ្លើយមិនទទួល ឬ ទទួលចុះហត្ថលេខាឬធ្វើការបញ្ជាក់។ នៅសវនាការសាធារណៈអន្តរការីនេះជា អ្នកបើការជំទាស់ក្នុងនោះមានជា រដ្ឋាភិបាលពួកគេតំណាង ។

ការបើកដំណើរក្តីអាចតាម០២របៀបៈ

តាមរយៈការជូនដំណឹងអំពីការព្រមព្រៀងពិសេសៈ ឯកសារដែលមានចរិតទ្វេភាគីអាចត្រូវប្តឹងទៅតុលាការដោយភាគីណាមួយឬទាំងពីរនៃរដ្ឋ។ កិច្ចព្រមព្រៀងពិសេសមួយត្រូវតែបញ្ជាក់ពីបញ្ហានៃជម្លោះ និងភាគី។ ដោយសារតែនឹងមិនមានរដ្ឋដាក់ពាក្យបណ្តឹង និងរដ្ឋឆ្លើយតបតុលាការនឹងសរសេរចំណងជើងដូចឧទាហរណ៍នេះBenin/Niger។

តាមរយៈមធ្យោបាយនៃការដាក់ពាក្យៈ ដោយមានចរិតជា ឯកត្តោភាគីត្រូវបានដាក់ជូនដោយរដ្ឋមួយប្រឆាំងនឹងរដ្ឋមួយគឺ មានចេតនាក្នុងការរក្សាលក្ខខណ្ឌអំពីប្រធានបញ្ហានៃជម្លោះ រដ្ឋដាក់ពាក្យបណ្តឹងត្រូវចង្អុលពីការទទួលស្គាល់យុត្តាធិការដោយសន្ធិសញ្ញាឬការប្រកាសពេលនោះតុលាការនឹង ធ្វើការដាក់ចំណងជើងបណ្តឹងដូចឧទាហរណ៍ថា Nicaragua v. Colombia។

កាលបរិច្ឆេទនៃការផ្តួចផ្តើមដំណើរការនីតិវិធីដែលជា ការទទួលដោយមន្ត្រីចុះបញ្ជីកិច្ចព្រមព្រៀងពិសេស ឬ ពាក្យស្នើសុំគឺជា ការកមណត់អំពីការបើកសវនាការនៅចំពោះមុខតុលាការ។ ដំណើរការនីតិវិធីដែលមានខ្លឹមសាររួមមានដំណាក់កាលជា លាយលក្ខណ៍អក្សរដែលក្នុងនោះភាគីទាំងពីរបានដាក់ឯកសារនិងផ្លាស់ប្តូរការតវ៉ាដែលមានសេចក្តីថ្លែងការណ៍លំអិតអំពីចំណុចនៃការពិត និងច្បាប់ដែលភាគីនីមួយៗពឹងផ្អែក និងដំណាក់កាលផ្ទាល់មាត់ដែលមានសវនាការជាសាធារណៈដែលភ្នាក់ងារនិងមេធាវីផ្តល់យោបល់ដល់តុលាការ។ ដោយសារតុលាការមានភាសាផ្លូវការពីរ (អង់គ្លេស និងបារាំង) អ្វីៗទាំងអស់ដែលសរសេរ ឬ និយាយ ជាភាសាមួយត្រូវបានបកប្រែទៅភាសាផ្សេងទៀត។ ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរមិនត្រូវបានផ្តល់ជូនដល់អ្នកសារព័ត៌មាន និងសាធារណៈជនឡើយរហូតដល់ការបើកសវនាការផ្ទាល់មាត់ហើយមានតែពេលនោះទេប្រសិនបើភាគីគ្មានការជំទាស់។

សាលក្រមគឺជា សេចក្តីសម្រេចចុងក្រោយដោយភ្ជាប់ភាគីទៅនឹងសំណុំរឿង និងដោយគ្មានការប្តឹងឧទ្ធរណ៍ ចៅក្រមណាដែលចង់ធ្វើដូច្នេះអាចដាក់បញ្ចូលមតិយោបល់ទៅក្នុងសាលក្រម។

តាមរយៈការចុះហត្ថលេខាលើធម្មនុញ្ញរដ្ឋជា សមាជិកនៃអង្គការសហប្រជាជាតិត្រូវគោរពតាមសេចក្តីសម្រេចរបស់តុលាការក្នុងករណីណាក៏ដោយដែលខ្លួនជាភាគី។ លើសពីនេះទៅទៀតសំណុំរឿងមួយអាចត្រូវបានបញ្ជូនទៅតុលាការហើយសំរេចដោយតុលាការ ប្រសិនបើភាគីទាំងពីរយល់ព្រមតាមមធ្យោបាយមួយ ឬផ្សេងទៀតចំពោះយុត្តាធិការរបស់ខ្លួនលើសំណុំរឿងនេះកម្រនឹងមានការសម្រេចចិត្តមិនអនុវត្ត។ រដ្ឋមួយដែលពិចារណាថាភាគីម្ខាងទៀតមិនបានបំពេញកាតព្វកិច្ចដែលមានស្រាប់តាមសាលក្រមដែលចេញដោយតុលាការអាចនាំរឿងនេះទៅក្រុមប្រឹក្សាសន្តិសុខដែលមានអំណាចណែនាំឬសម្រេចចិត្តលើវិធានការដែលត្រូវអនុវត្តដើម្បីឱ្យមានប្រសិទ្ធភាព ការវិនិច្ឆ័យ។

នីតិវិធីដែលបានពិពណ៌នាខាងលើគឺជា នីតិវិធីធម្មតា។ ទោះយ៉ាងណាក៏ដោយដំណើរនៃដំណើរការនីតិវិធីអាចត្រូវបានកែប្រែដោយដំណើរការចៃដន្យ។ កិច្ចដំណើរការនីតិវិធីដោយចៃដន្យទូទៅបំផុតគឺ ការជំទាស់បឋមដែលត្រូវបានលើកឡើងដើម្បីជំទាស់នឹងសមត្ថកិច្ចរបស់តុលាការក្នុងការសម្រេចលើរឿងក្តី (រដ្ឋដែលឆ្លើយតបអាចជំទាស់ឧទាហរណ៍ថាតុលាការខ្វះយុត្តាធិការឬថាពាក្យសុំមិនអាចទទួលយកបាន)។ បញ្ហានេះ គឺជារឿងមួយដែលតុលាការខ្លួនឯងជាអ្នកសម្រេច។ បន្ទាប់មកមានវិធានការណ៍បណ្តោះអាសន្នដែលរដ្ឋអាចស្នើសុំបានប្រសិនបើខ្លួនចាត់ទុកថាសិទ្ធិ ដែលបង្កើតជាកម្មវត្ថុនៃការដាក់ពាក្យរបស់ខ្លួនស្ថិតក្នុងគ្រោះថ្នាក់ភ្លាមៗ។ លទ្ធភាពទីបីគឺ ថារដ្ឋអាចស្នើសុំការអនុញ្ញាតអន្តរាគមន៍នៅក្នុងជម្លោះដែលពាក់ព័ន្ធនឹងរដ្ឋផ្សេងទៀតប្រសិនបើខ្លួនយល់ឃើញថាវាមានផលប្រយោជន៍ចំពោះលក្ខណៈស្របច្បាប់នៃករណីដែលអាចប៉ះពាល់ដល់ការសម្រេចចិត្ត។ លក្ខន្តិកៈនេះក៏មានចែងអំពីករណីដែល រដ្ឋឆ្លើយតបមិនចូលខ្លួនមកបំភ្លឺនៅចំពោះមុខតុលាការមិនថាដោយសារតែរដ្ឋនោះបដិសេធយុត្តាធិការរបស់តុលាការទាំងស្រុងឬដោយមូលហេតុផ្សេងទៀត។ ការខកខានដោយភាគីម្ខាងមិនបង្ហាញខ្លួនឱ្យឃើញគឺ មិនរារាំងដំណើរការនីតិវិធីរបស់ខ្លួនឡើយទោះបីតុលាការត្រូវបំពេញបន្ថែមខ្លួនឯងថាខ្លួនមានយុត្តាធិការក៏ដោយ។ តុលាការគួតែស្វែងរកថាភាគីច្រើនទៀតគ្រោងនឹងដាក់ដំណើរការដាច់ដោយឡែកក្នុងការដាក់ជូនបញ្ហាដូចគ្នា និងការដាក់ជូនប្រឆាំងនឹងទំនាក់ទំនងបញ្ហាដូចគ្នានោះដំណើរការនឹងចាប់ផ្តើម។ តុលាការបដិសេធកាតព្វកិច្ចរបស់ខ្លួនក្នុងនាមជាតុលាការពេញលេញ ប៉ុន្តែតាមការស្នើសុំរបស់ភាគីតុលាការក៏អាចបង្កើតអង្គជំនុំជម្រះពិសេសដើម្បីពិនិត្យសំណុំរឿងជាក់លាក់។ អង្គជំនុំជម្រះនៃនីតិវិធីសង្ខេបត្រូវបានតុលាការតែងតាំងជារៀងរាល់ឆ្នាំស្របតាមលក្ខន្តិកៈរបស់ខ្លួន។

ការអនុវត្តយុត្តាធិការរបស់តុលាការយុត្តិធម៌អន្តរជាតិនេះគឺ ត្រូវស្របតាម ប្រភពនៃច្បាប់ដែលតុលាការត្រូវអនុវត្តគឺៈ សន្ធិសញ្ញានិងអនុសញ្ញាអន្តរជាតិជាធរមាន។ ទំនៀមទម្លាប់អន្តរជាតិ គោលការណ៍ទូទៅនៃច្បាប់ ការសម្រេចចិត្តរបស់តុលាការ និងយុត្តិសាស្ត្រ។ ចំណែកច្បាប់ដែលត្រូវយកមកអនុវត្តក្នុងបទល្មើសព្រហ្មទណ្ឌនៃតុលាការព្រហ្មទណ្ឌគឺ ទីមួយច្បាប់លក្ខន្តិកៈនេះ ធាតុនៃបទល្មើសព្រហ្មទណ្ឌ និងវិធាននៃនីតិវិធីនិងភស្តុតាងរបស់តុលាការ និងទីពីរសន្ធិសញ្ញា និងគោលការណ៍និងវិធាននៃច្បាប់អន្តរជាតិដែលអាចយកមកអនុវត្តបាន ដោយរួមបញ្ចូលទាំងគោលការណ៍នៃច្បាប់អន្តរជាតិស្តីពីជម្លោះប្រដាប់អាវុធ។ លក្ខខណ្ឌទីបីនោះគឺ តុលាការអាចទាញយកច្បាប់ជាតិរបស់ប្រព័ន្ធច្បាប់ទាំងឡាយរបស់ពិភពលោកដែលស្របនឹងច្បាប់អន្តរជាតិ និង បទដ្ឋានអន្តរជាតិ។

សំណុំរឿងអាចត្រូវបានសន្និដ្ឋាន នៅដំណាក់កាលណាមួយនៃដំណើរការនីតិវិធីដោយការដោះស្រាយរវាងភាគី ឬ ដោយការមិនបន្ត។ ក្នុងករណីចុងក្រោយរដ្ឋដែលដាក់ពាក្យស្នើសុំអាចជូនដំណឹងដល់តុលាការបានគ្រប់ពេលថាខ្លួនមិនចង់បន្តនីតិវិធីនោះទេបើមិនដូច្នោះទេភាគីទាំងពីរអាចប្រកាសថា ពួកគេយល់ព្រមដកសំណុំរឿងនេះចេញ។ បន្ទាប់មកតុលាការដកសំណុំរឿងចេញពីបញ្ជីរបស់ខ្លួន។

ចំពោះករណីប្រឹក្សាយោបល់វិញគឺ ដំណើរការស៊ើបអង្កេតនៅចំពោះមុខតុលាការគឺបើកចំហចំពោះតែអង្គការចំនួនប្រាំរបស់អង្គការសហប្រជាជាតិ និងទីភ្នាក់ងារឯកទេសចំនួន១៦ ដែលស្ថិតជាគ្រួសារ ឬ អង្គការសម្ព័ន្ធរបស់អង្គការសហប្រជាជាតិ ហើយមានតែមហាសន្និបាតអង្គការសហប្រជាជាតិ និងក្រុមប្រឹក្សាសន្តិសុខអាចស្នើសុំយោបល់យោបល់លើ សំណួរផ្នែកច្បាប់ណាមួយ។

នៅពេលដែលតុលាការទទួលបានការស្នើសុំយោបល់ប្រឹក្សាតុលាការត្រូវតែ ប្រមូលផ្តុំនូវអង្គហេតុទាំងអស់ហើយដូច្នេះត្រូវផ្តល់សិទ្ធិអំណាចក្នុងដំណើរការសវនាការជាលាយលក្ខណ៍អក្សរ និងផ្ទាល់មាត់ស្រដៀងទៅនឹងករណីដែលមានជម្លោះដែរ។ តាមទ្រឹស្តីតុលាការអាចធ្វើបានដោយគ្មានដំណើរការនីតិវិធីបែបនេះក៏បានដែរ។

ពីរបីថ្ងៃបន្ទាប់ពីសំណើត្រូវបានដាក់ជូន តុលាការបានរៀបចំបញ្ជីឈ្មោះរដ្ឋ និងអង្គការអន្តរជាតិដែលទំនងជាអាចផ្តល់ព័ត៌មានអំពីសំណួរនេះនៅចំពោះមុខតុលាការ។ រដ្ឋបែបនេះមិនស្ថិតនៅក្នុងជំហរដូចភាគីក្នុងដំណើរការវិវាទទេគឺ តំណាងរបស់ពួកគេនៅចំពោះមុខតុលាការមិនត្រូវបានគេដឹងថាជា ភ្នាក់ងារនោះទេហើយការចូលរួមរបស់ពួកគេនៅក្នុងដំណើរការប្រឹក្សាមិនធ្វើឱ្យមតិរបស់តុលាការមានកាតព្វកិច្ចលើពួកគេឡើយ។ ជាធម្មតារដ្ឋដែលបានចុះបញ្ជីគឺជា រដ្ឋសមាជិកនៃអង្គការដែលស្នើសុំយោបល់។ រដ្ឋណាមួយដែលមិនត្រូវបានពិគ្រោះយោបល់ដោយតុលាការអាចសុំឱ្យមានក៏បានដែរ។

កិច្ចដំណើរការនីតិវិធីជាលាយលក្ខណ៍អក្សរមានរយៈពេលខ្លីជាងនៅក្នុងដំណើរការវិវាទរវាងរដ្ឋ ហើយច្បាប់ដែលគ្រប់គ្រងពួកគេអាចបត់បែនបាន។ អ្នកចូលរួមអាចសរសេរសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរដែលពេលខ្លះបង្កើតជាកម្មវត្ថុនៃការបញ្ចេញមតិដោយអ្នកចូលរួមដទៃទៀត។ សេចក្តីថ្លែងការណ៍និងយោបល់ដែលបានសរសេរត្រូវបានចាត់ទុកថាជាការសម្ងាត់តែក្រោយមកត្រូវបានបង្ហាញជា សាធារណៈនៅដើមដំបូងនៃដំណើរការសវនាការផ្ទាល់មាត់។

### កថាខណ្ឌទី៤៖ ការបញ្ចប់យុត្តាធិការ

សមាជិករដ្ឋសភាប៊ូរុនឌីនៅឆ្នាំ២០១៦ បានបោះឆ្នោតដកខ្លួនចេញពីលក្ខន្តិកៈទីក្រុងរ៉ូមដែលជា សន្ធិសញ្ញាបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC)។ ការសម្រេចនេះកើតឡើង ៦ ខែបន្ទាប់ពី ICC បានបើកការស៊ើបអង្កេតបឋមទៅលើអំពើហឹង្សាដែលបានផ្ទុះឡើងនៅក្នុងខែមេសាឆ្នាំ២០១៥។ មជ្ឈដ្ឋានយល់ឃើញថាប្រទេសអាហ្វ្រិកខាងកើតនេះនឹងដើរតាមគន្លងប្រទេសអាក្រក់ៗ ជាសមាជិកទីមួយដែលបោះបង់ចោល ICC ដោយផ្តាច់ខ្លួនចេញពីសហគមន៍អន្តរជាតិ។

លុះដល់ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៨ តុលាការឧក្រិដ្ឋកម្មអន្តរជាតិត្រូវបានជូនដំណឹងជា ផ្លូវការដោយអង្គការសហប្រជាជាតិថាសាធារណរដ្ឋហ្វីលីពីននៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៨ បានដាក់សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការដកខ្លួនចេញពីលក្ខន្តិកៈទីក្រុងរ៉ូមដែលជា សន្ធិសញ្ញាស្ថាបនារបស់តុលាការ ដែលមានអគ្គលេខាធិការអង្គការសហប្រជាជាតិជា អ្នករក្សាទុកនូវលក្ខន្តិកៈ។ តុលាការសោកស្តាយចំពោះការវិវត្តចុងក្រោយនេះហើយបានត្រឹមលើកទឹកចិត្តឱ្យហ្វីលីពីនជាគ្រួសាររបស់តុលាការនេះ។

ក្រោមសន្ធិសញ្ញាដែលបង្កើត ICC ដែលត្រូវបានគេស្គាល់ថាជា លក្ខន្តិកៈទីក្រុងរ៉ូម គឺតុលាការអាចធ្វើអន្តរាគមន៍បានលុះត្រាតែរដ្ឋទាំងឡាយមិនមានឆន្ទៈឬមិនអាចកាត់ទោសឧក្រិដ្ឋកម្មដោយខ្លួនឯងប៉ុណ្ណោះ។

ការដកខ្លួនចេញពីលក្ខន្តិកៈទីក្រុងរ៉ូមគឺជា ការសម្រេចរបស់អធិបតេយ្យភាពដែលជាកម្មវត្ថុនៃមាត្រា១២៧ នៃលក្ខន្តិកៈនោះ[22] ។ ការដកខ្លួននេះនឹងមាននប្រសិទ្ធិភាពមួយឆ្នាំបន្ទាប់ពីការជូនដំណឹងអំពីការដកសមាជិកភាពទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ។ ដោយយោងតាមកថាខណ្ឌទី២ នៃមាត្រា១២៧ គឺការខ្លួនរបស់រដ្ឋមួយនឹងមិនរួចបន្ទុកបានទេចំពោះកាតព្វកិច្ចដែលកើតចេញពីច្បាប់លក្ខន្តិកៈនេះ នៅក្នុងកំឡុងពេលដែលខ្លួនជាភាគី នៃច្បាប់លក្ខន្តិកៈនោះទេ រួមទាំងកាតព្វកិច្ចខាងហិរញ្ញវត្ថុដែលជំពាក់ផង។ ជាងនេះ ការដកខ្លួនរបស់រដ្ឋគឺគ្មានឥទ្ធិពលលើសហប្រតិបត្តិការនានា ជាមួយនឹងតុលាការរឿងស៊ើបអង្កេតព្រហ្មទណ្ឌ និងដំណើរ

[22] មាត្រា១២៧៖ អំពីការដកខ្លួនចេញ បានចែងថា រដ្ឋភាគីមួយដោយជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអគ្គលេខាធិការអង្គការសហប្រជាជាតិអាចដកខ្លួនចេញពីច្បាប់លក្ខន្តិកៈនេះបាន។ ការដកខ្លួនចេញនេះមានប្រសិទ្ធភាពក្នុងរយៈពេលមួយឆ្នាំបន្ទាប់ពីថ្ងៃដែលបានជូនដំណឹង លើកលែងតែការជូនដំណឹងនេះមានការបញ្ជាក់កាលបរិច្ឆេទដែលយូរជាងមួយឆ្នាំ។

ការជំនុំជម្រះរឿងក្តីនានាទាក់ទងនឹងរដ្ឋដែលដកខ្លួនមានកាតព្វកិច្ចត្រូវសហប្រតិបត្តិការ និងដែលបានចាប់ផ្តើមឡើងនៅមុនការពិចារណាជាបន្តលើបញ្ហាណាមួយដែលឋិតក្រោមការពិចារណាដោយតុលាការរួច ជាស្រេចមុនកាលបរិច្ឆេទដកខ្លួនទេ។ ម្ល៉ោះហើយដូចក្នុងរឿងក្តីហ្វីលីពីនគឺរដ្ឋអាជ្ញានៅតែប្រកាន់ជំហរមានសមត្ថកិច្ចដដែល។ គេក៏មានវិធីមួយទៀតគឺ តាមលក្ខណៈជាក់ស្តែងនៅពេលដែលប្រទេសមួយដកខ្លួនចេញពីលក្ខន្តិកៈទីក្រុងរ៉ូម ICC នឹងបាត់បង់យុត្តាធិការលើប្រទេសនោះ។ ព្រះរាជអាជ្ញាត្រូវបានអនុញ្ញាតឱ្យចាប់ផ្តើមការស៊ើបអង្កេតបឋម ឬការស៊ើបអង្កេតលើឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយជនជាតិ ឬ នៅលើទឹកដីនៃរដ្ឋភាគី។ ប្រទេសដែលមិនមែនជាសមាជិករបស់ICCស្ថិតនៅក្រៅលទ្ធភាពរបស់ខ្លួន លុះត្រាតែក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិនិយាយជាពិសេសអំពីស្ថានភាពនេះទៅតុលាការ។ យន្តការនេះត្រូវបាន អនុវត្តលើករណីស៊ូដង់និងលីប៊ីដែលនាំឱ្យមានការចោទប្រកាន់ប្រធានាធិបតីអាល់បាសៀនិងអតីតប្រធានាធិបតីលីប៊ីមួអាម៉ាហ្កាដាហ្វីនោះ។

ប្រសិនបើយុត្តាធិការ និងភាពស្របច្បាប់របស់ ICC កាន់តែធ្លាក់ចុះហើយបណ្តាប្រទេសកាន់តែដកថយសហគមន៍អន្តរជាតិនឹងត្រូវពឹងផ្អែកលើក្រុមប្រឹក្សាសន្តិសុខដើម្បីបញ្ជូនសំណុំរឿងទៅតុលាការ។ ពោលគឺ គេមើលឃើញថា នៅពេលដែលរដ្ឋជាច្រើនគំរាមកំហែងដកខ្លួនចេញពីលក្ខន្តិកៈទីក្រុងរ៉ូមនៅពេលដែលពួកគេស្ថិតក្រោមការត្រួតពិនិត្យការបញ្ជូនក្រុមប្រឹក្សាសន្តិសុខគឺជា មធ្យោបាយតែមួយគត់ដើម្បីរក្សាតុលាការជាស្ថាប័នដែលមានមុខងារ។

សម្រាប់ការបញ្ចប់យុត្តាធិការរបស់ICJគឺ ពុំមានបញ្ជាក់ដូចការដកខ្លួនពីលក្ខន្តិកៈរបស់តុលាការនេះ ឬអ្វីនោះទេដោយហេតុថា ក្រៅពីការទទួលស្គាល់លក្ខន្តិកៈរបស់តុលាការមានន័យថាជា សមាជិករបស់តុលាការមួយនេះ ការទទួលស្គាល់យុត្តាធិការរបស់តុលាការមានដល់ទៅបួនរបៀបទៅហើយគឺដោយឯកត្តោភាគី ដោយសន្ធិសញ្ញា ដោយកិច្ចព្រមព្រៀងពិសេស និងដោយសេចក្តីប្រកាសផងនោះ។ ម្ល៉ោះហើយ មានតែការបញ្ញត្តិនៅក្នុងអវសានប្បញ្ញត្តិទេដែលអាចបញ្ជាក់ថាតើផ្តល់ ឬ លែងផ្តល់អំណាចយុត្តាធិការឱ្យតុលាការមួយនេះបាន។ ប៉ុន្តែភាគច្រើនវិវាទទាំងនោះតែងតែប្រគល់ជូនតុលាការអន្តរជាតិដើម្បីរក្សាប្រយោជន៍សម្ភហភាព និងបុព្វហេតុយុត្តិធម៌របស់ជាតិឬរដ្ឋមួយហើយ។

## ករណីសិក្សាស្តីពីយុត្តាធិការតុលាការយុត្តធម៌អន្តរជាតក្នុងសំណុំរឿងក្តីប្រាសាទព្រះវិហារ

អង្គហេតុៈ ទទួលបានឯករាជ្យមិនបានប៉ុន្មានខែផងពីបារាំង ថៃបានបង្កប្រទូស្តរាយមកកាន់កម្ពុជាដោយប៉ុនប៉ងដណ្តើមបូជនីយដ្ឋានប្រវត្តិសាស្ត្រប្រាសាទព្រះវិហារតាមរយៈការបញ្ជូនប្រដាប់អាវុធ។ កម្ពុជាអស់រយៈពេលប្រមាណជា៤ឆ្នាំ បានធ្វើបណ្តឹងការទូតទៅកាន់ប្រទេសជិតខាងនេះជាច្រើនលើកច្រើនសារតែពុំមានដំណោះស្រាយសោះ។ ជាហេតុធ្វើឱ្យកម្ពុជាងាករកការដោះស្រាយវិវាទអន្តររដ្ឋតាមរយៈយន្តការតុលាការ។ ដោយនៅថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៥៩ កម្ពុជាបានដាក់ពាក្យបណ្តឹងទៅតុលាការយុត្តិធម៌អន្តរជាតិ ក្រុងឡាអេ នៅដើម្បីស្នើសុំឲ្យតុលាការប្រគល់អធិបតេយ្យដែនដីលើប្រាសាទព្រះវិហារមកឲ្យកម្ពុជា និងទាមទារឲ្យថៃដកកងកម្លាំងប្រដាប់អាវុធទាំងអស់ចេញពីប្រាសាទ។ ក្រោយពីទទួលបានបណ្តឹងនេះរួច នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៥៩ តុលាការបានចេញដីកាបង្គាប់ កំណត់កាលបរិច្ឆេទ ដែលកម្ពុជា និងថៃត្រូវបញ្ជូនសារណា និងសារណាតបទៅតុលាការ។ សារណារបស់កម្ពុជាត្រូវបានបញ្ជូនទៅដល់ដៃតុលាការ តាមពេលកំណត់។ ចំណែកថៃវិញ ដល់ពេលកំណត់ត្រូវបញ្ជូនសារណាតប ថៃបែរជាបានបញ្ជូនពាក្យបណ្តឹងមួយ បដិសេធមិនទទួលស្គាល់សមត្ថកិច្ចរបស់តុលាការអន្តរជាតិ ក្នុងការជំនុំជម្រះបណ្តឹងរបស់កម្ពុជា។ ក្នុងបណ្តឹងនោះថៃបានបញ្ជាក់ពីអញ្ញត្រកម្មបឋមរបស់ខ្លួនចំនួនពីរដែលក្នុងនោះអញ្ញត្របឋមទី១គឺ ថៃហាក់មានបំណងរារាំងមិនឱ្យតុលាការអនុវត្តយុត្តាធិការលើបណ្តឹងមកកាន់ខ្លួននោះទេ។ ការជំទាស់ដំបូងរបស់រដ្ឋាភិបាលថៃគឺថាសេចក្តីប្រកាសរបស់ថៃនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៥០ ដោយមានបំណងចង់បន្តរយៈពេល ១០ ឆ្នាំបន្ថែមទៀតនៃការប្រកាសថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩២៩ ដែលរដ្ឋាភិបាលប្រទេសនេះទទួលស្គាល់ថាជាកាតព្វកិច្ចipso Facto និងដោយគ្មានអនុសញ្ញាពិសេសណាមួយនៅក្នុងលក្ខខណ្ឌនៃទៅវិញទៅមក។ ថៃថាយុត្តាធិការរបស់តុលាការអចិន្ត្រៃយ៍អន្តរជាតិគឺ គ្មានប្រសិទ្ធភាពទេព្រោះសេចក្តីប្រកាសថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩២៩ បានបញ្ចប់តាមការរំលាយតុលាការអចិន្ត្រៃយ៍នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៤៦។ ថៃថាខ្លួនគេមិនត្រូវបានអញ្ជើញឱ្យចូលរួមនៅសាន់ហ្វ្រាន់ស៊ីស្កូទេសន្និសីទឆ្នាំ១៩៤៥ ហើយជា លទ្ធផលមិនមែនជាហត្ថលេខី នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិរួមទាំងលក្ខន្តិកៈនៃតុលាការយុត្តិធម៌ជាតិអន្តរជាតិគឺ ថៃចូលជាសមាជិកអង្គការនេះដល់ទៅ៨ខែក្រោយ។ ថៃរៀបរាប់អង្គហេតុថានៅពេលដែលប្រទេសថៃបានក្លាយជា ភាគីនៃលក្ខន្តិកៈរបស់តុលាការនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៤៦ គឺ គេចាត់ទុកថារដ្ឋដែលបានប្រកាសទទួលយកយុត្តាធិការជាកាតព្វកិច្ចរបស់តុលាការអចិន្ត្រៃយ៍ ហើយបានក្លាយជាភាគី

នៃលក្ខន្តិកៈ នៃតុលាការអន្តរជាតិមុនពេលផុតកំណត់នៃសុពលភាពនៃសេចក្តីប្រកាសនោះត្រូវបានចាត់ទុកថាយល់ព្រមទទួលយកយុត្តាធិការជាកាតព្វកិច្ចរបស់តុលាការអន្តរជាតិ ក្នុងរយៈពេលដែលនៅសល់ប៉ុណ្ណោះ។ ភាគីថៃក៏ថាខ្លួនគេមិនបានធ្វើការប្រកាសទទួលយកយុត្តាធិការដែលមានចែងក្នុងតុលាការឡើយនៅពេលដែលថៃបានចូលអង្គការសហប្រជាជាតិ។ ថៃប្រកែកថា ក្នុងសំណុំរឿងឧប្បទ្វហេតុលើអាកាសរវាងអ៊ីស្រាអែលនឹងប៊ុលហ្គារី គឺតុលាការបានសំរេចក្នុងករណី មាត្រា៣៦(៥)ភ្ជាប់តែរដ្ឋដែលត្រូវបានតំណាងនៅក្នុងសន្និសីទសាន់ហ្វ្រាន់ស៊ីស្កូ និងជាហត្ថលេខីនៃធម្មនុញ្ញអង្គការសហប្រជាជាតិ។ រដ្ឋាភិបាលថៃថា ចាប់ពីថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៥០ ថៃមិនដែលស្ថិតនៅក្រោមកាតព្វកិច្ចទទួលស្គាល់យុត្តាធិការជា កាតព្វកិច្ចរបស់តុលាការជាតិអន្តជាតិនៃកាតព្វកិច្ចថ្មីនោះទេ។

សេចក្តីសម្រេចអញ្ញត្រកម្មបឋមទី១របស់ថៃ៖ សវនាការសាធារណៈ ដើម្បីជុំនំជម្រះលើបណ្តឹងទាស់របស់ថៃ ត្រូវបានបើកធ្វើ ចាប់ពីថ្ងៃទី១០ រហូតដល់ថ្ងៃទី១៥ មេសា ឆ្នាំ១៩៦០។ គណៈប្រតិភូតំណាងភាគីកម្ពុជាដឹកនាំដោយលោកទ្រឿង កាង សមាជិកឧត្តមក្រុមប្រឹក្សារាជបល្ល័ង្ក អមដោយអ្នកច្បាប់ល្បីឈ្មោះពីរនាក់ដែលម្នាក់ជាមេធាវីប្រចាំតុលាការកំពូលអាមេរិក និងម្នាក់ទៀតជាសាស្ត្រាចារ្យច្បាប់បារាំង។ ចំណែកខាងភាគីថៃដឹកនាំដោយព្រះអង្គម្ចាស់ វ៉ង់សាម៉ាហ៊ីប ចាយ៉ាន់គូរ៉ា ឯកអគ្គរាជទូតថៃប្រចាំប្រទេសហូឡង់។

នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៦១ តុលាការក្រុងឡាអេបានចេញសេចក្តីសម្រេចច្រានចោលបណ្តឹងជំទាស់របស់ថៃ ហើយប្រកាសថា តុលាការមានសមត្ថកិច្ចពេញលេញក្នុងការជំនុំជម្រះលើបណ្តឹងរបស់កម្ពុជា។ នៅក្នុងសាលក្រមរបស់ខ្លួនតុលាការបានក្នុងសម្គាល់ថាកម្ពុជាបានរក្សាខ្លួនជា គោលការណ៍ទទួលយកយុត្តាធិការដាច់ខាតរបស់តុលាការ ហើយបានបញ្ជាក់ទៀតថា សេចក្តីប្រកាសរបស់ថៃដែលធ្វើឡើងនៅថ្ងៃទី២០ ឧសភា ឆ្នា១៩៥០ មានលក្ខណៈដូចនេះថា ខ្ញុំមានកិត្តិយសក្នុងការជម្រាបជូនអ្នកថា សេចក្តីប្រកាសថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩២៩ រដ្ឋាភិបាលរាជាណាចក្រនេះបានទទួលយកយុត្តិធិការតុលាការនេះស្របតាមមាត្រា៣៦ កថាខណ្ឌទី២ នៃលក្ខន្តិកៈនេះសម្រាប់រយៈពេល១០ឆ្នាំ និងលក្ខណៈតប។ សេចក្តីប្រកាសនោះបានធ្វើឱ្យថ្មីនៅថ្ងៃទី៣ ខែឧសភា ឆ្នាំ១៩៤០ ក្នុងរយៈពេល១០ឆ្នាំទៀត។ ស្របទៅតាមមាត្រា៣៦ កថាខណ្ឌទី៤ នៃលក្ខណៈនេះ តុលាការយុត្តិធម៌មានកិត្តិយសដើម្បីជូនដំណឹងដល់អ្នកអំពីរដ្ឋាភិបាលរបស់លោកជំទាវសូមបន្តសេចក្តីប្រកាសខាងលើបានលើកឡើងក្នុងរយៈពេល១០ ឆ្នាំបន្ថែមទៀតចាប់ពីថ្ងៃទី៣ ខែឧសភា ឆ្នាំ១៩៥០ ដែលមានដែនកំណត់និងមានលក្ខខណ្ឌដូចគ្នា និងការកក់ទុកដូចមានចែងនៅក្នុងសេចក្តីប្រកាសដំបូងនៃខែកញ្ញា ទី២០ ១៩២៩ ។

ប្រទេសថៃបានលើកឡើងនូវអញ្ញត្រកម្មបឋមជា មូលដ្ឋានក្នុងការមិនទទួលយកផ្នែកនៃយុត្តាធិការរបស់តុលាការ។ តុលាការចង្អុលថា ថៃបានបដិសេធមានចេតនាពេញលេញមិនទទួលយុត្តាធិការតុលាការ ហើយបានយកករណីឧបទ្ទវហេតុយន្តហោះអ៊ីស្រាអែលប៊ុលហ្គារីនៃខែឧសភា ឆ្នាំ១៩៥៩ មកសំអាងថាគ្មានប្រសិទ្ធភាពទៀតផង។ ត្រង់មាត្រា៣៦ កថាខណ្ឌទី៥ នៃយុត្តាធិការតុលាការដែលចែងថា ការប្រកាសក្រោមមាត្រា៣៦ នៃលក្ខន្តិកៈតុលាការអចិន្ត្រៃយ៍យុត្តិធម៌អន្តរជាតិនៅតែមានជា ធរមានត្រូវបានចាត់ទុកដោយរដ្ឋភាគីនៃលក្ខន្តិកៈបច្ចុប្បន្នត្រូវយល់ព្រមចំពោះយុត្តាធិការដាច់ខាត នៃតុលាការយុត្តិធម៌អន្តរជាតិអំឡុងពេលដែលពួកគេត្រូវដំណើរការស្របតាមលក្ខខណ្ឌរបស់ពួកគេ។

ត្រង់ចំណុចនេះតុលាការកាត់ក្តីថា តុលាការបានចាត់ទុកថាបទប្បញ្ញត្តិនោះអនុវត្តចំពោះតែភាគីដើមនៃលក្ខន្តិកៈប៉ុណ្ណោះហើយប៊ុលហ្គារីមិនបានក្លាយជា ភាគីនៃលក្ខន្តិកៈទេរហូតដល់ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៥៥ ការប្រកាសរបស់ប៊ុលហ្គារីអំពីការទទួលយកយុត្តាធិការជា កាតព្វកិច្ចដែលត្រូវចាត់ទុកថា បានផុតកំណត់នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៤៦ ជាថ្ងៃដែលតុលាការអចិន្ត្រៃយ៍បានឈប់ដំណើរការ។ ក្នុងករណីបច្ចុប្បន្ននេះប្រទេសថៃបានដំណើរការដោយឈរលើមូលដ្ឋានដែលជំហររបស់ថៃគឺ ដូចទៅនឹងប៊ុលហ្គារីដែរព្រោះថៃបានក្លាយជាភាគីនៃលក្ខន្តិកៈតែនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៤៦ ប្រហែលប្រាំបីខែបន្ទាប់ពីការស្លាប់របស់តុលាការអចិន្ត្រៃយ៍។ យុត្តាធិការដាច់ខាតរបស់តុលាការគឺនឹងមិនបំលែងជា ការយល់ព្រមនឹងតុលាការបច្ចុប្បន្នទេ។ ហើយអ្វីដែលថៃបានធ្វើគឺ ការបន្តឡើងវិញដែលមិនទទួលយកយុត្តាធិការដែលមិនបានកើតឡើង។ តុលាការមិនបានសម្រេចថា សេចក្តីសម្រេចឆ្នាំ១៩៥៩ មានលើថៃក្រៅពីការពិតថា សេចក្តីសម្រេចមិនអាចចាប់បង្ខំរវាងភាគីទេ តុលាការមើលឃើញថា ថៃតាមសេចក្តីប្រកាសថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៥០ បានទុកខ្លួនឯងគឺជា រឿងខុសគ្នាពីប៊ុលហ្គារី។ ក្នុងអំឡុងពេលនោះ មិនត្រឹមតែសេចក្តីប្រកាសរបស់ថៃឆ្នាំ១៩៤០ មិនដែលត្រូវបានបំប្លែងជាការទទួលយកយុត្តាធិការដាច់ខាតុលាការបច្ចុប្បន្នទេ ប៉ុន្តែវាផុតកំណត់ដោយលក្ខខណ្ឌ ឬ បស់វាពីរសប្តាហ៍មុនថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៥០។ ការប្រកាសនៅថ្ងៃទី២០ ខែឧសភាមក ជាឧបករណ៍ឯករាជ្យថ្មីដែលមិនបាធ្វើឡើងតាមមាត្រា៣៦(៥) នៃលក្ខណៈដែលថៃលើកឡើងមកបារម្ភនោះទេ។ ពេលនោះតុលាការបានលើកយកពីអានុភាពនៃឧបករណ៍ច្បាប់មកសំអាងគឺ សុពលភាពនៃការប្រកាសឆ្នាំ១៩៥០ ទៅវិញជាចំណោទវិនិច្ឆ័យ។ តុលាការយល់ឃើញថា ថៃបានមានកំហុសនៃការយល់លើភាសារបស់ខ្លួនដែលដើម្បីចង់សម្រេចបំណងរបស់ខ្លួនហើយថាការយល់ច្រឡំអង្គច្បាប់គឺជាបញ្ហាធ្ងន់ធ្ងរដែលមិនមែនជាលេសបាននោះទេ។ តុលាការថាបានសិនជាថៃចង់រក្សាទុកគឺថៃត្រូវបញ្ជូនឯកសារផ្លូវការទៅកាន់អគ្គលេខាធិការអង្គការសហប្រជាជាតិ ហើយបើពិនិត្យគឺក៏ពុំមានតុលាការណាផ្សេងក្រៅពីតុលាការនេះដែលថៃបន្តផ្តល់យុត្តាធិការដាច់ខាតបន្ថែមដែរសម្រាប់ហេតុផល

នោះដែលបានប្រើនៅក្នុងភាសាសេចក្តីប្រកាសរបស់នាងដែលការសម្រេចចិត្តនៅឆ្នាំ១៩៥៩ បានបង្ហាញថាមិនគ្រប់គ្រាន់ដើម្បីសម្រេចគោលបំណងរបស់ខ្លួន។ ប្រសិនបើតុលាការអនុវត្តការបកស្រាយធម្មតារបស់ខ្លួនសេចក្តីប្រកាសនោះគ្មានន័យអ្វីក្រៅពីការទទួលយកយុត្តាធិការជា កាតព្វកិច្ចរបស់តុលាការបច្ចុប្បន្នឡើយព្រោះគ្មានតុលាការផ្សេងទៀតដែលអាចទាក់ទងបានឡើយ។ ប្រទេសថៃដែលបានដឹងយ៉ាងច្បាស់អំពីការមិនមានវត្តមានរបស់តុលាការអាចថាគ្មានគោលបំណងអ្វីផ្សេងទៀតក្នុងការនិយាយទៅកាន់ អគ្គលេខាធិការអង្គការសហប្រជាជាតិតាមកថាខ័ណ្ឌ៤ នៃមាត្រា៣៦ នៃលក្ខន្តិកៈជាជាងទទួលស្គាល់យុត្តាធិការជាកាតព្វកិច្ចរបស់តុលាការបច្ចុប្បន្ន ។ សេចក្តីប្រកាសដែលនៅសេសសល់ត្រូវតែបកស្រាយតាមពន្លឺនៃការពិតសំខាន់នេះនិងនៅក្នុងបរិបទទូទៅនៃសេចក្តីប្រកាស។ សេចក្តីយោងទៅនឹងសេចក្តីប្រកាសឆ្នាំ១៩២៩ និង១៩៤០ ត្រូវតែចាត់ទុកថាជាវិធីសាស្ត្រងាយស្រួលក្នុងការចង្អុលបង្ហាញដោយមិនបញ្ជាក់ពីលក្ខខណ្ឌអ្វីដែលជា ល័ក្ខខ័ណ្ឌនៃការទទួលយក។ ដូច្នេះតុលាការបានពិចារណាថាមិនអាចមានការសង្ស័យអំពីអត្ថន័យ និងប្រសិទ្ធភាពអ្វីដែលគួរតែត្រូវបានកំណត់ចំពោះសេចក្តីប្រកាសឆ្នាំ១៩៥០ ហើយសម្រេចច្រានចោលអញ្ញត្រកម្មទី១ របស់ថៃ។

**ការជំនុំជម្រះលើអង្គសេចក្តី៖** នៅក្នុងសារណាជា លាយលក្ខណ៍អក្សរ ព្រមទាំងនៅក្នុងអំឡុងសវនាការផ្ទាល់មាត់ជាបន្តបន្ទាប់ កម្ពុជាបានលើកយក "ផែនទីដងរែក" (ផែនទីឧបសម្ព័ន្ធទី១) ដែលជាផែនទីកើតចេញពីសន្ធិសញ្ញាបារាំង-សៀម ឆ្នាំ១៩០៤ មកធ្វើជាមូលដ្ឋានច្បាប់។ តាមរយៈបន្ទាត់ព្រំដែន នៅក្នុងផែនទីឧបសម្ព័ន្ធទី១នេះ បង្ហាញថា ប្រាសាទព្រះវិហារស្ថិតនៅក្នុងទឹកដីរបស់កម្ពុជា។ ថៃបានវិញបានលើកឡើងថា នៅក្នុងពាក្យបណ្តឹងដំបូង កម្ពុជាទាមទារតែរឿងប្រាសាទព្រះវិហារប៉ុណ្ណោះ មិនបាននិយាយអំពីបញ្ហាព្រំដែននោះទេ។ ដូច្នេះតុលាការមិនអាចសម្រេចសេចក្តីទាក់ទងនឹងបញ្ហាព្រំដែនកម្ពុជា-ថៃបានទេ។ យ៉ាងនេះក៏ដោយក្តី តុលាការយល់ឃើញថា ភាគីសងខាងនិយាយថា ប្រាសាទព្រះវិហារលើទឹកដីពួកគេដូចនេះបញ្ហានៃជម្លោះគឺជម្លោះស្តីពីអធិបតេយ្យដែនដីហើយ ម្ល៉ោះហើយ តុលាការចាំបាច់ត្រូវតែកំណត់អំពីព្រំដែនរវាងកម្ពុជា និងថៃ នៅក្នុងតំបន់នេះ។ ថៃបន្តប្រឆាំងថា ខ្សែបន្ទាត់ព្រំដែន នៅក្នុងផែនទីនេះ ខុសពីអ្វីដែលបានចែងនៅក្នុងសន្ធិសញ្ញាបារាំង-សៀម ឆ្នាំ១៩០៤។ យោងតាមមាត្រា១ នៃសន្ធិសញ្ញានេះ សៀម និងបារាំង បានព្រមព្រៀងគ្នាថា ខ្សែបន្ទាត់ព្រំដែន នៅតំបន់ដងរែក គឺត្រូវយកតាមខ្សែបែងចែកផ្លូវទឹក។ ភាគីថៃយល់ថា បើមើលទៅលើដីជាក់ស្តែង ខ្សែបែងចែកផ្លូវទឹក គឺស្ថិតនៅខាងត្បូងប្រាសាទព្រះវិហារ។ ដូច្នេះ ប្រាសាទព្រះវិហារត្រូវស្ថិតនៅក្នុងទឹកដីថៃ។

ក្នុងសាលក្រមឆ្នាំ១៩៦២ តុលាការក្រុងឡាអេបានលើកឡើងថា មាត្រា១ នៃសន្ធិសញ្ញា ឆ្នាំ១៩០៤ បានចែងកំណត់យកខ្សែបែងចែកផ្លូវទឹកធ្វើជាព្រំដែនពិតមែន ក៏ប៉ុន្តែ នៅក្នុងមាត្រា៣ នៃសន្ធិសញ្ញាដដែលនេះ ចែងថា ការកំណត់ខ្សែបន្ទាត់ព្រំដែនពិតប្រាកដនឹងត្រូវធ្វើឡើងដោយគណៈកម្មការចម្រុះបារាំង-សៀម។

ដូច្នេះ គេអាចសន្និដ្ឋានបានថា មាត្រា១ នៃសន្ធិសញ្ញា ឆ្នាំ១៩០៤ កំណត់ត្រឹមតែលក្ខណៈវិនិច្ឆ័យជាគោលការណ៍ប៉ុណ្ណោះ។ ចំណែកឯខ្សែបន្ទាត់ព្រំដែនពិតប្រាកដគឺ គណៈកម្មការចម្រុះ ដែលជាអ្នកកំណត់។ ដូច្នេះ ខ្សែបន្ទាត់ព្រំដែនដែលគេអាចយកជាផ្លូវការបាន គឺព្រំដែនដែលកើតចេញពីការងាររបស់គណៈកម្មការចម្រុះ។ នៅតំបន់ដងរែក ខ្សែបន្ទាត់ព្រំដែន ដែលកើតចេញពីការងាររបស់គណៈកម្មការចម្រុះបារាំង-សៀម គឺមានតែមួយគត់ គឺខ្សែបន្ទាត់ព្រំដែន នៅក្នុងផែនទីឧបសម្ព័ន្ធទី១ ដែលកម្ពុជាបានលើកយកមកធ្វើជាសំអាង (ទំព័រទី២១ សាលក្រម ឆ្នាំ១៩៦២)។ ដូច្នេះ គេមិនចាំបាច់ស្វែងរកទីតាំងខ្សែបែងចែកផ្លូវទឹកអ្វីនោះទេ។

ភាគីថៃបានបដិសេធថា ផែនទីនេះមិនមែនកើតចេញពីគណៈកម្មការចម្រុះបារាំង-សៀមទេ ហើយថៃក៏មិនដែលទទួលស្គាល់ផែនទីនេះដែរ។ចៅក្រមបានសម្រេចថា ផែនទីឧបសម្ព័ន្ធទី១ គឺស្ថិតក្នុងចំណោមផែនទីទាំង១១ផ្ទាំង ដែលត្រូវបានបោះពុម្ព និងផ្សព្វផ្សាយជាសាធារណៈយ៉ាងទូលំទូលាយ។ ផែនទីនេះត្រូវបានចែកចាយទៅឲ្យរដ្ឋាភិបាលបារាំងផង រដ្ឋាភិបាលសៀមផង និងទៅឲ្យក្រុមអ្នកជំនាញខាងភូមិសាស្ត្រផង ទាំងអ្នកភូមិសាស្ត្របារាំង អ្នកភូមិសាស្ត្រសៀម និងអ្នកភូមិសាស្ត្រធំៗ នៅក្នុងតំបន់។ លើសពីនេះទៅទៀត ផែនទីឧបសម្ព័ន្ធទី១ ត្រូវបានរដ្ឋាភិបាលថៃចែកចាយទៅតម្កល់ទុក នៅឯស្ថានតំណាងរបស់ថៃ ប្រចាំប្រទេសធំៗមួយចំនួន រួមមាន អង់គ្លេស អាល្លឺម៉ង់ រុស្ស៊ី និងសហរដ្ឋអាមេរិក។ ឆ្លងកាត់ការផ្សព្វផ្សាយយ៉ាងទូលំទូលាយបែបនេះ ថៃមិនអាចអះអាងថា ខ្លួនមិនបានដឹង មិនបានទទួលស្គាល់ផែនទីឧបសម្ព័ន្ធទី១បានទេ។

ភស្តុតាងដ៏ជាក់ច្បាស់មួយទៀត គឺចាប់ពីខែមីនា ឆ្នាំ១៩០៩ គណៈកម្មការចម្រុះបារាំង-សៀម បានជួបប្រជុំគ្នាជាច្រើនខែ នៅទីក្រុងបាងកក ប្រទេសថៃ។ កិច្ចប្រជុំនេះមានគោលដៅរៀបចំចងក្រងផែនទីទាំងអស់ធ្វើជាឯកសារតែមួយ និងកំណត់អំពីពាក្យទាំងអស់ដែលត្រូវប្រើនៅក្នុងផែនទីទាំងនេះ ដើម្បីឲ្យស៊ីសង្វាក់គ្នារវាងភាសាបារាំង និងភាសាថៃ។ នៅក្នុងកិច្ចប្រជុំត្រួតពិនិត្យផែនទីនេះ ថៃមិនដែលតវ៉ាជំទាស់នឹងខ្សែបន្ទាត់ព្រំដែននៅក្នុងផែនទីឧបសម្ព័ន្ធទី១នេះផងឡើយ។

ម្យ៉ាងវិញទៀត ការដែលថៃលើកឡើងថា ខ្លួនមានការភាន់ច្រឡំ ហើយមើលមិនឃើញពីភាពមិនប្រក្រតីនៅលើផែនទីដងរែក ក៏ជារឿងមិនសមហេតុផលដែរ ពីព្រោះថា គ្រាន់តែគេមើលផែនទីឧបសម្ព័ន្ធទី១ គេអាចមើលឃើញយ៉ាងច្បាស់អំពីតំបន់ប្រាសាទព្រះវិហារ មិនអាចចន្លោះបានទេ។ នៅលើផែនទីនេះ ទីតាំងប្រាសាទព្រះវិហារត្រូវបានកំណត់ ដោយសញ្ញាសម្គាល់យ៉ាងច្បាស់ ដែលមានរាងជាប្លង់តួប្រាសាទ និងជណ្តើរប្រាសាទ។ ចំណែកខ្សែបន្ទាត់ព្រំដែនត្រូវបានគេគូសបង្ហាញយ៉ាងច្បាស់ នៅខាងជើងប្រាសាទព្រះវិហារ ហើយមិនត្រូវនឹងខ្សែបែងចែកផ្លូវទឹកទេ។ ដូច្នេះ វាជារឿងដែលមិនអាចទៅរួចទេ ដែលថា អ្នកដែលបានមើលផែនទីនេះហើយ តែមើលមិនឃើញអំពីចំណុចនេះ។ ម្យ៉ាងវិញទៀត សមាសភាពខាងភាគីថៃ ដែលជាអ្នកបានឃើញផែនទី

ឧបសម្ព័ន្ធទី១នេះគឺមានរដ្ឋមន្ត្រីក្រសួងការបរទេស រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សមាជិកគណៈកម្មការចម្រុះបារាំង-សៀម, ព្រមទាំងអភិបាលខេត្ត នៅជាប់នឹងតំបន់ប្រាសាទព្រះវិហារ ដែលសុទ្ធសឹងជាអ្នកដែលមានជំនាញខាងភូមិសាស្ត្រ និងស្គាល់ភូមិសាស្ត្រនៅតំបន់ព្រះវិហារយ៉ាងច្បាស់លាស់។

តាមរយៈហេតុផលទាំងនេះ តុលាការបានកំណត់ថា នៅតំបន់ប្រាសាទព្រះវិហារ ព្រំដែនស្របច្បាប់រវាងកម្ពុជា និងថៃ គឺខ្សែបន្ទាត់ព្រំដែន ដែលមានគូសនៅលើផែនទីឧបសម្ព័ន្ធទី១។

ដោយយោងទៅលើខ្សែបន្ទាត់ព្រំដែននេះ តុលាការយុត្តិធម៌អន្តរជាតិ ក្រុងឡាអេបានសម្រេចសេចក្តីថា:

- ប្រាសាទព្រះវិហារស្ថិតនៅក្នុងទឹកដី ដែលស្ថិតក្រោមអធិបតេយ្យរបស់កម្ពុជា (អនុម័តដោយ ៩សំឡេង ទល់នឹង៣)។
- ថៃត្រូវតែដកកងទ័ព ប៉ូលីស ឬឆ្មាំផ្សេងទៀត ដែលឈរជើងនៅក្នុងប្រាសាទ និងនៅជុំវិញប្រាសាទ ក្នុងដែនដីរបស់កម្ពុជា (៩សំឡេង ទល់នឹង៣)។
- ថៃត្រូវប្រគល់ត្រឡប់មកឲ្យកម្ពុជាវិញ នូវរាល់វត្ថុបុរាណ ដូចជា រូបចម្លាក់ សិលាចារឹក គ្រឿងចានឆ្នាំងធ្វើអំពីដី។ល។ ដែលថៃបានយកចេញពីប្រាសាទព្រះវិហារ ឬ ពីតំបន់ប្រាសាទ ក្នុងអំឡុងពេលដែលថៃកាន់កាប់ប្រាសាទ ចាប់តាំងពីឆ្នាំ១៩៥៤មក (៧សំឡេង ទល់នឹង ៥)៕

# ករណីសិក្សាយុត្តាធិការផ្ដល់យោបល់របស់តុលាការយុត្តធម៌អន្តរជាតលើភាពស្របច្បាប់នៃការគំរាមកំហែងឬប្រើប្រាស់អាវុធនុយក្លេអ៊ែរ

**មូលបញ្ហា៖** ស្នើឡើងដោយអង្គការសុខភាពពិភពលោកនៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ១៩៩៣ ដោយមើលឃើញពីផលប៉ះពាល់នៃបរិស្ថាន និងសុខភាពតាមរយៈការប្រើប្រាស់អាវុធប្រល័យលោកដោយរដ្ឋក្នុងសង្គ្រាម និងក្នុងជម្លោះប្រដាប់អាវុធថាជាការបំពានកាតព្វកិច្ចដែលមានក្រោមច្បាប់អន្តរជាតិក៏ដូចជា ធម្មនុញ្ញអង្គការមួយនេះ។ ICJ បានពិចារណាលើសំណើរបស់ WHO ក្នុងករណីណាដែលគេដឹងថាមានភាពស្របច្បាប់នៃការប្រើប្រាស់ដោយរដ្ឋអាវុធនុយក្លេអ៊ែរនៅក្នុងជម្លោះប្រដាប់អាវុធ។ ICJ បានកំណត់យកថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៤ ជាពេលវេលាកំណត់សម្រាប់ការដាក់ស្នើជាលាយលក្ខណ៍អក្សរប៉ុន្តែបន្ទាប់ពីទទួលបានការសរសេរលាយលក្ខណ៍អក្សរ និងផ្ទាល់មាត់ជាច្រើនក្រោយមកបានពន្យារកាលបរិច្ឆេទនេះរហូតដល់ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៩៤។ បន្ទាប់ពីបានពិចារណាលើករណីនេះតុលាការបានបដិសេធមិនផ្ដល់យោបល់លើសំណួររបស់ WHO ឡើយ។ តាមសេចក្ដីសម្រេចនៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៩៩៦ ដោយសំលេង១១ ទល់នឹង៣ ថាសំនួរមិនស្ថិតក្នុងវិសាលភាពនៃសកម្មភាពរបស់អង្គការសុខភាពពិភពលោកដូចមានចែងក្នុងមាត្រា៩៦ (២) នៃធម្មនុញ្ញអង្គការសហប្រជាជាតិឡើយ។ លុះនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៤ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តសេចក្ដីសម្រេច A/RES/49/75K ដោយបានស្នើសុំឱ្យ ICJ ប្រញាប់ផ្ដល់យោបល់ប្រឹក្សារបស់ខ្លួនលើសំណួរខាងក្រោមដែលមានប្រទេស៧៨គាំទ្រ ៤៣ប្រឆាំង ៣៨អនុប្បវាទ និង ២៦មិនបោះឆ្នោតគាំទ្រដូចខាងក្រោម៖

## តើការគំរាមកំហែងឬការប្រើប្រាស់អាវុធនុយក្លេអ៊ែរក្នុងកាលៈទេសៈណាដែលត្រូវបានអនុញ្ញាតក្រោមច្បាប់អន្តរជាតិ?

**ដំណើរការ៖** ជាបន្តបន្ទាប់តុលាការបានកំណត់យកថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៩៥ ជាកាលបរិច្ឆេទនៃការដាក់ពាក្យសម្រាប់សេចក្ដីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ។

រដ្ឋចំនួន៤២ បានចូលរួមក្នុងដំណាក់កាលជាលាយលក្ខណ៍អក្សរនៃការអង្វរករដែលជាចំនួនច្រើនបំផុតដែលមិនធ្លាប់មានដើម្បីចូលរួមក្នុងដំណើរការសវនាការនៅចំពោះមុខតុលាការ។ ក្នុងចំណោមរដ្ឋទាំង៥ ដែលប្រកាសថាមានអាវុធនុយក្លេអ៊ែរមានតែសាធារណរដ្ឋប្រជាមានិតចិនប៉ុណ្ណោះ ដែលមិនបានចូលរួម។ ក្នុងចំណោមប្រទេសដែលមានអាវុធនុយក្លេអ៊ែរចំនួន៣ គឺមានតែឥណ្ឌាទេដែលបានចូលរួម។ អ្នកចូលរួមជាច្រើនជារដ្ឋកំពុង

អភិវឌ្ឍដែលមិនធ្លាប់បានរួមចំណែកក្នុងដំណើរការនីតិវិធីនៅចំពោះមុខ ICJ ដែលជាការឆ្លុះបញ្ចាំងអំពីចំណាប់អារម្មណ៍ដែលមិនអាចប្រៀបផ្ទឹមបានចំពោះបញ្ហានេះ។

សវនាការផ្ទាល់មាត់ត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី៣០ ខែតុលា ដល់ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥។ សាម័រ កោះម៉ាស្សល កោះសាឡូម៉ូន កូស្តារីកា ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក ហ្សីមបាវេ ដូច WHO តែលេខាធិការដ្ឋានរបស់អង្គការសហប្រជាជាតិមិនបានបង្ហាញខ្លួនទេ ប៉ុន្តែបានដាក់ពាក្យបណ្ដឹងទៅតុលាការអំពីប្រវត្តិនៃដំណោះស្រាយ ៤៩/៧៥K។ រដ្ឋនីមួយៗត្រូវបានផ្តល់ពេល៩០ នាទី ដើម្បីធ្វើសេចក្តីថ្លែងការណ៍របស់ខ្លួន។ នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៩៩៦ ជិតប្រាំបីខែ បន្ទាប់ពីការបិទដំណាក់កាលផ្ទាល់មាត់ ICJ បានផ្តល់យោបល់របស់ខ្លួន។

សេចក្ដីសម្រេចយោបល់៖ ICJ មានសមាសភាពចៅក្រម១៥ រូបដែលត្រូវបានជ្រើសរើសដោយមហាសន្និបាតអង្គការសហប្រជាជាតិ និងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។ យោបល់ប្រឹក្សារបស់តុលាការអាចត្រូវបានស្នើសុំដោយអង្គការជាក់លាក់របស់អង្គការសហប្រជាជាតិ តែប៉ុណ្ណោះហើយវាមិនជាប់កាតព្វកិច្ចតាមលក្ខន្តិកៈរបស់តុលាការឡើយ។

ចៅក្រមទាំង១៥ រូបបានសុំផ្តល់យោបល់យោបល់របស់ពួកគេទាក់ទងនឹងភាពស្របច្បាប់នៃការគំរាមកំហែង ឬ ការប្រើប្រាស់អាវុធនុយក្លេអ៊ែរគឺមានសមាសភាពមកពី អាមេរិក ជប៉ុន បារាំង ហ្គុយយ៉ាណា ស្រីលង្កា អាល់ហ្សេរី ម៉ាដាហ្គាស្កា ចិន អាល្លឺម៉ង់ ហុងគ្រី សៀរ៉ាឡេអូន រុស្ស៊ី អ៊ីតាលី អង់គ្លេស វ៉េណាស៊ុយអេឡា និងកូឡុំប៊ី។ តុលាការបានពិចារណាលើបញ្ហា នៃការរារាំងដែលពាក់ព័ន្ធនឹងការគំរាមកំហែងប្រើប្រាស់អាវុធនុយក្លេអ៊ែរក្នុងកាលៈទេសៈជាក់លាក់ណាមួយលើសត្រូវ។ តើការគំរាមកំហែងបែបនេះខុសច្បាប់ទេ? តុលាការបានសំរេចដោយមានចៅក្រមខ្លះជំទាស់ថាប្រសិនបើការធ្វើការវាយប្រហារសងសឹកគំរាមកំហែងស្របតាមតម្រូវការយោធា និងសមាមាត្រនោះវាមិនចាំបាច់ខុសច្បាប់ទេ។

ភាពស្របច្បាប់នៃការកាន់កាប់អាវុធនុយក្លេអ៊ែរ៖ បន្ទាប់មកតុលាការបានពិចារណាពីភាពស្របច្បាប់នៃការកាន់កាប់នេះដែលផ្ទុយពីការប្រើប្រាស់អាវុធនុយក្លេអ៊ែរពិតប្រាកដ។ តុលាការបានពិនិត្យមើលសន្ធិសញ្ញាផ្សេងៗ រួមទាំងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិផងដែរ ហើយរកមិនឃើញភាសាសន្ធិសញ្ញាដែលហាមឃាត់ ជាពិសេសការកាន់កាប់អាវុធនុយក្លេអ៊ែរតាមប្រភេទជាក់លាក់។

ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិត្រូវបានពិនិត្យនៅក្នុងកថាខណ្ឌ៣៧-៥០ ដែលកថាខណ្ឌ៣៧ ដែលបញ្ជាក់ថា ឥឡូវនេះតុលាការនឹងដោះស្រាយបញ្ហានៃភាពស្របច្បាប់ឬភាពខុសច្បាប់នៃការទាមទារអាវុធ

នុយក្លេអ៊ែរដោយផ្អែកលើបទប្បញ្ញត្តិនៃធម្មនុញ្ញទាក់ទងនឹងការគំរាមកំហែង ឬ ការប្រើប្រាស់កម្លាំងដែលគ្មានការសំដៅលើការប្រើអាវុធជាក់លាក់ ហើយអាវុធដែលមិនស្របច្បាប់ក្រោមធម្មនុញ្ញ។

សន្ធិសញ្ញាត្រូវបានពិនិត្យនៅក្នុងកថាខ័ណ្ឌ៥៣-៦៣ ដែលកថាខណ្ឌ៥៣ គឺដូច្នេះតុលាការតឡូវត្រូវពិនិត្យមើលថាតើ មានការហាមឃាត់ណាមួយក្នុងការទាមទារឱ្យមានអាវុធនុយក្លេអ៊ែរដែររឺទេ ជាពិសេសទាក់ទងនឹងការជំទាស់ដែលបានឈានមុខគេថាអាវុធនុយក្លេអ៊ែរគួរតែត្រូវបានវិនិច្ឆ័យដូចការប្រើអាវុធពុលដែរ។ ទាក់ទងនឹងអនុសញ្ញាទីក្រុងឡាអេ ឆ្នាំ១៨៩៩ ទាក់ទងនឹងការប្រើប្រាស់អាវុធបាក់តេរីឬគីមីគឺតុលាការព្រួយបារម្ភចំពោះការអាវុធនុយក្លេអ៊ែរដែរតែតុលាការ មិនរកឃើញការហាមឃាត់ជាក់លាក់ណាមួយក្នុងការទាមទារឱ្យមានអាវុធនុយក្លេអ៊ែរនៅក្នុងសន្ធិសញ្ញាហាមឃាត់ការប្រើអាវុធប្រល័យពូជសាសន៍ជាក់លាក់ណាមួយឡើយ។

ដោយគោរពទៅនឹងសន្ធិសញ្ញាដែលដោះស្រាយទាំងស្រុងជាមួយ ការទិញការផលិតការកាន់កាប់ការដាក់ពង្រាយ និងការសាកល្បងអាវុធនុយក្លេអ៊ែរដោយមិននិយាយជាក់លាក់អំពីការគំរាមកំហែង ឬ ការប្រើប្រាស់របស់ពួកគេ តុលាការកត់សំគាល់ថាសន្ធិសញ្ញាទាំងនោះពិតជាបង្ហាញពីការព្រួយបារម្ភកាន់តែខ្លាំងឡើងនៅក្នុង សហគមន៍អន្តរជាតិជាមួយអាវុធទាំងនេះ។ តុលាការសន្និដ្ឋានពីនេះថាសន្ធិសញ្ញាទាំងនេះអាចត្រូវបានគេមើលឃើញថាជាការបង្ហាញពីការហាមឃាត់ជាទូទៅនៃការប្រើប្រាស់អាវុធបែបនេះនាពេលអនាគតប៉ុន្តែវាមិនបង្កើតជាការហាមឃាត់ដោយខ្លួនពួកគេទេ ។ ដូចគ្នានេះដែរទាក់ទងនឹងសន្ធិសញ្ញាតំបន់ហាមឃាត់ធនធានដូចជា Tlatelolco (អាមេរិកឡាទីន) និង Rarotonga (ប៉ាស៊ីហ្វិកខាងត្បូង) តុលាការកត់សំគាល់ថាខណៈពេលដែលសក្ខីកម្មរំដោះសហគមន៍រដ្ឋនិងសាធារណជនអន្តរជាតិពីគ្រោះថ្នាក់ ក៏តុលាការមិនចាត់ទុកធាតុទាំងនេះថាជាការហាមឃាត់ធម្មតា និងទូលំទូលាយជាសកលស្តីពីការប្រើប្រាស់ឬការគំរាមកំហែងនៃការប្រើប្រាស់អាវុធទាំងនោះដែរ។ ច្បាប់អន្តរជាតិប្រពៃណីក៏បានផ្តល់ភស្តុតាងមិនគ្រប់គ្រាន់ដែលថាការកាន់កាប់អាវុធនុយក្លេអ៊ែរត្រូវបានគេចាត់ទុកថាជាអំពើខុសច្បាប់ជាសកល។

នៅទីបំផុតតុលាការមិនអាចស្វែងរកយុត្តាធិការ ដែលជាការឯកភាពផ្លូវច្បាប់ ថាអាវុធនុយក្លេអ៊ែរគឺជាកម្មសិទ្ធិខុសច្បាប់។ ទោះយ៉ាងណាក៏ដោយក្រោយសង្គ្រាមតាំងពីឆ្នាំ១៩៤៥ មិនមានការប្រើអាវុធនុយក្លេអ៊ែរទេ ហើយមានដំណោះស្រាយជាច្រើនរបស់អង្គការសហប្រជាជាតិដែលថ្កោលទោសការប្រើប្រាស់។ យ៉ាងណាដំណោះស្រាយបែបនេះមិនត្រូវបានគាំទ្រជាសកលទេ ជាពិសេសគួរឱ្យកត់សម្គាល់ថាមហាអំណាចនុយក្លេអ៊ែរជំទាស់នឹងការប្រើប្រាស់រវាងគ្នា។ ICJ មិនបានរកឃើញថាការពិតទាំងនេះបានបង្ហាញពីច្បាប់ទម្លាប់ថ្មី និងច្បាស់លាស់ដែលហាមឃាត់អាវុធនុយក្លេអ៊ែរជាដាច់ខាត។

ទោះយ៉ាងណាក៏ដោយមានច្បាប់មនុស្សធម៌សកលជាច្រើនដែលអនុវត្តចំពោះសង្គ្រាម។ ឧទាហរណ៍វាជាអំពើខុសច្បាប់សម្រាប់យុទ្ធជនពិសេសសំដៅទៅលើជនស៊ីវិលហើយអាវុធប្រភេទខ្លះដែល បង្កការខូចខាតដោយមិនរើសអើងត្រូវបានហាមឃាត់ដោយខុសច្បាប់។ រដ្ឋទាំងអស់ហាក់ដូចជាគោរពច្បាប់ទាំងនេះដែលធ្វើឱ្យពួកគេក្លាយជាផ្នែកមួយនៃច្បាប់អន្តរជាតិប្រពៃណី ដូច្នេះតុលាការបានសំរេចថាច្បាប់ទាំងនេះនឹងអនុវត្តចំពោះការប្រើប្រាស់អាវុធនុយក្លេអ៊ែរផងដែរ។ ការប្រើប្រាស់អាវុធនុយក្លេអ៊ែរអាចជាច្បាប់ប្រសិនបើអនុវត្តជាជម្រើសចុងក្រោយក្នុងកាលៈទេសៈធ្ងន់ធ្ងរ (ដូចជាប្រសិនបើរដ្ឋមានស្ថានភាពគ្រោះថ្នាក់)។

ការសម្រេចចិត្តៈ តុលាការបានអនុម័តសំឡេង ៧ ផ្សេងគ្នាដែលទាំងអស់នេះត្រូវបានអនុម័តដូចតទៅៈ

- តុលាការបានសំរេចអនុវត្តតាមការស្នើសុំយោបល់(១៣ទល់១)
- តុលាការបានឆ្លើយតបថាមិនមានប្រពៃណីទំនៀមទំលាប់និងច្បាប់អន្តរជាតិណាមួយដែលមានការអនុញ្ញាតជាក់លាក់ណាមួយពីការគំរាមកំហែងឬការប្រើប្រាស់អាវុធនុយក្លេអ៊ែរឡើយ(១៤ទល់០)
- តុលាការបានឆ្លើយតបថាមិនមានប្រពៃណីទំនៀមទំលាប់ និងច្បាប់អន្តរជាតិណាមួយឡើយ ដែលមាន។ ការហាមឃាត់ទូលំទូលាយនិងជាសកលចំពោះការគំរាមកំហែងឬការប្រើប្រាស់អាវុធនុយក្លេអ៊ែរ (១១ទល់៣)
- តុលាការបានឆ្លើយតបថាការគំរាមកំហែង ឬ ការប្រើប្រាស់កម្លាំងដោយមធ្យោបាយអាវុធនុយក្លេអ៊ែរដែលផ្ទុយនឹងមាត្រា២ កថាខណ្ឌទី៤ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ហើយដែលមិនបំពេញតាមតម្រូវការទាំងអស់នៃមាត្រា៥១ គឺមិនស្របច្បាប់ (១៤ទល់០)
- តុលាការបានឆ្លើយតបថាការគំរាមកំហែង ឬ ការប្រើប្រាស់អាវុធនុយក្លេអ៊ែរក៏គួរតែត្រូវគ្នាទៅនឹងតម្រូវការនៃច្បាប់អន្តរជាតិដែលអាចអនុវត្តបាននៅក្នុងជម្លោះប្រដាប់អាវុធជាពិសេសគោលការណ៍ និងច្បាប់នៃច្បាប់មនុស្សធម៌ក៏ដូចជាកាតព្វកិច្ចជាក់លាក់ក្រោមសន្ធិសញ្ញា និងកិច្ចការផ្សេងទៀត ដែលបង្ហាញយ៉ាងច្បាស់អំពីអាវុធនុយក្លេអ៊ែរ (១៤ទល់០)
- តុលាការបានឆ្លើយតបថាការគំរាមកំហែង ឬ ការប្រើប្រាស់អាវុធនុយក្លេអ៊ែរជាទូទៅនឹងផ្ទុយទៅនឹងវិធាននៃច្បាប់អន្តរជាតិដែល អាចអនុវត្តបាននៅក្នុងជម្លោះប្រដាប់អាវុធហើយជាពិសេសគោលការណ៍និងវិធាននៃច្បាប់មនុស្សធម៌។ ហើយធាតុផ្សំ នៃការពិតដែលតុលាការមិនអាចសន្និដ្ឋានបានច្បាស់លាស់ ថាតើការគំរាមកំហែងឬការប្រើប្រាស់អាវុធនុយក្លេអ៊ែរនឹងស្របច្បាប់ឬមិនស្របច្បាប់ក្នុងកាលៈទេសៈធ្ងន់ធ្ងរ នៃការការពារខ្លួនដែលក្នុងនោះការរស់រានមានជីវិតរបស់រដ្ឋនឹងស្ថិតក្នុងគ្រោះថ្នាក់ (៧ទល់៧)

- តុលាការបានឆ្លើយតបថាមានកាតព្វកិច្ចបន្តដោយស្មោះត្រង់ និងនាំឱ្យមានការចរចាបញ្ចប់ដែលនាំឱ្យមានការរំសាយអាវុធនុយក្លេអ៊ែរនៅគ្រប់ទិដ្ឋភាពទាំងអស់ ក្រោមការត្រួតពិនិត្យអន្តរជាតិដ៏តឹងរឹង និងមានប្រសិទ្ធភាព (១៤ទល់០)

ការបោះឆ្នោតឧត្តមានុភាព៖ ទាក់ទិននឹងការគំរាមកំហែងឬការប្រើប្រាស់អាវុធនុយក្លេអ៊ែរជាទូទៅនឹងផ្ទុយទៅនឹងច្បាប់ នៃច្បាប់អន្តរជាតិដែលអាចអនុវត្តក្នុងជម្លោះប្រដាប់អាវុធដោយមិនរាប់បញ្ចូលទាំងកាលៈទេសៈធ្ងន់ធ្ងរនៃការការពារខ្លួនដែលក្នុងនោះ ការរស់រានមានជីវិត នៃរដ្ឋមួយនឹងស្ថិតនៅក្នុងហានិភ័យ។ ទោះយ៉ាងណាក៏ដោយចៅក្រម៣ នាក់ក្នុងចំណោម៧ នាក់ បានសរសេរមតិដោយឡែកដោយពន្យល់ថាហេតុផលដែលពួកគេខ្វែងគំនិតគ្នាគឺ ថាពួកគេមិនមានករណីលើកលែង កាលៈទេសៈណាក៏ដោយ (រួមទាំងការធានានូវការរស់រានរបស់រដ្ឋមួយ) ចំពោះគោលការណ៍ទូទៅដែលថាការប្រើប្រាស់អាវុធនុយក្លេអ៊ែរគឺ ខុសច្បាប់។ អ្នកជំទាស់ទី៤ គឺចៅក្រមអូដានៃប្រទេសជប៉ុនបានជំទាស់ភាគច្រើនដោយសំអាងថាតុលាការមិនគួរបើកសវនាការរឿងនេះទេ។ អនុប្រធាន Schwebel បានកត់សម្គាល់នៅក្នុងទស្សនៈដែលមិនយល់ស្របរបស់លោកថា វាមិនអាចទទួលយកបានទេថាការប្រើប្រាស់អាវុធនុយក្លេអ៊ែរក្នុងកម្រិតមួយដែលអាចបណ្តាល ឱ្យមនុស្សរាប់លាននាក់ស្លាប់នៅក្នុងឧបទ្ទវហេតុដែលមិនរើសអើង និងដោយការឈានដល់ចំណុចកំពូលមានផលអាក្រក់ក្នុងលំហនិងពេលវេលាហើយមិនអាចរស់នៅបានច្រើន ឬ ទាំងអស់នៃផែនដីអាចស្របច្បាប់។ទោះយ៉ាងណាមតិរបស់តុលាការមិនបានសន្និដ្ឋានច្បាស់លាស់និងជាប្រភេទឡើយ ថាតើស្ថិតក្នុងកាលៈទេសៈធ្ងន់ធ្ងរនៃការការពារខ្លួន ថាយកការគំរាមកំហែង ឬ ប្រើប្រាស់ជាអំពើខុសច្បាប់ តែតុលាការបានបញ្ជាក់ជាឯកច្ឆន្ទថាបណ្តារដ្ឋនានានៅលើពិភពលោកមានកាតព្វកិច្ចចងចរចាដោយសុចរិតនិងសម្រេចបាននូវការរំសាយអាវុធនុយក្លេអ៊ែរ។

# ករណីសិក្សាស្តីពីយុត្តាធិការតុលាការព្រហ្មទណ្ឌអន្តរជាតនៃសំណុំរឿងអតីតប្រធានាធិបតីស៊ូដង់ខាងត្បូង លោក Omar Hassan Ahmad Al Bashir

## សង្ខេបអង្គហេតុ

ប្រធានាធិបតីស៊ូដង់លោក Omar Hassan Ahmad Al Bashir ត្រូវបានបណ្តេញចេញពីតំណែងរបស់ខ្លួនដោយសារតែបញ្ហាសង្គ្រាម។ គាត់បានឡើងកាន់អំណាចដោយការធ្វើរដ្ឋប្រហារយោធាក្នុងឆ្នាំ១៩៨៩ ហើយបានគ្រប់គ្រងប្រទេសដ៏ធំមួយនៅក្នុងទ្វីបអាហ្វ្រិករហូតដល់ ឆ្នាំ២០១១។ នៅពេលដែលគាត់បានដណ្តើមអំណាចស្របពេលដែលប្រទេសស៊ូដង់ស្ថិតនៅចំពេលមានសង្គ្រាមស៊ីវិលរយៈពេល២១ឆ្នាំ រវាងខាងជើង និងខាងត្បូង។ ថ្វីបើរដ្ឋាភិបាលរបស់គាត់បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងដើម្បីបញ្ចប់ជម្លោះនោះក្នុងឆ្នាំ២០០៥ក៏ដោយ ក៏កិច្ចព្រមព្រៀងមួយទៀតបានផ្ទុះឡើងក្នុងពេលតែមួយនៅតំបន់ដាហ្វួខាងលិច (Western region of Darfur) ដែលលោក Bashir ត្រូវបានចោទប្រកាន់ពីបទរៀបចំឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយតុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICC) ។

ថ្វីបើមានដីកាចាប់ខ្លួនអន្តរជាតិដែលចេញដោយ ICC ក៏ដោយក៏គាត់បានឈ្នះការបោះឆ្នោតជាប់ៗគ្នាក្នុងឆ្នាំ២០១០ និង ២០១៥។ ទោះយ៉ាងណាជ័យជម្នះចុងក្រោយរបស់គាត់ត្រូវបានរាំងដោយការធ្វើពហិការពីគណបក្សប្រឆាំងធំ ៗ ។

ដីកាចាប់ខ្លួននេះបាននាំឱ្យមានការហាមឃាត់ការធ្វើដំណើរទៅក្រៅប្រទេស។ ទោះយ៉ាងណាលោក Bashir នៅតែធ្វើទស្សនកិច្ចការទូតទៅកាន់ប្រទេសផ្សេងៗរួមមានអេហ្ស៊ីបអារ៉ាប៊ីសាអូឌីត និងអាហ្វ្រិខាងត្បូង។ ប៉ុន្តែគាត់ត្រូវបានបង្ខំឱ្យចាកចេញយ៉ាងលឿនពីអាហ្វ្រិកខាងត្បូងនៅខែមិថុនា ឆ្នាំ២០១៥ បន្ទាប់ពីតុលាការបានពិចារណាថាតើត្រូវអនុវត្តដីកាចាប់ខ្លួន ឬយ៉ាងណា។ មុននឹងឡើងកាន់តំណែងជាមេបញ្ជាការកងទ័ពដែលទទួលខុសត្រូវដឹកនាំប្រតិបត្តិការនៅភាគខាងត្បូងប្រឆាំងនឹងមេដឹកនាំឧទ្ទាម ចន ហ្គារ៉ាងចុង(John Garang)។

នៅពេលដែលគាត់បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពជាមួយហ្គារ៉ាង (Garang) និងចលនារំដោះប្រជាជនស៊ូដង់របស់គាត់គាត់បានព្យាយាមសង្កត់ធ្ងន់លើកិច្ចព្រមព្រៀងនេះមិនមែនជាបរាជ័យទេ។ លោកបានមានប្រសាសន៍ថា "យើងមិនបានចុះហត្ថលេខាលើវាទេបន្ទាប់ពីយើងបានបែកបាក់គ្នាប៉ុន្តែពួកយើងបានចុះហត្ថលេខាលើវាខណៈពេលដែលយើងកំពុងឈានដល់ចំណុចកំពូលនៃជ័យជម្នះរបស់យើង"។

## សេចក្តីសម្រេច

លោក Al Bashir ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតក្រោមលក្ខន្តិកៈក្រុងរ៉ូម។ នៅពេលដែលលោក Al Bashir ត្រូវបានអនុញ្ញាតឱ្យចាកចេញពីអាហ្វ្រិកខាងត្បូងនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥ ជនរងគ្រោះនៃឧក្រិដ្ឋកម្មរបស់គាត់ បានរង់ចាំដីកាចាប់ខ្លួនដើម្បីយកលោក Al Bashir ទៅអនុវត្តទោស អស់រយៈពេលជាង ០៦ឆ្នាំ។ ដើម្បីនាំយកការពិត និងយុត្តិធម៌សម្រាប់ជនរងគ្រោះទាំងនេះតុលាការត្រូវតែអាចប្រើអំណាចរបស់ខ្លួនដើម្បីសាកល្បងជាមួយលោក Al Bashir។ តែងតែមានការរំពឹងថានឹងមានការចាប់ខ្លួនកំឡុងពេលចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥ ខណៈពេលដែលលោក Al Bashir កំពុងស្ថិតនៅលើទឹកដីនៃប្រទេសអាហ្វ្រិកខាងត្បូង ដែលគួរធ្វើតាមសំណើរបស់តុលាការចាប់ខ្លួន និងប្រគល់រូបលោកទៅតុលាការ។ ផ្ទុយទៅវិញអាហ្វ្រិកខាងត្បូងបានជួយសម្រួលដល់លោក Al Bashir ឱ្យធ្វើការចាកចេញ ដែលវាប្រឆាំងនឹងច្បាប់ជាតិ និងអន្តរជាតិ។

ចៅក្រមម្នាក់បានធ្វើអ្វីទាំងអស់ដែលគាត់អាចធ្វើបានដើម្បីឱ្យអាហ្វ្រិកខាងត្បូងអនុវត្តតាមសំណើ ដែលកំពុងរង់ចាំ។ ធ្វើការប្រឆាំងនឹងពេលវេលាគាត់បានពិគ្រោះយោបល់ជាមួយអាហ្វ្រិកខាងត្បូងបាន ដំណឹងអំពីការបញ្ជូនរបស់អាហ្វ្រិកខាងត្បូងហើយបានរំលឹកឡើងវិញអំពីច្បាប់ដែលអនុវត្ត និងដឹកនាំយុត្តាធិការដោយហេតុនេះអាចបំបាត់ភាពមិនច្បាស់លាស់ណាមួយដែលអះអាងដោយ អាហ្វ្រិកខាងត្បូងដោយគោរពតាមកាតព្វកិច្ចរបស់ខ្លួនក្រោមលក្ខន្តិកៈ។ ដោយសម្រេចចិត្តមិនចាប់ខ្លួន និងការចុះចាញ់លោក Al Bashir អាហ្វ្រិកខាងត្បូងបានរារាំងតុលាការមិនឱ្យអនុវត្តមុខងារ និងអំណាចច្បាប់។

ការបញ្ជូនទៅ ASP និងUNSC គឺជាមធ្យោបាយដោះស្រាយដ៏សមស្របនៅក្នុងកាលៈទេសៈ។ ខណៈពេលវាយឺតពេលហើយសម្រាប់ការបញ្ជូនបែបនេះដើម្បីទទួលបានការអនុលោមតាមករណីពិសេសនេះរបស់អាហ្វ្រិកខាងត្បូង ១៥៧ វានឹងជួយនៅពេលអនាគតប្រសិនបើបុគ្គលប្រឆាំងដែលមានដីកាចាប់ខ្លួនដ៏លេចធ្លោម្នាក់បានទៅទស្សនកិច្ចនៅអាហ្វ្រិកខាងត្បូង ឬរដ្ឋភាគីផ្សេងទៀតហើយអាចការពារការកើតឡើងវិញនៃការមិនគោរពតាមបញ្ញត្តិច្បាប់នេះ។

**ការសង្ខេបគ្រឹះស្ថាននានា**

ដោយមូលហេតុដូចបានជម្រាបជូនខាងលើនេះអយ្យការស្នើសុំអង្គជំនុំជម្រះ៖

ក) រកឃើញថា អាហ្វ្រិកខាងត្បូងមិនបានគោរពតាមកាតព្វកិច្ចរបស់ខ្លួនក្រោមលក្ខន្តិកៈទីក្រុងរ៉ូមដោយមិនចាប់ខ្លួន និងប្រគល់លោកអាល់បាសៀទៅតុលាការខណៈពេលដែលគាត់នៅលើទឹកដីអាហ្វ្រិកខាងត្បូង ទោះបីជាបានទទួលសំណើក៏ដោយ ដោយតុលាការតាមមាត្រា៨៧ និង មាត្រា៨៩ នៃលក្ខន្តិកៈទីក្រុងរ៉ូម សម្រាប់ការចាប់ខ្លួន និងការចុះចាញ់របស់លោក Al Bashir

ខ) កំណត់ថាកាលៈទេសៈ គឺថាការរកឃើញជាផ្លូវការនៃការមិនអនុលោមតាមអាហ្វ្រិកខាងត្បូងក្នុងន័យនេះ និងការបញ្ជូនបញ្ហានេះទៅសភានៃរដ្ឋភាគីនៃលក្ខន្តិកៈទីក្រុងរ៉ូម និងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិយោងតាមមាត្រា៨៧ (៧) នៃលក្ខន្តិកៈត្រូវបានធានា។

# សេចក្តីសន្និដ្ឋាន

តុលាការយុត្តិធម៌អន្តរជាតិ ត្រូវបានគេហៅថាជាតុលាការពិភពលោកដោយសារតុលាការនេះជាស្ថាប័នចម្បងមួយរបស់អង្គការសហប្រជាជាតិ និងមានវិសាលភាពនៅប្រទេសភាគច្រើនទូទាំងពិភពលោកដែលជាសមាជិកអង្គការសហប្រជាជាតិទទួលស្គាល់យុត្តាធិការរបស់អង្គការនេះ។ តុលាការនេះប្រៀបបានដូចជាអ្នកស្នងតំណែងពីតុលាការអចិន្ត្រៃយ៍នៃយុត្តិធម៌អន្តរជាតិអាចដោះស្រាយវិវាទច្បាប់អន្តរជាតិ រវាងប្រទេសសមាជិកអង្គការសហប្រជាជាតិទាំង ១៩៣។ យុត្តាធិការរបស់តុលាការនេះមានពីរប្រភេទគឺ លើជម្លោះអន្តរជាតិហើយមានសមត្ថកិច្ចតែលើរដ្ឋជាតួអង្គទីមួយ នៃនីតិអន្តរជាតិប៉ុណ្ណោះ។ តុលាការនេះក៏មានយុត្តាធិការផ្នែកប្រឹក្សាយោបល់ឱ្យរដ្ឋ និងអង្គការអន្តរជាតិដែលមានសមត្ថកិច្ចក្នុងក្របខណ្ឌ និងឱវាទអង្គការសហប្រជាជាតិ។ សម្រាប់យុត្តាធិការរបស់តុលាការលើជម្លោះអន្តរជាតិគឺ រដ្ឋអាចកសាងបួនរបៀបនៃការទទួលយកយុត្តាធិការរបស់តុលាការជាឯកត្តោភាគី ឬ កាតព្វកិច្ចក៏បាន ដោយសន្ធិសញ្ញាក៏បាន ដោយកិច្ចព្រមព្រៀងពិសេស ឬ ការប្រកាសរបស់រដ្ឋឆ្លើយតបក៏បានដែរ។ ភាពខុសគ្នានៃការទទួលយកយុត្តាធិការរបស់តុលាការតាមបួនរបៀបនេះគឺ បើទទួលយកដោយឯកត្តោភាគីគឺយោងតាមមាត្រា៣៦(២) នៃលក្ខន្តិកៈតុលាការ រដ្ឋអាចប្រកាសពេលណាក៏បានដែរ ក្នុងការទទួលស្គាល់យុត្តាធិការដាច់ខាត និងដោយគ្មានការព្រមព្រៀងពិសេស។ បច្ចុប្បន្ននេះមានតែ ៧៣ប្រទេស ដែលទទួលស្គាល់យុត្តាធិការរបស់តុលាការនេះដោយកាតព្វកិច្ចធ្វើឱ្យវាមានលក្ខណៈដាច់ខាតលើ។ តាមសន្ធិសញ្ញាវិញ គឺមាត្រា៣៦(១) នៃលក្ខន្តិកៈតុលាការបានចែងថាតុលាការមានយុត្តាធិការក្នុងគ្រប់បញ្ហាទាំងអស់ដែលមានចែងជាពិសេសនៅក្នុងសន្ធិសញ្ញា និងអនុសញ្ញាដែលមានសុពលភាព។ ដោយយោងតាមមាត្រា៣៦(១) នៃលក្ខន្តិកៈតុលាការយុត្តាធិការរបស់តុលាការរួមមានសំណុំរឿងទាំងអស់ដែលភាគីសំដៅលើ។ ក្នុងករណីបែបនេះភាគីបង្ហាញការយល់ព្រមរបស់ពួកគេដោយផ្អែកលើមូលដ្ឋានពិសេស ដោយកិច្ចព្រមព្រៀងពិសេសមួយដែលស្នើសុំឱ្យតុលាការជំនុំជម្រះក្តីលើវិវាទជាក់លាក់ណាមួយ។ យុត្តាធិការត្រូវបានប្រគល់ឱ្យតុលាការនៅពេលជូនដំណឹងដល់តុលាការអំពីកិច្ចព្រមព្រៀងពិសេសនោះដែល ភាគច្រើនគេដឹងថាជាសំណុំរឿងទាំងនោះពាក់ព័ន្ធនឹងវិវាទច្បាប់ ទាក់ទងនឹងអធិបតេយ្យភាពទឹកដីឬការកំណត់ព្រំដែនដី ឬ ព្រំដែនសមុទ្រ។ ការទទួលយកយុត្តាធិការរបៀបចុងក្រោយគឺ កើតឡើងពេលដែលរដ្ឋមួយអាចដាក់ពាក្យសុំឯកតោភាគីដើម្បីរៀបចំដំណើរការនីតិវិធីនៅចំពោះមុខតុលាការដោយមិនមានការធានាពីការយល់ព្រមពីរដ្ឋដែលឆ្លើយតប។ នៅដំណាក់កាលនេះតុលាការមិនមាន យុត្តាធិការក្នុងការដោះស្រាយពាក្យស្នើសុំនេះទេរហូតដល់រដ្ឋដែលប្រឆាំងនឹងការស្នើសុំនេះយល់ព្រមពីយុត្តាធិការរបស់តុលាការក្នុងគោលបំណង នៃសំណុំរឿងនោះដែលពេលនោះរដ្ឋនោះអាចទទួលយកយុត្តាធិការរបស់តុលាការដោយសេចក្តីប្រកាសដោយផ្ទាល់។ ចំណែកយុត្តាធិការប្រឹក្សា

យោបល់វិញគឺ គ្របដណ្ដប់តែទៅលើបញ្ហាច្បាប់តែប៉ុណ្ណោះហើយមានតែអង្គការពីរទេមានសមត្ថកិច្ចដោយផ្ទាល់គឺ អង្គការមហាសន្និបាត និងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ចំណែកក្រៅពីនេះគឺសំណើត្រូវពឹងពាក់ទៅអង្គការមានសមត្ថកិច្ចផ្ទាល់ ប៉ុន្តែអង្គការមានសមត្ថកិច្ចផ្ទាល់មិនអាចធ្វើសេចក្ដីសម្រេចប្រានចោលកាត់មុខអំណាចតួនាទីរបស់តុលាការយុត្តិធម៌អន្តរជាតិឡើយ។

ចំណែកតុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវបានគេហៅកាត់ថាជា សាលាក្ដីអចិន្ត្រៃយ៍ដើម្បីកាត់ទោសបុគ្គលពីប្រភេទបទល្មើសចំនួន០៤ ដែលរួមមានបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បទឧក្រិដ្ឋកម្មសង្គ្រាមនិងឧក្រិដ្ឋកម្មនៃការឈ្លានពាន។ បន្ថែមពីនេះបទល្មើសទាំងនេះចាំបាច់ត្រូវបានប្រព្រឹត្តនៅ ឬ ក្រោយថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០២ដោយបុគ្គលនៃរដ្ឋជាសមាជិក ឬ បុគ្គលដែលកាន់សញ្ជាតិរដ្ឋជាសមាជិកលើដែនដីណាក៏ដោយ។

ឧក្រិដ្ឋកម្មទាំងនោះត្រូវបញ្ជូនទៅកាន់ព្រះរាជអាជ្ញា ICC ដោយ UNSC យោងតាមសេចក្ដីសំរេចដែលបានអនុម័តនៅជំពូកទី៧ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ឬ ដោយរដ្ឋណាមួយ ឬ ផ្ដួចផ្ដើមចោទប្រកាន់ដោយរដ្ឋអាជ្ញាខ្លួនឯងតែម្ដង។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិត្រូវបានគេមើលឃើញថាមានភាពស្រដៀងគ្នានឹងតុលាការយុត្តិធម៌អន្តរជាតិដោយសារមានចរិតលក្ខណៈជា តុលាការអន្តរជាតិដូចគ្នាហើយមានសមត្ថកិច្ចទៅលើតួអង្គនៃរដ្ឋជាសមាជិករបស់តុលាការ។ ប៉ុន្តែទម្រង់សមាជិកភាពរបស់ICCគឺ បញ្ជាក់ពីយុត្តាធិការស្រាប់ដែលខុសពីICJអាចជ្រើសបែបបទនៃការទទួលស្គាល់យុត្តាធិការបានច្រើនរបៀបដែលធ្វើឱ្យរបៀបនេះការបញ្ចប់យុត្តាធិការរបស់តុលាការទៅលើរដ្ឋមួយមានរបៀបខុសគ្នាដែលពីរករណីមកហើយការដកខ្លួនពីតុលាការព្រហ្មទណ្ឌអន្តរជាតិ គឺស្មើនឹងការបដិសេធមិនឱ្យតុលាការមានយុត្តាធិការមកលើរដ្ឋ ដែលនេះគឺជាករណីប្រទេសហ្វីលីពីន និងប៊ូរុនឌី។ ICC ក៏ត្រូវបានគេមើលឃើញថាខ្វះយុត្តាធិការដែនដីជា សកលដោយសារតុលាការនេះកាត់ទោសតែនៅពេលណាដែលប្រព័ន្ធតុលាការប្រទេសមួយអលទ្ធភាព ឬ អសមត្ថភាព ខណៈICJភាគច្រើនជារឿងវិវាទអន្តរជាតិដែលជៀសមិនរួចត្រូវតែរដ្ឋមួយលះបង់អធិបតេយ្យមកឱ្យតុលាការមានយុត្តាធិការលើ។

# អនុសាសន៍

ឆ្លងតាមការសិក្សាស្រាវជ្រាវលើអត្ថបទបញ្ចប់សារណាមួយនេះមក ជាការមើលឃើញ និងសូមចូលរួមជាចំណែកលើចំនុចមួយចំនួនដែលពួកខ្ញុំមើលឃើញថាជាចំណុចដែលគួរតែកែទម្រង់ និងបំពេញបន្ថែមនូវចំនុចខ្វះខាត និងភាពចន្លោះប្រហោង។ ក្នុងករណីតុលាការយុត្តិធម៌អន្តរជាតិ (ICJ) មានចំណុចអសមត្ថភាព និងខ្វះមូលដ្ឋាននៃការប្រើប្រាស់យុត្តាធិការ គឺការពិបាកចាប់បង្ខំឱ្យភាគីចុងចោទចូលខ្លួនមកតតាំងក្តី។ **ឧទាហរណ៍៖** ករណី Israel V. Belarus ហើយ ICJ បានត្រឹមតែពិនិត្យមើលយុត្តាធិការរបស់ខ្លួនថាគ្មាន។ ICJ ច្រើនតែពឹងក្រុមប្រឹក្សាសន្តិសុខដែលពូកែខាងសេចក្តីសម្រេចឱ្យមកធ្វើការចូលរួមសម្រេច ប៉ុន្តែមិនមានអ្នកអនុវត្តសាលក្រមដែលវាប្រដូចបានថា ICJ គ្មានអាជ្ញាសាលា មានន័យថាអំណាចសាលក្រមស្រពិចស្រពិល។

ដោយឡែកករណីតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) វិញ ករណីប្រទេសរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរអាចនៅក្រៅសំណាញ់ច្បាប់របស់ ICC ហើយអាចគេចខ្លួនពេលណាក៏បានទៀត មានន័យថា មើលទៅទូលាយហើយ ICC ហាក់ពុំមានចំណាត់ការទាន់ពេលវេលា និងសមត្ថភាពគ្រប់គ្រាន់នៅឡើយទេ។ ចុះហេតុម្តេចក៏យុត្តាធិការរបស់ ICC ចង្អៀត កម្រណាស់បុគ្គលមានអំណាច កម្រអនុវត្តច្បាប់បាន សូម្បីតែការកោះហៅក៏ភាគីមិនបានចូលខ្លួនមកដោះស្រាយតាមសាលដីការកោះរបស់ ICC ហើយមួយវិញទៀតប៉ូលីសអន្តរជាតិក៏ខ្សោយ។

ជារួមមកអនុសាសន៍របស់ពួកយើងខ្ញុំ ដូចបានរៀបរាប់ខាងលើ គ្រាប់តែជាទស្សនៈ និងការមើលឃើញផ្ទាល់ខ្លួនដោយផ្អែកលើការសិក្សា ស្រាវជ្រាវកន្លងមកតែប៉ុណ្ណោះ។ ប្រសិនបើមិត្តអ្នកអានមានការយល់ឃើញខុសពីនេះវាគ្រាន់តែជាការគិតផ្ទាល់ខ្លួន ដោយពួកយើងមានការវិភាគខុសគ្នា ដូច្នេះហើយសូមមិត្តអ្នកអានធ្វើការពិចារណាទៅតាមបរិបទ និងការវិវត្តនៃគថសង្គមជាក់ស្តែង។

# បញ្ជីរូបភាព



តើរដ្ឋនោះជាសមាជិកអង្គការសហប្រជាជាតិទេ ?
No
Yes
តើរដ្ឋនោះជាភាគីរបស់លក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិទេ ?
No
Yes
តើរដ្ឋនោះបានធ្វើសេចក្តីប្រកាសយោងតាមដំណោះស្រាយឆ្នាំ១៩៤៦របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិទេ ?
No
Yes
រដ្ឋនោះមិនអាចចូលតុលាការបានទេ
រដ្ឋនោះអាចចូលទៅកានតុលាការបាន
យុត្តាធិការរបស់តុលាការ
តើរដ្ឋចង់ទទួលយកយុត្តាធិការរបស់តុលាការសម្រាប់ជម្លោះជាក់លាក់
Yes
រដ្ឋអាចបញ្ចប់កិច្ចព្រមព្រៀងពិសេសមួយជាមួយភាគីម្ខាងទៀតចំពោះវិវាទនេះ
រដ្ឋអាចដាក់ពាក្យស្នើសុំនៅចំពោះមុខតុលាការហើយអញ្ជើញរដ្ឋផ្សេងទៀតឱ្យទទួលយកយុត្តាធិការរបស់តុលាការក្នុងគោលបំណងនៃសំណុំរឿងនោះ។ រដ្ឋក៏អាចទទួលយកយុត្តាធិការរបស់តុលាការសម្រាប់គោលបំណងនៃសំណុំរឿងដែលរដ្ឋមួយផ្សេងទៀតបាននាំមកតុលាការ។
No
តើរដ្ឋចង់ទទួលយកយុត្តាធិការរបស់តុលាការក្នុងគ្រប់វិវាទជាមួយរដ្ឋណាមួយដែរឬទេ ?
Yes
រដ្ឋអាចបញ្ចប់សន្ធិសញ្ញាទ្វេភាគីជាមួយរដ្ឋផ្សេងទៀតសម្រាប់គោលបំណងនោះ
No
តើរដ្ឋចង់ទទួលយកយុត្តាធិការរបស់តុលាការក្នុងជម្លោះជាមួយរដ្ឋពិសេសមួយទាក់ទងនឹងការបកស្រាយឬការអនុវត្តសន្ធិសញ្ញាជាក់លាក់ដែរឬទេ ?
Yes
រដ្ឋអាចរួមបញ្ចូលនូវឃ្លាយុត្តាធិការនៅក្នុងសន្ធិសញ្ញាទ្វេភាគីជាក់លាក់
No
តើរដ្ឋចង់ទទួលយកយុត្តាធិការរបស់តុលាការក្នុងគ្រប់វិវាទជាមួយរដ្ឋផ្សេងទៀតទេ ?
Yes
រដ្ឋអាចប្រកាន់ខ្ជាប់ឬបញ្ចប់សន្ធិសញ្ញាពហុភាគីសម្រាប់គោលបំណងនោះ
រដ្ឋអាចធ្វើសេចក្តីប្រកាសទទួលស្គាល់យុត្តាធិការរបស់តុលាការ
No
តើរដ្ឋចង់ទទួលយកយុត្តាធិការរបស់តុលាការក្នុងជម្លោះជាមួយរដ្ឋផ្សេងទៀតទាក់ទងនឹងការបកស្រាយឬការអនុវត្តសន្ធិសញ្ញាជាក់លាក់ដែរឬទេ ?
Yes
រដ្ឋអាចរួមបញ្ចូលនូវឃ្លាយុត្តាធិការនៅក្នុងសន្ធិសញ្ញាពហុភាគីជាក់លាក់
យុត្តាធិការរបស់តុលាការ

**Source (thematic data)**: International Court of Justice, **Credits**: Made with Natural Earth, **Copyrights**: @ 2014 Natural Earth.

**General remarks**: The boundaries and names shown as well as the designations used on this map do not imply official endorsement or acceptance.



# ឯកសារយោង

## ឯកសារជាតិ

### ១. សៀវភៅ និង ឯកសារផ្សេងៗ

- នីតិអន្តរជាតិសាធារណៈ រៀបរៀងដោយ សាស្ត្រាចារ្យ ឡើក ពិដោរ ឆ្នាំ២០១៨
- មូសារ អ៊ីហ្សាម.(២០១៥) តួនាទីរបស់តុលាការយុត្តិធម៌អន្តរជាតិក្នុងការដោះស្រាយជម្លោះអន្តរជាតិ-ឯកសារស្រាវជ្រាវសង្ខេប-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- របាយការណ៍តុលាការព្រហ្មទណ្ឌអន្តរជាតិ ការសម្របនីតិកម្មកម្ពុជាទៅនឹងលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (2006)
- អង្គការអន្តរជាតិ រៀបរៀងដោយ សាស្ត្រាចារ្យ ពៅ សារឿន បោះពុម្ពលើកទី១ ឆ្នាំ២០១០
- Law Journal of Cambodia (ព្រឹត្តិប័ត្រច្បាប់កម្ពុជា): Preah Vihear (khmerlawjournal.blogspot.com)

## ឯកសារអន្តរជាតិ

### ២. ច្បាប់អន្តរជាតិ

- ធម្មនុញ្ញអង្គការសហប្រជាជាតិអនុម័តនៅថ្ងៃទី២៦ឧសភាឆ្នាំ១៩៤៥ និង ចូលជាធរមានថ្ងៃទី២៤តុលាឆ្នាំ១៩៤៥
- លក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ
- លក្ខន្តិកៈនៃតុលាការយុត្តិធម៌អន្តរជាតិអនុម័តនៅថ្ងៃទី២៦ ឧសភា ឆ្នាំ១៩៤៥ និង ចូលជាធរមានថ្ងៃទី២៤ តុលាឆ្នាំ១៩៤៥
- វិធានផ្ទៃក្នុងនៃតុលាការយុត្តិធម៌អន្តរជាតិអនុម័តនៅថ្ងៃទី១៤មេសាឆ្នាំ១៩៤៥ និង ចូលជាធរមាននៅថ្ងៃទី០១កក្កដាឆ្នាំ១៩៧៨

## ៣. ឯកសារយោង


- Alexandrov, S. A. (2006). The Compulsory Jurisdiction of the International Court of Justice: How Compulsory Is It? Chinese Journal of International Law, 5(1), 29–38. https://doi.org/10.1093/chinesejil/jml008
- GRANT GILMORE, *THE INTERNATIONAL COURT OF JUSTICE*, 55 Yale L.J. (1946).
- Romano, Cesare P.R.; Alter, Karen J.; Shany, Yuval (2013). The Oxford Handbook of International Adjudication. Oxford University Press. pp. 4–9. ISBN 9780199660681.
- Ryngaert, C. (n.d.). The concept of jurisdiction in international law. *Research Handbook on Jurisdiction and Immunities in International Law*, 50–75. https://doi.org/10.4337/9781783472185.00007
- Vagias, M. (2011). *The territorial jurisdiction of the International Criminal Court: Certain contested issues*. Bynkershoek Publishing.
- Walsh, J. W. (1901). The True Meaning of the Term "Jurisdiction". The American Law Register (1898-1907), 49(6), 346. https://doi.org/10.2307/3306463


## ៤. គេហទំព័រអន្តរជាតិ


- BBC News. (2015, June 25). What does the International Criminal Court do? https://www.bbc.co.uk/news/world11809908?fbclid=IwAR3gkmNQg1jnmj09WDuGEbV1eyN7ZUDhwrcb9hbnkwaeHM6zO7LOf36Smcg
- BBC News. (2019, August 14). Omar al-Bashir: Sudan's ousted president.
- *How the Court Works | International Court of Justice*. (n.d.). ICJ. Retrieved August 15, 2021, from https://www.icj-cij.org/en/how-the-court-works
- http://www.rfi.fr/km/preah-vihear-case-icj-1962
- https://km.wikipedia.org/wiki/ប្រាសាទព្រះវិហារ
- https://www.icj-cij.org/en/how-the-court-works

- *ICC statement on the Philippines' notice OF withdrawal: State participation in Rome Statute system essential to international rule of law*. International Criminal Court. (2018, March 20). https://www.icc-cpi.int/Pages/item.aspx?name=pr1371.
- Withdraw from ICC in 2016 - Bing. (n.d.). Africa Renewal. Retrieved August 15, 2021, fromhttps://www.bing.com/search?q=withdraw+from+ICC+in+2016&cvid=113d9184eff54801b96b5e1d9ebd77ab&aqs=edge..69i57.9358j0j4&FORM=ANAB01&PC=U531
- How the Court works (icc-cpi.int)

# ឧបសម្ព័ន្ធ

# CHARTER OF THE UNITED NATIONS

AND

# STATUTE OF THE INTERNATIONAL COURT OF JUSTICE

SAN FRANCISCO · 1945

# CHARTER OF THE UNITED NATIONS

WE THE PEOPLES OF THE UNITED NATIONS
DETERMINED

to save succeeding generations from the scourge of war, which twice in our lifetime has brought untold sorrow to mankind, and

to reaffirm faith in fundamental human rights, in the dignity and worth of the human person, in the equal rights of men and women and of nations large and small, and

to establish conditions under which justice and respect for the obligations arising from treaties and other sources of international law can be maintained, and

to promote social progress and better standards of life in larger freedom,

AND FOR THESE ENDS

to practice tolerance and live together in peace with one another as good neighbors, and

to unite our strength to maintain international peace and security, and

to ensure, by the acceptance of principles and the institution of methods, that armed force shall not be used, save in the common interest, and

to employ international machinery for the promotion of the economic and social advancement of all peoples,

HAVE RESOLVED TO COMBINE OUR EFFORTS
TO ACCOMPLISH THESE AIMS.

Accordingly, our respective Governments, through representatives assembled in the city of San Francisco, who have exhibited their full powers found to be in good and due form, have agreed to the present Charter of the United Nations and do hereby establish an international organization to be known as the United Nations.

# CHAPTER I

## PURPOSES AND PRINCIPLES

### *Article 1*

The Purposes of the United Nations are:

1. To maintain international peace and security, and to that end: to take effective collective measures for the prevention and removal of threats to the peace, and for the suppression of acts of aggression or other breaches of the peace, and to bring about by peaceful means, and in conformity with the principles of justice and international law, adjustment or settlement of international disputes or situations which might lead to a breach of the peace;

2. To develop friendly relations among nations based on respect for the principle of equal rights and self-determination of peoples, and to take other appropriate measures to strengthen universal peace;

3. To achieve international cooperation in solving international problems of an economic, social, cultural, or humanitarian character, and in promoting and encouraging respect for human rights and for fundamental freedoms for all without distinction as to race, sex, language, or religion; and

4. To be a center for harmonizing the actions of nations in the attainment of these common ends.

### *Article 2*

The Organization and its Members, in pursuit of the Purposes stated in Article 1, shall act in accordance with the following Principles.

